# មេរៀនធម៌

# ជំនួយសតិ

# ភាគទី ២



រៀបរៀងដោយ

ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស

# សេចក្ដីអនុញ្ញាត

បានឃើញ និងពិនិត្យផ្ទៀងផ្ទាត់ទៅយល់ថា សមស្របមានឱនិបស្ស័យសម្រាប់អ្នកមានបញ្ញាភ្លៀវភ្លា សិក្សារៀនសូត្រ និងយល់ដឹងនូវអត្ថរសអំពីសាច់ធម៌ល្អិតក្នុងព្រះអភិធម្ម ដែលជាថ្នាំសម្រាប់ព្យាបាលរោគឆ្លងទាំងឡាយមានរោគលោកធម៌ឧបាទានធម៌ និង នីវរណៈធម៌ជាដើម ។ ដែលតែងតែនាំចិត្តនិងចេតសិកទៅកាន់ភូមិអបាយ ។

**យល់ព្រម**

វត្តឧណ្ណលោក ភ្នំពេញ

ថ្ងៃ សៅរ៍ ទី ០៨ ខែ មិនា ឆ្នាំ ១៩៩៧

**ទេព វង្ស**

**សម្ដេចព្រះសង្ឃរាជ**

# សេចក្ដីអនុញ្ញាត

បានមើលហើយត្រឹមត្រូវល្អណាស់យល់ឃើញថាគួរបោះពុម្ពផ្សព្វផ្សាយបានដើម្បីបានជាពន្លឺសម្រាប់គ្រប់មជ្ឈដ្ឋាន ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ មិនា ឆ្នាំ ១៩៩៧

**សម្ដេចព្រះមង្គលទេពាចារ្យ**

**អ៊ុម ស៊ុម**

**សង្ឃត្ថេរោ**

# ពាក្យប្រារព្ធ

សៀវភៅ **ជំនួយសតិភាគ ២** នេះ ខ្ញុំព្រះករុណា ខ្ញុំបាទ បានរៀបចំចងក្រងបន្តិចម្តងៗ ក្នុងឆ្នាំសិក្សាធម៌ទី ៨ នៅបាត់ដំបង និង ភ្នំពេញ ។

សៀវភៅ **ជំនួយសតិភាគ ១** បានបោះពុម្ពចែកជាធម្មទានរួចមួយឆ្នាំកន្លងទៅហើយដោយសទ្ធាជ្រះថ្លានៃពុទ្ធបរិស័ទច្រើននាក់ ។ ដោយអក្សរក្នុងសៀវភៅទាំងពីរភាគនេះមានខុសខ្លះ ដូច្នេះសូមពុទ្ធបរិស័ទអ្នកអានមេត្តាអត់នូវទោសអោយដល់ខ្ញុំព្រះករុណា ខ្ញុំបាទផងចុះ ហើយសូមអនុគ្រោះកែតម្រូវនូវអក្សរដែលខុសនោះដោយកុសលចេតនា ។

ខ្ញុំព្រះករុណា ខ្ញុំបាទសូមអនុមោទនានូវកុសលចេតនាក្នុងការបដិបត្តិតាមធម៌ តាមវិន័យរបស់ព្រះគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមជាពុទ្ធបរិស័ទ ម្យ៉ាងទៀតខ្ញុំបាទសូមអនុមោទនានូវកុសលរបស់អ្នកដែលបានបរិច្ចាគប្រាក់បោះពុម្ពសៀវភៅជំនួយសតិទាំងពីរភាគនេះនិងកុសលក្នុងការចាត់ចែងជួយគ្រប់យ៉ាងដើម្បីអោយសំរេចបាននូវការបោះពុម្ពទាន់ពេលវេលាដែលបានគ្រោងទុកជាមុន ។

សូមអោយពុទ្ធបរិស័ទទាំងអស់ បានសំរេចនូវបញ្ញាបារមីមានឧបនិស្ស័យក្រាស់ទៅដោយបញ្ញាចាក់ធ្លុះនូវធម៌ជាអមតៈ ។

ខ្ញុំព្រះករុណា ខ្ញុំបាទ **ម៉ុត សាវឌ្ឍ**

# ព្រះពុទ្ធ ២៨ ព្រះអង្គ

## នមោ មេ សព្វពុទ្ធានំ ឧប្បន្នានំ មហេសិនំ

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំចំពោះព្រះពុទ្ធជាម្ចាស់គ្រប់ព្រះអង្គដែលបានត្រាស់រួចមកហើយ ព្រះអង្គស្វែងរកគុណដ៏ធំ ( ព្រះសម្ពុទ្ធទាំងនោះគឺ )

**១~ តណ្ហង្ករោ មហាវីរោ** ~ ព្រះតណង្ករ ព្រះអង្គមានព្យាយាមធំ

**២~ មេធង្ករោ មហាយសោ** ~ ព្រះមេធង្ករ ព្រះអង្គមានយសធំ

**៣~ សរណង្ករោ លោកហិតោ** ~ ព្រះសរណង្ករ ព្រះអង្គធ្វើជាប្រយោជន៍ដល់សត្វលោក

**៤~ ទីបង្ករោ ជុតិន្ធរោ** ~ ព្រះទីបង្ករ ព្រះអង្គទ្រទ្រង់នូវបញ្ញាដ៏រុងរឿង

**៥~ កោណ្ឌញ្ញោ ជនបាមោក្ខោ** ~ ព្រះកោណ្ឌញ្ញៈ ព្រះអង្គជាប្រធាននៃពពួកជន

**៦~ មង្គលោ បុរិសាសភោ** ~ ព្រះមង្គល ព្រះអង្គជាបុរសដ៏ប្រសើរ

**៧~ សុមនោ សុមនោ ធីរោ** ~ ព្រះសុមន ព្រះអង្គជាអ្នកប្រាជ្ញមានព្រះហឫទ័យដ៏ល្អ

**៨~ រេវតោ រតិវឌ្ឍនោ** ~ ព្រះរេវត ព្រះអង្គញ៉ាំងសេចក្តីត្រេអរអោយចំរើន

**៩~ សោភិតោ គុណសម្បន្នោ** ~ ព្រះសោភិត ព្រះអង្គបរិបូណ៌ដោយព្រះគុណ

**១០~ អនោមទស្សី ជនុត្តមោ** ~ ព្រះអនោម ទស្សី ព្រះអង្គឧត្តមជាងពពួកជន

**១១~ បទុមោ លោកបជ្ជោតោ** ~ ព្រះបទុម ព្រះអង្គញ៉ាំងលោកឱ្យភ្លឺស្វាង

**១២~ នារទោ វរសារថី** ~ ព្រះនារទ ព្រះអង្គដូចសារថីដ៏ប្រសើរ

**១៣~ បទុមុត្តរោ សត្តសារោ** ~ ព្រះបទុមុត្តរ ព្រះអង្គជាខ្លឹមសារនៃពួកសត្វ

**១៤~ សុមេធោ អប្បដិបុគ្គលោ** ~ ព្រះសុមេធ ព្រះអង្គរកបុគ្គប្រៀបដូចគ្មាន

**១៥~ សុជាតោ សព្វលោកគ្គោ** ~ ព្រះសុជាត ព្រះអង្គប្រសើរលើសជាងសត្វលោកទាំងពួង

**១៦~ បិយទស្សី នរាសភោ** ~ ព្រះបិយទស្សី ព្រះអង្គប្រសើរជាងនរជន

**១៧~ អត្ថទស្សី ការុណិកោ** ~ ព្រះអត្ថទស្សី ព្រះអង្គប្រកបដោយករុណា

**១៨~ ធម្មទស្សី តមោនុទោ** ~ ព្រះធម្មទស្សី ព្រះអង្គបន្ទោបង់នូវងងឹត

**១៩~ សិទ្ធត្ថោ អសមោ លោកេ** ~ ព្រះ សិទ្ធត្ថ ព្រះអង្គឥតមានអ្នកណាស្មើក្នុងលោក

**២០~ តិស្សោ ច វទតំ វរោ** ~ ព្រះតិស្ស ព្រះអង្គប្រសើរជាងអ្នកប្រាជ្ញខាងសំដីទាំងឡាយ

**២១~ ផុស្សោ ច វរទោ ពុទ្ធោ** ~ ព្រះពុទ្ធទ្រង់ព្រះនាមផុស្ស ព្រះអង្គប្រទាននូវធម៌ដ៏ប្រសើរ

**២២~ វិបស្សី ច អនូបមោ** ~ ព្រះវិបស្សី ព្រះអង្គឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ

**២៣~ សិខី សព្វហិតោ សត្ថា** ~ ព្រះសិខី ព្រះអង្គជាគ្រូប្រៀនប្រដៅធ្វើអោយជាប្រយោជន៍ដល់សត្វទាំងពួង

**២៤~ វេស្សភូ សុខទាយកោ** ~ ព្រះវេស្សភូ ព្រះអង្គប្រទាននូវសេចក្តីសុខ

**២៥~ កកុសន្ធោ សត្ថវាហោ** ~ ព្រះកកុសន្ធ ព្រះអង្គនាំសត្វចេញចាកផ្លូវឆ្ងាយដាច់ស្រយាលគឺ កិលេស

**២៦~ កោនាគមនោ រណញ្ជហោ** ~ ព្រះកោនាគមន ព្រះអង្គបំបាត់បង់នូវសត្រូវគឺ កិលេស

**២៧~ កស្សបោ សិរិសម្បន្នោ** ~ ព្រះកស្សប ព្រះអង្គបរិបូរណដោយសិរី

**២៨~ គោតមោ សក្យបុង្គវោ** ~ ព្រះគោតម ព្រះអង្គ ប្រសើរចម្បងជាងពួកសក្យរាជ ។

# ការពិចារណា
# របស់ព្រះសុមេធបណ្ឌិត

កាលនោះ តថាគត នៅទីស្ងាត់ ក៏គិតយ៉ាងនេះថាធម្មតាភពថ្មីទៀត តែងនាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយសរីរៈ ក៏នាំមកនូវសេចក្តីទុក្ខដូចគ្នា ( សេចក្តីស្លាប់ប្រកបដោយមោហៈ នាំមកនូវទុក្ខ រូបដែលជរាញាំញីហើយក៏នាំមកនូវទុក្ខ ) អាត្មាអញមានជាតិជាធម្មតា មានជរាធម្មតា មានព្យាធិជាធម្មតា អាត្មាអញនឹងស្វែងរកព្រះនិព្វាន ដែលមិនចាស់ មិនស្លាប់ ជាទីក្សេមក្សាន្ត ។

បើដូច្នេះអាត្មាអញគួរតែលះបង់កាយស្អុយនេះដែលពេញដោយសាកសពផ្សេងៗជាអ្នកមិនអាឡោះអាល័យ មិនមានសេចក្តីត្រូវការ ហើយនឹងចេញទៅ ។

ផ្លូវនោះនឹងមានពិត ផ្លូវនោះមិនមែនជាមិនមានហេតុទេ បុគ្គលអាចទៅបាន អាត្មាអញនឹងស្វែងរកផ្លូវនោះដើម្បីដោះខ្លួនចាកភព ។

កាលបើទុក្ខមាន សុខក៏មាន យ៉ាងណាកាលបើភពមានការប្រាសចាកភព បុគ្គលគួរប្រាថ្នារកក៏យ៉ាងនោះដែរ ។

កាលបើក្តៅមាន ត្រជាក់ដទៃក៏មានយ៉ាងណា កាលបើភ្លើង ៣ ប្រការមាន ព្រះនិព្វានដែលបុគ្គលគួរប្រាថ្នាក៏មានយ៉ាងនោះដែរ ។

កាលបើបាបមាន បុណ្យក៏មាន យ៉ាងណាកាលបើជាតិមានព្រះនិព្វានមិនមានជាតិដែលបុគ្គលគប្បីប្រាថ្នាក៏មានយ៉ាងនោះដែរ ។

បុរសដែលប្រឡាក់លាមកឃើញស្រះពេញ ដោយទឹកហើយមិនស្វែងរកស្រះ ទោសនោះមិនមែនជាទោសនៃស្រះទេ យ៉ាងណាមិញ កាលបើស្រះគឺព្រះនិព្វនមានហើយ បុគ្គលមិនស្វែងរកស្រះសម្រាប់លាងនូវកិលេសជាមន្ទិលចេញទេ ទោសនោះមិនមែនជាទោសនៃស្រះគឺព្រះនិព្វានទេ គឺជាទោសរបស់បុរសក៏យ៉ាងនោះដែរ ។

បុរសដែលមានជម្ងឺកាលបើពេទ្យមាន តែមិនអោយពេទ្យនោះព្យាបាលជំងឺនោះទេ ទោសនោះមិនមែនជាទោសនៃពេទ្យទេ យ៉ាងណាបុគ្គលត្រូវជម្ងឺ គឺកិលេសទាំងឡាយបៀតបៀនហើយដល់នូវសេចក្តីទុក្ខ មិនស្វះស្វែងរកអាចារ្យទោសនោះមិនមែនជាទោសនៃអាចារ្យទេ គឺជាទោសរបស់បុគ្គលនោះឯង

យ៉ាងនោះដែរ ។ ( បើដូច្នោះ ) គួរតែអាត្មាអញលះបង់កាយស្អុយនេះដែលពេញដោយសាកសពផ្សេងៗចេញ គប្បីជាអ្នកមិនមានសេចក្ដីអាឡោះអាល័យ មិនមានសេចក្ដីត្រូវការរូបហើយចេញទៅ ។

បុរសបានស្រាយសាកសពដ៏គួរខ្ពើមរអើមដែលជាប់ឰដ៏កគប្បីជាអ្នកមានសេចក្ដីសុខទៅតាមទំនើងខ្លួន មានអំណាចខ្លួនឯងយ៉ាងណាមិញ ។

អាត្មាអញគួរតែលះបង់កាយស្អុយនេះ ដែលជាទីប្រមូលមកនូវសាកសពផ្សេងៗចេញ ហើយគប្បីជាអ្នកមិនអាលោះអាល័យមិនមានសេចក្ដីត្រូវការចេញយ៉ាងនោះដែរ ។

បុរសស្ត្រីទាំងឡាយទៅបន្ទោរបង់នូវករីសៈក្នុងបង្គន់ ហើយឥតមានអាឡោះអាល័យ ឥតមានសេចក្ដីត្រូវការ ដើរចេញទៅយ៉ាងណាមិញ ឯអាត្មាអញនឹងលះបង់នូវកាយស្អុយនេះដែលពេញដោយសាកសពផ្សេងៗចេញទៅ ដូចបុរសស្ត្រីទាំងឡាយដែលបន្ទោបង់វច្ចៈក្នុងបង្គន់ដូច្នេះឯង ។

ម្ចាស់ទូកទាំងឡាយតែងលះបង់ទូកចាស់ ដែលពុកផុយលិចចូលទឹក ឥតមានអាឡោះអាល័យ ឥតត្រូវការវិញ យ៉ាងណាមិញអាត្មាអញ និង លះបង់នូវកាយនេះ ដែលមានរន្ធ៩ហូរជានិច្ច ហើយចេញទៅដូចជាម្ចាស់ទូកលះបង់ទូកចាស់ដូច្នេះដែរ ។

បុរសកាលដើរទៅជាមួយនឹងពួកចោរយកទ្រព្យទៅផងឃើញភ័យអំពីការខូចខាតទ្រព្យ ក៏លះបង់ហើយដើរទៅយ៉ាងណា កាយនេះក៏មានឧបមាស្មើដោយមហាចោរ អាត្មាអញនឹងលះបង់កាយនេះចេញ ព្រោះខ្លាចខូចខាតកុសលធម៌យ៉ាងនោះដែរ ។ លុះតថាគតគិតឃើញយ៉ាងនេះហើយ ក៏អោយទ្រព្យជាច្រើនរយកោដិដល់ពួកជនមានទីពឹង និង ពួកជនដែលឥតទីពឹងហើយចូលទៅកាន់ព្រៃហិមពាន្ត ។ មានភ្នំមួយឈ្មោះធម្មិកនៅជិតព្រៃហិមពាន្តតថាគតធ្វើអាស្រមសាងបណ្ណសាលាក្បែរភ្នំនោះ ។

# ពុទ្ធការកធម៌បារមី ១០

កាលនោះ តថាគត កំពុងជ្រើសរើស ក៏បានឃើញ**ទានបារមី**ជា**ដំបូង** ជាគន្លងធំ ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សន្សំមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើនូវទានបារមីជាដំបូងនេះអោយមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណចូរបំពេញនូវទានបារមីចុះ ។

ក្អមដែលមានទឹកពេញ បុគ្គលណាមួយផ្កាប់ចុះ ចាក់មិនអោយសល់ទឹក ទឹកមិនដក់នៅក្នុងក្អមនោះ យ៉ាងណាអ្នកបើឃើញពួកស្មូមមកទោះថោកទាប ខ្ពង់ខ្ពស់ ឬ មធ្យម ចូរអោយទានកុំអោយសេសសល់អោយដូចជាក្អមដែលគេផ្កាប់ដូច្នេះ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណអោយសម្រេច ។ កាលនោះតថាគតកំពុងជ្រើសរើសរកក៏ឃើញបារមីទី **២** ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកឯងចូរសមាទានធ្វើសីលបារមីទី ២ នេះអោយមាំមួនបើអ្នកលុះនូវពោធិញ្ញាណចូរបំពេញនូវ**សីលបារមី**ចុះ ។ សត្វចាមរី ( កាលឃើញ ) រោមកន្ទុយចំពាក់ នឹងរបស់អ្វីមួយ ស៊ូស្លាប់ក្នុងទីនោះ មិនព្រមផ្តាច់កន្ទុយចោលឡើយ យ៉ាងណាមិញអ្នកចូរបំពេញនូវសីលទាំងឡាយក្នុងភូមិទាំង ៤ ( គឺសីល៤ ) ចូររក្សាសីលសព្វកាលអោយដូចជាសត្វចាមរីរក្សាកន្ទុយយ៉ាងនោះចុះ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញ នឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀតដែលជាធម៌ញ៉ាំងដែលជាធម៌ញ៉ាំងពោធិញ្ញាណអោយសំរេច ។ កាលនោះតថាគតកំពុងជ្រើសរើសរកក៏បានឃើញ **នេក្ខម្មបារមីទី៣** ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក (ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើនេក្ខម្មបារមីទី៣នេះអោយមាំមួនបើអ្នកចង់លុះនូវពោធិញ្ញាណចូរបំពេញនូវនេក្ខម្មបារមីចុះ ។ បុរសដែលជាប់ក្នុងគុកអស់កាលយូរត្រូវសេចក្តីទុក្ខបៀតបៀនហើយរមែងមិនញ៉ាំងសេចក្តីត្រេកអរអោយកើតឡើងក្នុងគុកនោះទេ រមែងស្វែងរកការរួច ( ចាកគុកនោះ )យ៉ាងណា អ្នកចូរឃើញនូវភពទាំងអស់ដូចជាគុកចុះ ចូរបែរមុខទៅរកនេក្ខម្មៈដើម្បីរួចចាកភពយ៉ាងនោះ

ដែរ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណអោយសំរេច ។ កាលនោះតថាគតកំពុងជ្រើសរើសរកក៏បានឃើញ **បញ្ញាបារមីទី ៤** ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើបញ្ញាបារមីទី ៤ នេះអោយមាំមួនបើអ្នកចង់ដល់នូវពោធិញ្ញាណចូរបំពេញនូវបញ្ញាបារមីចុះ ។

ភិក្ខុកាលប្រព្រឹត្តបិណ្ឌបាត មិនរំលងនូវត្រកូលទាំងឡាយទោះថោកទាប ខ្ពង់ខ្ពស់ ឬ មធ្យម រមែងបានចង្ហាន់ល្មមញ៉ាំងអត្តភាពអោយប្រព្រឹត្តទៅយ៉ាងណា អ្នកបើសាកសួរជនជាអ្នកប្រាជ្ញសព្វកាលនឹងដល់នូវបញ្ញាបារមី ហើយបានលុះនូវពោធិញ្ញាណមិនខានក៏យ៉ាងនោះដែរ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀតដែលជាធម៌ញ៉ាំងពោធិញ្ញាណអោយសំរេច ។ កាលនោះតថាគតកំពុងជ្រើសរើសរកក៏បានឃើញ **វិរិយបារមីទី ៥** ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើវិរិយបារមីទី ៥ នេះអោយមាំមួន បើអ្នកចង់លុះនូវពោធិញ្ញាណចូរបំពេញនូវវិរិយបារមីចុះ ។

សត្វសីហៈជាស្តេចនៃម្រឹគមានព្យាយាមមិនរួញរាមានចិត្តផ្គងសព្វកាលក្នុងការអង្គុយ ឈរ ដើរយ៉ាងណា អ្នកគួរផ្គងព្យាយាមអោយមាំមួនក្នុងភពទាំងពួងយ៉ាងនោះចុះ លុះដល់នូវវិរិយបារមីហើយនឹងបានសំរេចពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀត ដែលជាធម៌ញ៉ាំងពោធិញ្ញាណអោយសំរេច ។ កាលនោះ តថាគតកំពុងជ្រើសរើសរកក៏បានឃើញ **ខន្តិបារមីទី ៦** ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯង ថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើខន្តិបារមីទី ៦ នេះអោយមាំមួនអ្នកកុំមានចិត្តបែកជាពីរក្នុងខន្តិបារមីនោះនឹងបានដល់ពោធិញ្ញាណមិនខានឡើយ ។

ធម្មតាផែនដីរមែងអត់ទ្រាំចំពោះវត្ថុទាំងពួងទោះស្អាតក្តី មិនស្អាតក្តីដែលគេដាក់ចុះហើយរមែងមិនធ្វើនូវសេចក្តីថ្នាំងថ្នាក់និងសេចក្តីត្រេអរឡើយយ៉ាងណា ។

អ្នកក៏គួរអត់ទ្រាំនូវការរាប់អាននិងការមើលងាយរបស់ពួកជនទាំងពួងនោះដែរ លុះដល់នូវខន្តិបារមីហើយនឹងបានសំរេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀតដែលជាធម៌ញុំាងពោធិញ្ញាណអោយបានសំរេច ។ កាលនោះតថាគតកំពុងជ្រើសរើសរកក៏បានឃើញ **សច្ចបារមីទី ៧** ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯង ថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើសច្ចបារមីទី ៧ នេះអោយមាំមួន កុំមានពាក្យបែកជាពីរក្នុងសច្ចបារមីនោះនិងបានសំរេចសម្ពោធិញ្ញាណមិនខានឡើយ ។

ធម្មតាផ្កាយព្រឹកជាជញ្ជីងរបស់លោក ព្រមទាំងទេវលោករមែងមិនឃ្លាតចាកវិថី ក្នុងរដូវភ្លៀង ឬ ហេមន្តរដូវឡើយយ៉ាងណា ។ អ្នកកុំឃ្លាតចាកវិថី ក្នុងសច្ចៈទាំងឡាយ យ៉ាងនោះដែរ លុះដល់នូវសច្ចបារមីហើយ នឹងបានសំរេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណអោយសំរេច ។ កាលនោះតថាគត កំពុងជ្រើសរើសរកក៏បានឃើញ **អធិដ្ឋានបារមីទី ៨** ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើអធិដ្ឋាន បារមីទី ៨ នេះអោយមាំមួន អ្នកកុំញាប់ញ័រក្នុងអធិដ្ឋានបារមីនោះនឹងបានសំរេចសម្ពោធិញ្ញាណមិនខានឡើយ ។

ភ្នំថ្មឥតកំរើកតាំងស៊ប់មិនរញ្ជួយដោយខ្យល់ដ៏ខ្លាំងក្លារមែងតាំងនៅក្នុងទីរបស់ខ្លួនដដែលយ៉ាងណា អ្នកចូរកុំកំរើកក្នុងអធិដ្ឋានបារមីសព្វកាលយ៉ាងនោះដែរលុះដល់អធិដ្ឋានបារមីហើយ នឹងបានសំរេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀត ដែលជាធម៌ញុំាងពោធិញ្ញាណអោយសំរេច ។ កាលនោះតថាគត កំពុងជ្រើសរើស

រកក៏បានឃើញ **មេត្តាបារមីទី ៩** ដែលពោធិសត្វទាំងឡាយអំពីបុរាណ ធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទាន ធ្វើមេត្តាបារមីទី ៩ នេះឱ្យមាំមួន អ្នកចូរកុំឱ្យមានបុគ្គលដទៃ ស្មើដោយមេត្តា បើអ្នកចង់លុះនូវពោធិញ្ញាណ ។

ធម្មតាទឹករមែងផ្សព្វផ្សាយត្រជាក់ស្មើចំពោះជនទាំងល្អទាំងអាក្រក់ រមែងកំចាត់បង់នូវធូលីនិងមន្ទិលយ៉ាងណា ។

អ្នកចូរចំរើនមេត្តាអោយស្មើចំពោះមិត្ត និងសត្រូវយ៉ាងនោះដែរ លុះដល់នូវមេត្តាបារមីហើយនឹងបានសំរេចសម្ពោធិញ្ញាណមិនខានឡើយ ។

ពុទ្ធធម៌ទាំងឡាយមិនមែនមានត្រឹមតែប៉ុណ្ណោះទេ អាត្មាអញនឹងជ្រើសរើសរកពុទ្ធធម៌ដ៏ទៃទៀត ដែលជាធម៌ញាំងពោធិញ្ញាណអោយសំរេច ។ កាលនោះតថាគតកំពុងជ្រើសរើសរកក៏បានឃើញ **ឧបេក្ខាបារមីទី ១០** ដែលពោធិសត្វទាំងឡាយអំពីបុរាណធ្លាប់សេព ធ្លាប់អាស្រ័យមក ( ហើយទូន្មានខ្លួនឯងថា ម្នាលសុមេធបណ្ឌិត ) អ្នកចូរសមាទានធ្វើឧបេក្ខា បារមីទី ១០ នេះអោយបានមាំមួនអ្នកគួរជាបុគ្គលដូចជាជញ្ជីងដ៏មាំមួននឹងបានសំរេចពោធិញ្ញាណមិនខានឡើយ ។

ធម្មតាផែនដីតែងព្រងើយកន្តើយចំពោះវត្ថុមិនស្អាតក្តីស្អាតក្តីដែលគេដាក់ចុះហើយ តែងវៀរចាកសេចក្តីក្រោធនិងសេចក្តីត្រេអរ ចំពោះវត្ថុទាំងពីរនោះយ៉ាងណា អ្នកចូរធ្វើខ្លួនអោយដូចជាជញ្ជីងចំពោះសុខនិងទុក្ខសព្វកាលយ៉ាងនោះដែរ។ អ្នកលុះដល់នូវឧបេក្ខាបារមីហើយនឹងសំរេចសម្ពោធិញ្ញាណពុំខាន ។

ធម៌ទាំងឡាយណាជាគ្រឿងញាំងពោធិញ្ញាណអោយសំរេច ធម៌ទាំងនោះមានក្នុងលោកត្រឹមតែប៉ុណ្ណោះ ពុទ្ធការធម៌ដទៃក្រៅអំពីបារមី ១០ នោះមិនមានទេ អ្នកចូរតាំងនៅក្នុងបារមីទាំង ១០ នោះអោយមាំមួនចុះ ។ កាលតថាគតពិចារណានូវបារមីទាំងនេះដោយសភាវសរសលក្ខណៈ ( លក្ខណៈនៃសភាវៈដែលមានកិច្ចនាទី ) ផែនដីទាំងមួយម៉ឺនលោកធាតុក៏ ញាប់ញ័រដោយតេជៈនៃធម៌ ។ ផែនដីកំរើកបន្លឺឡើង ដូចជាឃ្នាបអំពៅដែលត្រូវគេគាប ឬ ចក្កយន្តប្រេងត្រូវគេគាបហើយ ( រមែងវិលញ័រ ) យ៉ាងណាផែនដីក៏ញាប់ញ័រយ៉ាងនោះដែរ ។

# ហេតុគោច្ឆកៈ

## មានហេតុ ៦ ឧុកៈ ១២ ធម្មា

### ១~ ហេតុ ធម្មា

ពួកធម៌ជាហេតុបានដល់ចេតសិក ៦ ប្រភេទ គឺ លោភៈ១ ទោសៈ១ មោហៈ១ អលោភៈ១ អទោសៈ១ បញ្ញា១ ហេតុ ទាំង ៦ នេះប្រៀបបីដូចជាឫសនៃដើមឈើ នាមរូបដែលអាស្រ័យនូវហេតុ ប្រៀបបីដូចជា ដើម មែក ស្លឹក ផ្លែ ផ្កា ។

### សតិប្បដ្ឋាន

- មានលោភៈ មួយពេលនាំមកនូវសេចក្តីទុក្ខអស់កាលជាអង្វែង ។
- លោភៈក្នុងរបស់មួយ នាំអោយមានលោភៈក្នុងរបស់ច្រើនទៀត ។
- ព្រោះតែលោភៈ ទើបចេះពេញចិត្តចំពោះកិលេសខ្លួនឯង និង កិលេសអ្នកដ៏ទៃ ។
- ការងារក្នុងលោកមិនមានទីបញ្ចប់ ក៏ព្រោះតែលោភៈពីមួយជាតិតទៅមួយជាតិ។
- មិនចេះអស់កង្វល់ព្រោះនៅមានលោភ
- សេពគប់ជាមួយលោភៈជំពាក់បំណល់កាម
- ការចំរើនកុសលជារបស់សំខាន់ មិនមែនតែតាមផ្លូវកាយ ឬតាមផ្លូវវាចាប៉ុណ្ណោះទេ សូម្បីការនឹកគិតក៏សំរេចជាកុសលផងដែរ ប៉ុន្តែការដែលនឹកគិតល្អជាបុណ្យកុសលនោះ ក៏មិនអាចមានជារហូតបានឡើយ ព្រោះយើងមានការសន្សំកិលេសមកច្រើនណាស់ហើយ ។

មួយថ្ងៃៗដែលនឹងមិនអោយអកុសលវិតក្កៈកើតរឿយៗនោះ មិនបានសោះឡើយ គឺមិនអាចហាមអកុសលវិតក្កៈ មានកាមវិតក្កៈ ឬ ព្យាបាទវិតក្កៈជាដើមបានទេ ។

សួរថាតើត្រូវលះអកុសលវិតក្កៈបានយ៉ាងណា ?

ខណៈដែលកុសលចិត្តកើតឡើងក៏លះអកុសលវិតក្កៈបានមួយគ្រា តែមិនរលត់អស់ជាសមុច្ឆេទឡើយ អកុសលវិតក្កៈជាសភាវធម៌មួយបែបដែលគួររលឹកដឹងលក្ខណៈ ក្នុងមហាសតិប្បដ្ឋានសំដែងសភាវធម៌គ្រប់យ៉ាង ជាសតិប្បដ្ឋាន កាលដឹងថាមិនមានសភាវធម៌ណាដែលមិនមែនជាសតិប្បដ្ឋានក៏ផ្តើមដឹងថា សភាវៈធម៌ទាំងឡាយនោះត្រឹមតែជារូបធម៌ នាមធម៌ប៉ុណ្ណោះ ដូច្នោះ

កាលអកុសលវិតក្កៈកើតឡើងដូចម្តេចទើបមិនរលឹកដឹងថា ត្រឹមតែជានាមធម៌មួយបែបប៉ុណ្ណោះ ?

- កាលដឹងលក្ខណៈរបស់អកុសលវិតក្កៈច្បាស់ឡើងៗ ក៏លះបង់សេចក្តីប្រកាន់នូវអកុសលវិតក្កៈថាជាតួខ្លួន កាលនៅមិនមែនជាព្រះអរហន្ត អកុសលវិតក្កៈរមែងកើតឡើងរហូតដល់អរហត្តមគ្គ ទើបអាចលះបង់ជាសមុច្ឆេទ ។

- បុគ្គលដែលមិនមានប្រក្រតីចំរើនសតិប្បដ្ឋានចេះភ័យខ្លាចរង្កៀសចំពោះអកុសលធម៌ផ្សេងៗ ប៉ុន្តែមិនរង្កៀសចំពោះការមិនដឹងនូវលក្ខណៈនៃអកុសលធម៌តាមពិតឡើយ ទើបស្វែងរកវិធីបដិបត្តិដទៃ ក្រៅអំពីសតិរលឹកដឹងនូវលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដ ។

**លក្ខណាទិចតុក្កៈ នៃ លោភៈ**

- **អារម្មណគ្គហណ លក្ខណោ** មានការប្រកាន់ក្នុងអារម្មណ៍ជាលក្ខណៈដូចស្វាជាប់ជ័រ ។

- **អភិសង្គ រសោ** មានការជាប់នៅក្នុងអារម្មណ៍ជាកិច្ច ដូចបន្ទះសាច់ស្រស់ដាក់លើគ្រឿងក្តៅ ។

- **អបរិច្ចាគបច្ចុប្បដ្ឋានោ** មានការមិនលះបង់ជាផល ដូចសំពត់ពណ៌សប្រឡាក់ជ័រចេកបោកមិនជ្រះ ឬ ដូចប្រឡាក់ថ្នាំបន្តក់ភ្នែក ។

- **សញ្ញោជនិយធម្មេសុ អស្សាទទស្សន បទដ្ឋានោ** ការឃើញដោយសេចក្តីត្រេកអរក្នុងធម៌ដែលជាអារម្មណ៍របស់សញ្ញោជនៈជា ហេតុជិត ។

- **លុព្ភតីតិ លោភោ** ឈ្មោះថាលោភៈ ដោយអត្ថថាចង់បាន ។

- លោភៈ នេះកើតជាមួយលោភៈមូលចិត្ត ៨ ដួង ។

- ទោសៈ មិនមែនកើតមកអំពីអ្នកដទៃទេ គឺកើតមកអំពីកិលេសនៃខ្លួនឯង ។

- ទោសៈ អាស្រ័យចិត្តណា ក៏មានការដុតកំឡោចនូវចិត្តនោះ ដូចជាភ្លើងអាស្រ័យអុសណា ក៏មានការដុតកំទេចអុសនោះដូច្នោះដែរ ។

- នៅពេលដឹងថា អ្នកដទៃមានអកុសលចិត្ត គួរតែមានមេត្តាព្រោះថា អកុសលមិនមែនជាប្រយោជន៍ឡើយ ។

- ត្រូវចេះអត់ឱនអោយដល់អ្នកដែលមានកំហុសខុសឆ្គាំឆ្គងព្រោះ ថាការខុសឆ្គាំឆ្គងជាធម្មតារបស់នៅអ្នកមានកិលេស ។

- មិនគប្បីជំអក់នៅក្នុងទោសៈ ព្រោះថាទោសៈមិនមែនជាមិត្ត តែគឺជាសត្រូវនៃខ្លួនឯង ។

- ចិត្តរបស់បុគ្គលណា គឺជាចិត្តរបស់បុគ្គលនោះ កាលខឹងជាមួយអ្នកដទៃមិនមែនជាចិត្តអ្នកដទៃឡើយ ហើយបើអ្នកដទៃខឹងក្រោធជាមួយយើងក៏មិនមែនចិត្តយើងដែរ ។

- វង្វៀសចំពោះកិលេសខ្លួនឯង ជំនួសការវង្វៀសចំពោះកិលេសអ្នកដទៃ ។

## លក្ខណាទិចតុក្កៈ នៃ ទោស

- **ចណ្ឌិក្កលក្ខណោ** មានការកាចជាលក្ខណៈ ដូចពស់មានពិសដែលត្រូវគេវាយ ។

- **វិសប្បនរសោ** មានការអន្ទះអន្ទែងជាកិច្ច ដូចពិសជ្រាបក្នុងកាយក្រហល់ក្រហាយអន្ទះសា ។

- **អត្តនោ និស្សយទហនរសោ** ឬ មានការដុតទីអាស្រ័យនៅរបស់ខ្លួនឯងគឺចិត្តដូចភ្លើងឆេះព្រៃជាកិច្ច ។

- **ទុស្សនបច្ចុប្បដ្ឋានោ** មានការប្រទូសរ៉ាយជាផល ដូចសត្រូវបានឱកាស ។

- **អាឃាតវត្ថុបទដ្ឋានោ** មានអាឃាតវត្ថុជាបទដ្ឋាន **ហេតុជិត ទុស្សតីតិ ទោសោ** ឈ្មោះថាទោសៈដោយអត្ថថាប្រទូសរ៉ាយ ។

- ទោសៈនេះកើតជាមួយទោសមូលចិត្ត ២ ដួង ។

- ធម៌ដែលត្រូវចំរើន គឺអរិយមគ្គអង្គ៨ ការចំរើនអរិយមគ្គអង្គ៨ គឺចំរើននៅពេលឃើញរូប ឬឮសំលេងជាដើមនេះឯង ។

- អកុសលធម៌ដែលគួរអោយវង្វៀសជាងគេនោះ គឺ អវិជ្ជាបានដល់ការមិនដឹងសេចក្តីពិតនៃសភាវធម៌ដែលកំពុងប្រាកដក្នុងជីវិតប្រចាំថ្ងៃ ។

- លោភៈ ទោសៈ ឥស្សា មច្ឆរិយ និង អកុសលធម៌ផ្សេងៗទៀត តែងកើតរួមជាមួយមោហៈ មិនដែលកើតរួមជាមួយសតិបញ្ញាឡើយ ។

- មោហៈ ធ្វើអោយមានការយល់ឃើញថា ខ្លួនឯងជាអ្នកបានអ្វីៗអំពីលោកនេះហើយត្រេកអរ មានការប្រកាន់ដោយមានះ ។

- មោហៈ វង្វេងក្នុងលក្ខណៈនៃសភាវធម៌នាំអោយប្រកាន់ថាជាខ្លួន ឬថាជារបស់ខ្លួន ការមានសតិរលឹកដឹងលក្ខណៈនៃសភាវធម៌ជាប្រក្រតី ទើបអាចលះបង់នូវមោហៈ អវិជ្ជាអោយ

អស់ទៅបាន ។

- ការមិនដឹងថា អវិជ្ជាគឺមិនដឹងបរមត្ថធម៌ក្នុងខណៈឃើញ ឬ ក្នុងខណៈឮ ឬ ក្នុងខណៈលោភៈ ទោសៈជាដើម មិនអាចមានការចំរើនអរិយមគ្គអង្គ ៨ ដើម្បីលះអវិជ្ជាបានឡើយ ។

- ការបរិភោគនូវថ្នាំពិស រមែងដល់នូវសេចក្តីទុក្ខ ឬ ស្លាប់យ៉ាងណាការកើត ចាស់ ឈឺ ស្លាប់ក្នុងវដ្តសង្សារ ព្រោះការបរិភោគនូវភព ពោលគឺសេចក្តីត្រេអរក្នុងភព ។ របស់អ្នកដទៃគឺអ្នកដទៃត្រេអរ ចំណែករបស់យើងគឺយើងត្រេអរ ដូច្នេះរបស់ដែលត្រូវប្រយ័ត្នជាទីបំផុតគឺរបស់យើង ។

- បុគ្គលល្ងង់ជាសត្រូវនឹងខ្លួនឯង ព្រោះរៀបចំសេចក្តីទុក្ខទុកសំរាប់ខ្លួនឯង ។

## លក្ខណាទិចតុក្កៈ នៃ មោហៈ

- **អញ្ញាណលក្ខណោ** មានការមិនដឹងនូវសេចក្តីពិតនៃបរមត្ថធម៌ជាលក្ខណៈ ។

- **អារម្មណសភាវច្ឆាទនរសោ** មានការបិទបាំងនូវសភាវៈនៃអារម្មណ៍នាំអោយយល់ច្រឡំផ្សេងៗជាកិច្ច ។

- **អន្ធការបច្ចុប្បដ្ឋានោ** មានសភាពងងឹតនាំអោយវង្វេងជាផល ។

- **អយោនិសោមនសិការបទដ្ឋានោ** មានការធ្វើទុកក្នុងចិត្តខុសទំនងមិនត្រូវតាមហេតុផលជាបទដ្ឋាន ។

- **អារម្មណេមុយ្ហតីតិ មោហោ អញ្ញាណំ** ឈ្មោះថា មោហៈ ដោយអត្ថថា វង្វេងក្នុងអារម្មណ៍បានដល់អញ្ញាណ ។

- មោហៈ នេះកើតក្នុងអកុសលចិត្តទាំង ១២ ដួង ។

- អលោភៈការមិនជាប់ជំពាក់មាននៅគ្រប់កុសលទាំងអស់ គឺជាមិត្តជួយអោយបានសំរេចនូវអរិយមគ្គ ។

- អលោភៈ ធ្វើសីលអោយស្អាតទាំងគ្រហស្ថ ទាំងបព្វជិត ។

- អលោភៈ ជាបរមត្ថធម៌ជាសភាវៈពិតប្រព្រឹត្តទៅក្នុងចិត្តល្អ គួរអប់រំការរលឹករឿយៗ ទាល់តែបានឃើញថា ការធ្វើល្អគ្រប់យ៉ាងពុំមែនជាតួខ្លួនយើងឡើយ ។

- មួយ គឺលោភៈមិនមែនជារបស់មានប្រយោជន៍ មួយទៀត គឺអលោភៈមានប្រយោន៍ដ៏ក្រៃលែង គួរជ្រើសយកតែអលោភៈប៉ុណ្ណោះនេះ គឺស្មារតី ។

- មិនគួរភ្ញាក់ផ្អើល ឬ ចំណូលចូលចិត្តក្នុងរបស់មិនមានសារៈ ។

- គួរមាំទាំក្នុងអលោភៈខ្លាំងឡើងៗ ។

- សេចក្តីសន្តោស គឺអលោភៈអ្នកមានសេចក្តីសន្តោសឈ្មោះថាអ្នកមានធម៌ល្អ សេចក្តីសន្តោសជាទ្រព្យដ៏ប្រសើរក្រៃលែង ។

- អលោភៈជាអ្នកមាន ជាអ្នកគ្រប់ពុំខ្វះខាតឡើយតាមផ្លូវចិត្ត ។

- លោភៈជាមេក្រ អលោភៈជាសេដ្ឋី

- ខណៈដែលកំពុងគិតនោះ តើអ្វីពិត អ្វីមិនពិត ? បរមត្ថពិតរឿងដែលគិតមិនពិត ។

- ព្រះធម៌តឿនអោយពិចារណាខ្លួនឯង ដើម្បីអោយដឹងថារហូតជីវិតនេះមិនមានតួខ្លួន មិនមានសត្វបុគ្គល មានត្រឹមតែរូបជាធាតុមិនដឹង នាមជាធាតុដឹងប៉ុណ្ណោះ ។

- ចំណីអាហារក្នុងព្រៃអត់មានម្ចាស់ក៏ពិតមែនហើយ ប៉ុន្តែមានដាក់ថ្នាំបំពុល ធ្វើអោយអ្នកស្រេចឃ្លាន មិនមានពិចារណាហើយបានបរិភោគទៅក៏ដល់នូវសេចក្តីស្លាប់ ឬ ទុក្ខវេទនាស្ទើរតែនឹងស្លាប់ យ៉ាងណាមិញសេចក្តីត្រេអរចំពោះអារម្មណ៍ក្នុងលោកភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ចិត្ត គឺ ពិតជាមិនរួចចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស និង ឧបាយាសៈឡើយ ។

- របស់ដែលត្រូវប្រយ័ត្នបំផុត គឺរបស់យើង ព្រោះរបស់យើងហ្នឹងឯងដែលសំរាប់អោយត្រេគអររាល់ថ្ងៃ គួរអប់រំសតិរលឹកបរមត្ថធម៌រឿយៗ ទើបបានឃើញពិតថា អារម្មណ៍ក្នុងលោក ៦ គឺ រូប សំលេង ក្លិន រស ផោដ្ឋព្វៈ ធម្មារម្មណ៍ ពុំមែនជារបស់គួរត្រេអរដោយលោភៈឡើយ ។

- អារម្មណ៍ គឺ អ្វីដែលចិត្តដឹងជារបស់ខាងក្រៅ គឺ ក្រៅអំពីចិត្ត អារម្មណ៍មិននៅក្នុងការហួងហែងរបស់ចិត្តឡើយ ចិត្តទាំងឡាយមិនអាចចាប់អារម្មណ៍របស់ខ្លួនបានទេ ទាំងចិត្តក៏មិនមានតួខ្លួនឯងទៀតផង ត្រូវរលត់បាត់ទៅ ពុំមានស្ថិតនៅធ្វើជាម្ចាស់នៃលោក គឺអារម្មណ៍នោះឡើយ ។

- គួរតាមសិក្សាសង្កេតនូវសភាវពិតក្នុងជីវិតប្រចាំថ្ងៃរឿយៗ ទើបអាចរំងាប់នូវតណ្ហា សេចក្តីប្រាថ្នាត្រូវការស្វែងរកសភាវៈដទៃមកជួរជំនួស ។

- មិនគួរវង្វេងរកដឹងសច្ចៈធម៌ក្រៅអំពីជីវិតប្រចាំថ្ងៃឡើយ បើរូបធម៌ នាមធម៌ក្នុងជីវិតប្រចាំថ្ងៃមិនមែនរបស់ពិត មិនមែន

ជាសច្ចៈទេនោះ តើជាអ្វីទៅវិញ ?

- ភាវេតព្វធម៌ គឺធម៌ដែលត្រូវចំរើន បានដល់ការចំរើននូវសេចក្ដីដឹងចំពោះសភាវពិតក្នុងជីវិតជាយ៉ាងសាមញ្ញាធម្មតា រហូតដល់ការប្រាកដច្បាស់នៃនាមរូប សូម្បីក្នុងពេលកំពុងនិយាយ កំពុងស្ដាប់ កំពុងបរិភោគ ។ល។

- ការបដិបត្តិសតិប្បដ្ឋានក្នុងជីវិតប្រចាំថ្ងៃជាប្រក្រតីដោយពុំមានទៅធ្វើអ្វីអោយពិសេសខុសអំពីប្រក្រតី ទើបស្គាល់អវិជ្ជាមែនទែនដែលធ្លាប់តែបិទបាំងនូវនាមរូបអស់កាលជាអង្វែងមកហើយ អវិជ្ជានេះឯងដែលនាំមកនូវការប្រកាន់ហួងហែងនាមរូបថាជាតួខ្លួន ។

## លក្ខណាទិចតុក្កៈ នៃ អលោភៈ

- **អលគ្គនាខលក្ខណោ** មានការមិនជាប់នៅក្នុងអារម្មណ៍ជាលក្ខណៈដូចតំណក់ទឹកមិនជាប់នៅសើមត្របកឈូក ។

- **អបរិគ្គហរសោ** មានការមិនប្រកាន់ហួងហែងជាកិច្ច ដូចការរួចផុតអំពីថ្នាំពិសឬរួចផុតពីអន្ទាក់ដោយសេចក្ដីថាអារម្មណ៍ក្នុងលោកគឺជាអន្ទាក់ ការមិនហួងហែងនូវអារម្មណ៍ គឺមិនជាប់អន្ទាក់ ។

- **អនល្លីនភាវបច្ចុប្បដ្ឋានោ** មានការមិនប្រកាន់មាំក្នុងអារម្មណ៍ជាផល ដូចបុគ្គលធ្លាក់ក្នុងរណ្ដៅស្មោកគ្រោក ហើយមិនត្រូវការនៅក្នុងរណ្ដៅនោះ មិនហួងហែងរណ្ដៅនោះឡើយ អារម្មណ៍ក្នុងលោកទាំង ៦ គឺ រូប សំលេង ក្លិន រស ផោដ្ឋព្វៈ និង ធម្មារម្មណ៍ប្រៀបបបីដូចជារណ្ដៅស្មោកគ្រោក ។

- **យោនិសោមនសិការបទដ្ឋានោ** ការយកចិត្តទុកដាក់ត្រូវតាមហេតុផលច្បាស់លាស់ គឺជាហេតុជិតនៃអលោភៈ ។

- មេត្តា អង្គធម៌ គឺ អទោសៈ

- មានមេត្តា ព្រោះឃើញដល់បំណងរបស់អ្នកដទៃត្រូវការសេចក្ដីសុខដូចយើងដែរ ។

- មានមេត្តា ព្រោះមិនប្រកាន់ចរិយាការប្រព្រឹត្តិរបស់អ្នកដ៏ទៃ ឃើញអកុសលរបស់អ្នកដទៃ ជាគ្រោះថ្នាក់របស់គេ វង្វៀសចំពោះកិលេសខ្លួនឯង ។

- មានមេត្តា មានការលះបង់ ។

- មានមេត្តា មានការរាប់អាន ។

- មានមេត្តា មានការអើពើ ។

- មានមេត្តា មិនមានការមើលងាយ មិនមានការឆ្មើងឆ្មៃ ។

- មេត្តា ជាម្លប់របស់ចិត្តដ៏ត្រជាក់ ។

- មេត្តា ជាគ្រឿងប្រដាប់ចិត្តដ៏ប្រសើរ ។

- មេត្តា ជាថ្នាំរបស់ចិត្តដ៏ពូកែ ។

- បានជាត្រូវមានមេត្តា ព្រោះថាសត្វទាំងឡាយគួរអោយមានមេត្តា ។

- ព្រោះចង់គ្រាន់បើ ទើបបានជាប្រកាន់ឫកឆ្មើងឆ្មៃ និយាយគំរាមកំហែងដោយសេចក្តីខឹងក្រោធ ដោយការមើលងាយ ប៉ុន្តែតាមពិតជីវិតរស់នៅជាមួយអកុសលជាជីវិតថោកទាប ដូច្នេះត្រូវចេះថែទាំរក្សានូវសេចក្តីល្អឃើញនូវសេចក្តីល្អថាជារបស់មួយល្អជាងទ្រព្យសម្បត្តិខាង ក្រៅទៅទៀត ។

- ការមិនក្រោធខឹង គឺ អទោសៈជារបស់ល្អណាស់ មានប្រយោជន៍ ការខឹងក្រោធមិនមានប្រយោជន៍ឡើយ ។

- ការមិនក្រោធខឹងជាគ្រឿងអលង្ការរបស់អ្នកប្រាជ្ញ ។

- គួរសិក្សាពិចារណានូវធម្មៈគ្រប់យ៉ាងដែលកំពុងប្រាកដក្នុងខណៈនេះដែលជាសភាវៈមួយលក្ខណៈៗ សូម្បីអទោសៈក៏ជាធម្មៈ លោភៈក៏ជាធម្មៈ ទោសៈជាធម្មៈ អលោភៈក៏ជាធម្មៈ មេត្តាក៏ជាធម្មៈ ចិត្តឃើញក៏ជាធម្មៈ ចិត្តឮ ។ល។ ចិត្តនឹកគិត សុខ ទុក្ខ ។ល។ សភាវៈគ្រប់យ៉ាងសុទ្ធតែជាធម្មៈ ធម្មៈគឺបរមតធម៌ គឺជាសភាវៈពិត ចិត្តគឺចិត្ត នាមគឺនាម រូបគឺរូប មិនទៅជាមនុស្សសត្វ បុគ្គល តួខ្លួន យើង គេឡើយ ។

- ការរំពៃប្រុងចាប់កំហុសអ្នកដទៃ ព្រោះខ្លួនឯងក្រាស់ដោយកិលេស មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ស្ងាត់ឡើយ ។

- ម្លប់នៃព្រះសទ្ធម្មជាម្លប់ស្ងាត់ជ្រងំសុខក្សេមក្សាន្តបានដល់សតិប្បដ្ឋាន ៤ ។

- មានជំរកត្រជាក់មិនជ្រក ស៊ូនៅហាលក្តៅ ព្រោះនៅធ្វើការបំរើគេ ។

- លោកនៃជីវិតពិតត្រឹមតែជាអារម្មណ៍នៃវិថីចិត្ត ប៉ុណ្ណោះ បើវិថីចិត្តតាមទ្វារ ៦ មិនមានទេ លោកធាតុនេះក៏មិនមានដោយពិតនេះ គឺជាលោកនៃជីវិតរបស់បុគ្គលម្នាក់ៗ ជីវិតមិនអាចរស់នៅក្នុងលោកបានយូរឡើយ ត្រូវរលត់បាត់ទៅព្រមទាំងលោកក៏បែកធ្លាយដែរ ដូចជាដុំពពុះទឹកអីចឹងឯង ។

- ជីវិត គឺគ្រាន់តែជាផលនៃបច្ច័យប៉ុណ្ណោះ រស់នៅក្នុងលោកផ្សេងៗគ្នា គឺលោកដែលជាអារម្មណ៍របស់ខ្លួនឯង ។

- លោកនៃជីវិតមិនមែនជាផែនដី ព្រៃ ភ្នំ មិនមែនជាផ្ទះ

សម្បែង ទីកន្លែង មិនមែនជាក្រុង ជាជនបទហើយ ក៏មិនមានមាសប្រាក់ ទ្រព្យសម្បត្តិ សម្ភារៈសព្វបែប សព្វយ៉ាងនោះឡើយ លោកពិតនៃជីវិតគឺត្រឹមតែជាអារម្មណ៍របស់វិថីចិត្តមួយខណៈយ៉ាងរហ័សនោះប៉ុណ្ណោះ ។

- ជីវិតក្នុងលោក ៦ នេះពុំដែលមានអ្វីជារបស់ខ្លួនឯងទេ ហើយដែលពិតណាស់ទៅទៀតនោះ ជីវិតពុំមានតួខ្លួនឯងឡើយ ត្រូវវិនាសទៅវិញយ៉ាងឆាប់ដូចជាផ្លេកបន្ទោរ ដូច្នោះដែរ ។

- ការតាក់តែងនូវលោកដោយអំណាចកម្ម គឺ អភិសង្ខារ ព្រោះការប្រកាន់ដោយតណ្ហាថា លោកជារបស់ខ្លួនយើង ដូចជាការតាក់តែងរូបអោយស្អាត សំលេងអោយពិរោះជាដើមនេះឈ្មោះថា សត្វលោក គឺអ្នកជាប់ជំពាក់នៅក្នុងលោក ។

- ការខុសការឆ្គាំឆ្គងនៃមនុស្សម្នាក់ៗ រមែងមានជាធម្មតា ទាំងមានចេតនា ទាំងមានការភ្លាំងភ្លាត់ដោយអត់បំណង ដើម្បីអោយខុស ដូចជាការធ្វើដំណើរតាមផ្លូវជាដើម ជួនក៏ប្រញាប់ពេកទៅ ជួនក៏ត្រូវបត់ជ្រុលជ្រួសយ៉ាងណាៗ ក៏ត្រូវទុកថា ដូចជាបងប្អូនត្រូវរៀនចេះអត់ឱន ចេះគួរសម កុំមើលមុខដោយសំឡក់សំឡឹង ពាក្យសំដីទ្រគោះបោះបោក យើងគួរតែជ្រាបថា មនុស្សម្នាក់ៗមានម៉ែ មានឪ មានក្រុមគ្រួសារ មានការគ្រប់គ្រងថែទាំគ្នា មិនប្រាថ្នាអោយបុគ្គលណាប្រមាថមើលងាយឪពុក ឬ ម្តាយ ឬ បងប្អូនរបស់ខ្លួនឡើយ ព្រោះហេតុដូច្នេះ ហើយយើងមិនត្រូវអោយអ្នកដ៏ទៃខ្មាស់គេ ឬឈឺចិត្ត ឬខាតបង់ប្រយោជន៍ដោយសារយើងឡើយ ម្យ៉ាងទៀតបើយើងបានពិនិត្យទៅលើសភាវៈពិតដែលកំពុងមានប្រាកដ ក៏វាចប់ត្រឹមរបស់ពិតហ្នឹងទៅហើយ មិនមានអ្នកណាអាចកែប្រែសភាវៈពិតដែលកំពុងប្រាកដនោះបានឡើយ ។

- ការមានតួខ្លួនយើងដោយអំណាចការប្រកាន់នាមរូប គួរអោយរង្កៀស គួរអោយខ្មាស់ណាស់ គឺវាជាកំពូលនៃការបរាជ័យក្នុងជីវិតនេះ យើងចង់ឈ្នះអ្នកដទៃមានប្រយោជន៍អ្វី ខំជេរខំស្តី សំឡក់ សំឡឹង ខ្ទន់ខ្ទាញ់ កំណាញ់ ច្រណែន អួតអាងខ្លួនទាំងអស់នេះ តើមានប្រយោជនអ្វីទៅ ? ចុះបើព្រមអត់មានតួខ្លួនយើងទៅវិញដោយជ្រកនៅក្រោមព្រះសទ្ធម្មសមំក្នុងក្តីស្ងាត់បាត់ខ្លួនពីនាមរូប មិនប្រសើរទេឬ ?

- ព្រោះតែទិដ្ឋិថាមានតួខ្លួនឯង ទើបចេះតែភ័យខ្លាចអត់ តាម

ពិតវិថីចិត្តក្នុងលោក ៦ មិនដែលចាប់នូវអារម្មណ៍របស់ខ្លួនឯងទុកបានឡើយ ហើយថែមទាំងត្រូវវិនាសនូវខ្លួនឯងនោះទៅវិញទៀតបើដូច្នោះម៉េចក៏ចាំបាច់ភ័យតក់ស្លុតខ្លាចអត់ បើវាមិនទាំងមានតួខ្លួនជាអ្នកអត់ផងនោះ ។

- កាមគុណនោះរឹតតែស៊ី រឹតតែឃ្លាន លោភៈនោះរឹតតែបានរឹតតែមិនគ្រប់ ។

- បើត្រូវការពន្លត់ភ្លើងត្រូវកុំថែមអុស ហើយដងទឹកចាក់ទៅវារលត់ហើយ យ៉ាងណាការរំលត់កិលេសក៏ដូចគ្នា មិនត្រូវចេះទៅតាមអំណាចកិលេស មិនបង្អង់នោះទេ អ្វីៗដែលកិលេសត្រូវការពុំមែនសំរាប់រំងាប់នូវកិលេសនោះឡើយ តែវាធ្វើអោយកិលេសរឹតតែធំធាត់ទៅវិញទេ កិលេសធំធាត់នាំអោយប្រព្រឹត្តនូវកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតដោយពិត ដូច្នេះការសង្រួមកាយ វាចា ចិត្ត ប្រព្រឹត្តសុចរិត គឺប្រៀបបីដូចជាការដកអុសអោយភ្លើងអន់ សតិប្បដ្ឋានមានសុចរិត ៣ ជា អាហារក៏បាននាំមកនូវព្រះនិព្វានជាអារម្មណ៍រំលត់កិលេស ដូចជាទឹករំលត់នូវភ្លើងដូច្នេះឯង ។

**លក្ខណាទិចតុក្កៈ នៃ អទោសៈ**

- **អចណ្ឌិក្កលក្ខណោ** មានការមិនកាចជាលក្ខណៈ ដូចមិត្តល្អជួយទំនុបបំរុង ។

- **អាឃាតវិនយរសោ** មានការកំចាត់អាឃាតជាកិច្ច ។

- **សោមភាវបច្ចុប្បដ្ឋានោ** មានសេចក្តីត្រជាក់ជាផលដូចព្រះច័ន្ទពេញវង់ ។

- មានយោនិសោមនសិការ ជាហេតុជិត ។

- ការមិនក្រោធជួយអោយមានបញ្ញាស្មារតី ។

- អមោហៈគឺបញ្ញា បានដល់ការដឹងច្បាស់តាមសេចក្តីពិតនៃអារម្មណ៍ មិនវង្វេងច្រឡំខុសអំពីការពិត ។

- អកុសលគ្រប់យ៉ាងមិនអាចកើតរួមជាមួយបញ្ញាបានឡើយព្រោះបញ្ញាបានដឹងសេចក្តីពិតនៃអារម្មណ៍ ។

- សេចក្តីពិតនៃអារម្មណ៍គ្រប់យ៉ាង កាលដែលបញ្ញាឃើញច្បាស់ ក៏ជាការហាមឃាត់នូវកិលេស ដោយសេចក្តីថាកិលេសពុំអាចកើតបានឡើយ ។

- អ្នកចំរើនសតិប្បដ្ឋាន រមែងមិនហួងហែងកិលេស ប៉ុន្តែមិនមែនបានសេចក្តីថា មានការបណ្តែតបណ្តោយអោយកិលេស

ចំរើនច្រើននោះទេ ព្រោះកិលេសគ្រប់យ៉ាងក៏ជាអនត្តា ពុំអាចហាមឃាត់កុំអោយកើតឡើងបានឡើយ តែថាការមានសតិរលឹកលក្ខណៈពិតនៃសភាវធម៌រឿយៗក្នុងជីវិតប្រចាំថ្ងៃ បញ្ញាដឹងច្បាស់ឡើងៗនូវអារម្មណ៍ជាបរមត្ថ ក៏ជាហាមឃាត់នូវកិលេស បិទនូវកិលេស ព្រោះកិលេសកើតតែជាមួយមោហៈគឺអវិជ្ជា មិនកើតរួមជាមួយសតិបញ្ញាឡើយ ។

- **សារម្មណាធម្មា** ពួកធម៌មានការដឹងអារម្មណ៍បានដល់ចិត្តនិងចេតសិក រាល់ពេលដឹងអារម្មណ៍សតិរលឹកដឹងបាននូវការដឹងអារម្មណ៍នោះ សង្កេត ពិនិត្យ សិក្សាក៏បានឃើញថា ការដឹងអារម្មណ៍គ្រាន់ជានាមធម៌ប៉ុណ្ណោះ ប្រព្រឹត្តទៅតាមទ្វារ មានទ្វារភ្នែកជាដើម គឺមិនមែនជាសត្វបុគ្គលក្នុងការដឹងអារម្មណ៍នោះឡើយ ។

- បើមិនអប់រំនូវបញ្ញាទេនោះ មុខតែមិនអាចជាឆ្លួតបានឡើយ ឆ្លួតព្រោះកាម ឆ្លួតព្រោះសេចក្ដីក្រោធ ឆ្លួតព្រោះមោហៈ អវិជ្ជា ឆ្លួតព្រោះមិច្ឆាទិដ្ឋិ ។ល។

- មនុស្សយើងតែងសង្ឃឹមថា នឹងបាននូវអ្វីដែលខ្លួនត្រូវការប្រាថ្នាចង់បាន ប៉ុន្តែក៏អស់សង្ឃឹមផងដែរ ព្រោះថាការបានមកនោះវាមិនធ្វើអោយគ្រប់គ្រាន់ ហើយរឹងរិតតែស្រេកឃ្លានណាស់ទៀត ព្រះបាទមន្ធាតុនៅជាព្រះរាជកុមារជាងប្រាំបីម៉ឺនឆ្នាំ ជាស្ដេចចក្រគ្រប់គ្រងលើទ្វីបទាំង ៤ ជាងប្រាំបីម៉ឺនឆ្នាំ ទ្រង់ទទួលការគ្រប់គ្រងនៅឋានទេវតាចាតុម្មហារាជិកា ហើយទទួលនូវការចែករំលែកឋានតាវត្តិង្សអំពីព្រះឥន្ទ្រ ប៉ុន្តែទ្រង់នៅតែអស់ព្រះជន្មទាំងមិនឆ្អែត ដូច្នេះមានតែសម្បត្តិបញ្ញាប៉ុណ្ណោះទេ ដែលធ្វើអោយចេះឆ្អែត ចេះគ្រប់គ្រាន់ ដកព្រួញតណ្ហាដែលជាប់នៅក្នុងចិត្ត ។

- បញ្ញត្តិជាអារម្មណ៍របស់ចិត្ត ចេតសិក តែបញ្ញត្តិមិនដឹងអារម្មណ៍ឡើយ ។

- ម៉ែ ឪ កូន ប្ដី ប្រពន្ធ ញាតិ អ្នកធំ អ្នកតូច ។ល។ ទាំងអស់នេះគឺជាបុគ្គលបញ្ញត្តិ ។

- ដឹងថានេះគឺកូនរបស់ខ្ញុំ ធាតុដឹង អាការដឹងនេះពុំមែនជាម៉ែ ឬជាឪទេ គឺជាចិត្តដែលមានបញ្ញត្តិជាអារម្មណ៍ ។

- យើងស្វាមីដឹង នេះជាបញ្ញត្តិអារម្មណ៍របស់ចិត្តក្នុងមួយខណៈនោះ ស្វាមីដឹងថានាងនេះជាប្រពន្ធខ្ញុំ ការដឹងនេះពុំមែន

ស្វាមីជាតួដឹងទេ គឺជាចិត្តខណៈមួយផ្សេងទៀត ពុំមែនជាចិត្តក្នុងខណៈដែលដឹងថា យើងជាស្វាមីនោះទេ ។

- ដោយបរមត្ថនោះបញ្ញត្តិមិនដឹងបញ្ញត្តិឡើយ មានតែវិថីចិត្តក្នុងមនោទ្វារកើតឡើងប៉ុណ្ណោះ ដែលអាចដឹងថានេះជាយើងនោះជាគេឬ ក៏អប្បមញ្ញាវិបាកបដិសន្ធិក្នុងព្រហ្មលោកក៏ គឺជានាមធម៌ដែលមានសត្វបញ្ញត្តិជាអារម្មណ៍ ។

- យើងដឹងថាអ្វីៗជារបស់យើង តាមពិតយើងដែលជាម្ចាស់ទ្រព្យសម្បត្តិនោះ មិនដឹងអ្វីទេ ចិត្តទេតើដែលដឹង ធម្មជាតិចិត្តមិនមែនជាសត្វបុគ្គលតួខ្លួនយើងឡើយ ។

- អ្នកធំមើលងាយអ្នកតូច តាមពិតអ្នកធំមិនមានជាសភាវៈអ្វីទាំងអស់ ក្នុងពេលនោះមានសតិរលឹកដឹងនូវសភាវធម៌ពិត ការប្រៀបធៀបគ្នារមែងមិនមាន គ្មានអ្នកមាន គ្មានអ្នកក្រ មានតែចិត្តគិតជាបរមត្ថ ។

- អ្នកធំ អ្នកមាន អ្នករូបស្អាត អ្នកត្រកូលខ្ពង់ខ្ពស់ទាំងអស់នេះមិនមែននាំអោយស្ងប់ចិត្តទេ បរមត្ថធម៌ពិត ទើបនាំមកនូវការស្ងប់ចិត្តដល់អ្នកដែលឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃ ។

- អ្នកតូចទាប អ្នកក្រ អ្នករូបអាក្រក់ អ្នកត្រកូលទន់ទាបទាំងអស់នេះ មិនមែននាំអោយខ្វាយខ្វល់លំបាកចង្អៀតចង្អល់ទេ អវិជ្ជា គឺការមិនដឹងបរមត្ថធម៌ពិត ប្រកាន់ស្អិតនូវនាមរូប ទើបនាំមកនូវកង្វល់ ។

## **លក្ខណាទិចតុក្កៈ នៃ បញ្ញា**

- **យថាភូតបដិវេធលក្ខណា** មានការចាក់ធ្លុះនូវធម៌ តាមសេចក្តីពិតដែលកើតឡើងយ៉ាងណា តាមហេតុតាមបច្ច័យជាលក្ខណៈ ។

- **វិសយោភាសន រសា** មានការបំភ្លឺនូវអារម្មណ៍ ហើយបានឃើញច្បាស់នូវសេចក្តីពិតជាកិច្ច ។

- **អសម្មោហបច្ចុប្បដ្ឋានា** មានការមិនវង្វេងជាផល ។

- **យោនិសោមនសិការបទដ្ឋានា** មានការធ្វើទុកក្នុងចិត្តត្រឹមត្រូវតាមហេតុផលជាហេតុជិត ។

## **២_ ន ហេតូធម្មា**

- ពួកធម៌មិនមែនជាហេតុបានដល់រូប ២៨ដួង ចេតសិក ៤៦ដួង ( វៀរហេតុ៦ ) ចិត្ត ១២១ដួង និង និព្វាន ។

- ពិភពលោកនេះគឺជាលោកនៃវិថីចិត្ត ជីវិតរស់នៅក្នុងលោកជាអារម្មណ៍របស់ខ្លួនឯង ជីវិតត្រូវរលត់បាត់ទៅវិញជាមួយ

ខណៈចិត្ត ។

- សុខ ឬ ទុក្ខពុំមែនអ្នកដទៃធ្វើដោយខ្លួនឯង ហើយក៏ពុំមែនអ្នកដទៃធ្វើអោយដែរបានន័យថាខ្លួនឯង ឬអ្នកដទៃពុំមានឡើយផស្សៈជាបច្ច័យនៃសុខ ឬ ទុក្ខ ។

- សភាវធម៌ដែលប្រាកដចំពោះសតិ ប្រៀបបីដូចជានៅពេលយប់ងងឹត ហើយមានពន្លឺផ្លេកបន្ទោរ អាចឃើញរូបបានក្នុងពេលនោះ យ៉ាងណាក្នុងខណៈមានសតិ គឺសភាវធម៌ប្រាកដច្បាស់ដោយសារពន្លឺនៃសតិ ។

- បញ្ញា កំចាត់បង់នូវភាពងងឹត គឺមោហៈ ។

- សត្វសេះអត់ស្នែងយ៉ាងណាសង្ខារធម៌ អត់ខ្លួន សត្វបុគ្គលយ៉ាងនោះឯង ។

- លោភៈជាប់ជំពាក់ចំពោះរូបប្រាថ្នាចង់បានរូប តើព្រោះហេតុអ្វី ? បើលោភៈអត់មានភ្នែកសំរាប់មើលរូបផង ។

ឆ្លើយថា សញ្ញាដែលចាំបាននូវរូបនោះជានិច្ចសញ្ញាកើតជាមួយលោភៈនាំអោយមានការត្រិះរិះជាកាមវិតក្កៈហាក់ដូចជាលោភៈមានភ្នែកបានឃើញរូបអញ្ចឹងឯង ។

- សតិរលឹកបាននូវរូបត្រឹមតែជា **ទិដ្ឋំ** គឺសំរាប់ឃើញតែប៉ុណ្ណោះ អនិច្ចសញ្ញា គឺការសំគាល់បានថាការអស់ទៅនៃចិត្តឃើញរូប ឬ ការអស់ទៅនៃរូបជារបស់ដែលមិនគួរត្រេអរឡើយ ។

- លោភៈមិនមាន ត្រចៀក ច្រមុះ អណ្តាត កាយ ប៉ុន្តែលោភៈជាប់ជំពាក់ក្នុង សំលេង ក្លិន រស ផោដ្ឋព្វៈក៏ព្រោះមិនមានបញ្ញា ឃើញការអស់ទៅនៃសំលេង ក្លិន រស ផោដ្ឋព្វៈម្ល៉ោះហើយ និច្ចសញ្ញាក៏នាំអោយមានការត្រិះរិះខុសផ្សេងៗទៅ ។

- រូបារម្មណ៍សំរាប់ត្រឹមតែឃើញប៉ុណ្ណោះ កាលណាបើមានបញ្ញាប្រគល់រូបារម្មណ៍អោយចិត្តឃើញ កិច្ចដែលត្រូវត្រេអរក្នុងរូបារម្មណ៍រមែងមិនមាន ។

- សំលេងសំរាប់ត្រឹមតែឮ ក្លិនសំរាប់ត្រឹមតែធុំក្លិន រសសំរាប់ត្រឹមតែចិត្តដឹងរស ផោដ្ឋព្វៈសំរាប់ត្រឹមតែកាយវិញ្ញាណ កាលណា ឃើញដូច្នេះពុំវង្វេងក្នុងអារម្មណ៍ឡើយ ។

- បើមិនមានការរលឹកដឹងនូវចក្ខុវិញ្ញាណទេនោះ មុខតែវង្វេងក្នុងរូបារម្មណ៍ហើយ ។

**៣- សហេតុកា ធម្មា**

ពួកធម៌មានហេតុ បានដល់សហេតុចិត្ត ៧១ដួង ចេតសិក សម្បយុត្ត ៥២ដួង ( វៀរមោហចេតសិកនៅក្នុងមោហមូលចិត្ត ២ដួង ) ។

- សហេតុកចិត្ត ប្រែថាចិត្តដែលមានហេតុ គឺចិត្តដែលមាន ហេតុ ៦ ហេតុណាមួយរួមជាមួយចិត្ត ។

**សហេតុកចិត្តមាន ៣ ពួក គឺ**

**១- ឯកហេតុកចិត្ត** បានដល់ចិត្តប្រកបជាមួយហេតុមួយ ។

**២- ទ្វិហេតុកចិត្ត** បានដល់ចិត្តប្រកបជាមួយហេតុពីរ ។

**៣- តិហេតុកចិត្ត** បានដល់ចិត្តប្រកបជាមួយហេតុបី ។

## ១- ឯកហេតុកចិត្ត

- បានដល់មោហមូលចិត្ត ២ដួង គឺ វិចិកិច្ឆាសម្បយុត្តចិត្ត ១ ដួង និង ឧទ្ធច្ចសម្បយុត្តចិត្ត ១ដួង ។

- មោហមូលចិត្តទី ១ ប្រកបដោយវិចិកិច្ឆា មានចេតសិក កើតរួម ១៥ដួង គឺ អញ្ញសមានា ១០ដួង ( វៀរ អធិមោក្ខៈ បីតិ ឆន្ទៈ ) មោចតុកៈ ៤ដួង វិចិកិច្ឆា ១ដួង ។

- នៅក្នុងចេតសិក ១៥ដួង នេះ មានតែមោហៈចេតសិក ១ ដួង ប៉ុណ្ណោះដែលជាហេតុ ដូច្នេះទើបមោហមូលចិត្តទី ១ និងចេតសិក ១៤ដួង ប្រកបជាមួយហេតុតែមួយ គឺមោហហេតុ ចំណែកមោហហេតុវិញមិនប្រកបជាមួយហេតុទេ ព្រោះមោហ មូលចិត្ត និងចេតសិក ១៤ដួង នោះមិនមែនជាហេតុ ។

- មោហមូលចិត្តទី ២ ប្រកបដោយឧទ្ធច្ចៈ មានចេតសិក ១៥ ដួងដែរ គឺ អញ្ញសមានា ១១ដួង ( វៀរបីតិ ឆន្ទៈ ) មោចតុកៈ ៤ គឺ មោហៈ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ។

- នៅក្នុងចេតសិក ១៥ដួង នេះត្រូវយល់ដូចនៅក្នុងមោហ ចិត្តទី ១ ដែរ ទើបមោហចិត្តពីរដួងនេះ ដួងមួយៗប្រកបជាមួយ ហេតុតែមួយ ។

## ២- ទ្វិហេតុកចិត្ត

- បានដល់ចិត្ត ២២ដួង គឺ លោភមូលចិត្ត ៨ដួង មានលោភ ហេតុ និង មោហហេតុកើតរួមជាមួយ ។

- ទោសមូលចិត្ត ២ដួង មានទោសហេតុ និង មោហហេតុ កើតរួមជាមួយ ។

- មហាកុសលចិត្ត ៤ដួង មហាវិបាកចិត្ត ៤ដួង មហាកិរិយា ចិត្ត ៤ដួង ដែលជាញាណវិប្បយុត្ត មានអលោភហេតុ និង អ ទោសហេតុកើតរួមជាមួយ ។

**៣. តិហេតុកចិត្ត**

បានដល់ចិត្ត ៤៧ដួង ឬ ដោយពិស្តារមាន ៧៩ដួង គឺ

- មហាកុសលចិត្ត ៤ដួង មហាវិបាកចិត្ត ៤ដួង មហាកិរិយាចិត្ត ៤ដួង ដែលជាញាណសម្បយុត្តត្រូវជា ១២ដួង ។

- មហគ្គតចិត្ត ២៧ដួង

- លោកុត្តរចិត្ត ៨ដួង ឬ ៤០ដួង តិហេតុកចិត្តនេះប្រកបដោយហេតុបី គឺ អលោភហេតុ អទោសហេតុ អមោហហេតុ ។

- សូមជ្រាបថាក្នុងសហេតុកចិត្តមួយៗ មិនមែនមានតែចេតសិកជាតួហេតុប៉ុណ្ណោះទេ ដែលកើតរួមជាមួយនោះ គឺមានចេតសិកច្រើនទៀតគ្រាន់តែមិនមែនជាហេតុដែលកើតរួមជាមួយ ។

**ចំណែកហេតុដោយន័យផ្សេងៗ**

**ន័យទី ១** គឺ អសោភណហេតុ និង សោភណហេតុ ។

- លោភៈ ទោសៈ មោហៈ ជាអសោភណហេតុដែលកើតរួមជាមួយអកុសលចិត្ត ។

- អលោភៈ អទោសៈ អមោហៈ ជាសោភណហេតុដែលកើតរួមជាមួយសោភណចិត្ត ។

**ន័យទី ២** គឺ អកុសលហេតុបានដល់ លោភៈ ទោសៈ មោហៈកើតជាមួយអកុសលចិត្ត កុសលហេតុបានដល់អលោភៈ អទោសៈ អមោហៈ កើតជាមួយកុសលចិត្ត អលោភៈ អទោសៈ អមោហៈ ជាអព្យាកតៈកើតជាមួយអព្យាកតចិត្ត ដែលជាសហេតុក ។

**ន័យទី ៣** គឺ ដោយជាតិមាន ៤ គឺ លោភៈ ទោសៈ មោហៈ ជាអកុសលជាតិ ចំណែកអលោភៈ អទោសៈ អមោហៈ ជាកុសលជាតិក៏មាន ជាវិបាកជាតិក៏មាន ជាកិរិយាក៏មាន ។

**ន័យទី ៤** គឺ ដោយភូមិមាន ៤ គឺ កាមភូមិមានហេតុ ៦ គឺលោភៈ ទោសៈ មោហៈ អលោភៈ អទោសៈ អមោហៈ ។ រូបភូមិ អរូបភូមិ លោកុត្តរភូមិ ក្នុងភូមិមួយៗមានហេតុបី គឺ អលោភៈ អទោសៈ អមោហៈ ។

**ន័យទី ៥** គឺ ដោយបុគ្គល គឺ បុថុជ្ជន ព្រះសោតាបន្ន ព្រះសកទាគាមី មានហេតុគ្រប់ទាំង ៦ ។

ចំណែកព្រះអនាគាមី មានតែហេតុ ៥ ( វៀរទោសៈ )

ចំណែកព្រះអរហន្ត មានតែហេតុ ៣ ជា អព្យាកតៈ

**សហេតុកចេតសិក**

ការសង្គ្រោះចេតសិកដោយហេតុ មាន ៥ ន័យ គឺ

**ន័យទី ១** . ចេតសិកដែលមានហេតុ ១ មាន ៣ ចេតសិកគឺ

- វិចិកិច្ឆា ប្រកបជាមួយមោហហេតុ
- លោភៈ ប្រកបជាមួយមោហហេតុ
- ទោសៈ ប្រកបជាមួយមោហហេតុ

**ន័យទី ២** . ចេតសិកដែលមានហេតុ ២ មាន ៩ ចេតសិក គឺ មោហៈ ទិដ្ឋិ មានៈ ឥស្សា មច្ឆរិយ កុក្កុច្ចៈ អលោភៈ អទោសៈ អមោហៈ សូមជ្រាបថា ចេតសិតដែលមានហេតុទាំងអស់នេះ មិនចំពោះតែក្នុងចិត្តុប្បាទមួយទេ ។

**ន័យទី ៣** . ចេតសិតដែលមានហេតុ ៣ មាន ២៧ ចេតសិក គឺ អហិរិកៈ អនោត្តប្បៈ ឧទ្ធច្ចៈ ថីនៈ មិទ្ធៈ ចេតសិក ៥ នេះប្រកបជាមួយ លោភៈ ទោសៈ និង មោហៈ ។

ចំណែកសោភណចេតសិក ២២ដួង ទៀត ( វៀរ អលោភៈ អទោសៈ បញ្ញា ) ប្រកបជាមួយសោភណហេតុ ៣ ។

**ន័យទី ៤** . ចេតសិកដែលមានហេតុ ៥ គឺ បីតិ ចេតសិក ដែលប្រកបជាមួយហេតុ ៥ ( វៀរទោសៈ ) ។

**ន័យទី៥**.ចេតសិកដែលមានហេតុ ៦ មាន១២ចេតសិក គឺ អញ្ញសមានាចេតសិក ( វៀរបីតិ ) ។

**បញ្ជាក់** . សូមជ្រាបថាចេតសិក ៥ ន័យនេះ មិនចំពោះតែ ហេតុក្នុងចិត្តុប្បាទមួយទេ ។

សរុប សហេតុកាធម្មា ដោយសហេតុកចិត្ត ៧១ ដួង

- ចិត្ត ២ ដួង មានហេតុ ១
- ចិត្ត ២២ ដួង មានហេតុ ២
- ចិត្ត ៤៧ ដួង មានហេតុ ៣ ។
- នេះចំពោះក្នុងចិត្តុប្បាទមួយៗ

ដោយសហេតុកចេតសិក ៥២ ដួង

- ចេតសិក ៣ ដួង មានហេតុ ១
- ចេតសិក ៩ ដួង មានហេតុ ២
- ចេតសិក ២៧ ដួង មានហេតុ ៣
- ចេតសិក ១ ដួង មានហេតុ ៥
- ចេតសិក ១២ ដួង មានហេតុ ៦ ។
- នេះមិនចំពោះចិត្តុប្បាទតែមួយឡើយ គឺរួមប្រភេទ ចេតសិកដែលដូចគ្នាក្នុងចិត្តុប្បាទផ្សេងៗ ។

## សតិប្បដ្ឋាន

- ធម៌ដែលត្រូវដឹងដែលត្រូវត្រាស់ដឹង គឺបរមត្ថធម៌បុគ្គល

ដែលកើតរោគបដិបត្តិធម៌ តែងចង់បានធម៌ដោយពុំដឹងថា តើអ្វីជាធម៌ដែលត្រូវដឹង ឬ ដែលត្រូវត្រាស់ដឹង ព្រោះតែមិនដឹងធម៌ ទើបចង់បានធម៌ ។

- ការចង់បានអ្វីក៏ដោយគួរតែអប់រំការរលឹកដឹងអោយឃើញច្បាស់ថា  ការចង់បានជាបរមត្ថធម៌ ពុំមែនជាសត្វ បុគ្គល តួខ្លួនយើងឡើយ ។

- ពុំអាចឃើញធម៌ពិតបានឡើយ បើអ្វីៗក៏សុទ្ធតែប្រកាន់ថាជាខ្លួន ឬ ជារបស់ខ្លួន ។

- ពួកធម៌ជាកុសល ពួកធម៌ជាអកុសល ពួកធម៌អព្យាកត ធម្មៈដោយសេចក្តីថា មិនមែនជាសត្វ ជាតួខ្លួន យើងគេឡើយ ដូច្នេះការឃើញធម៌ គឺឃើញសភាវពិតជាបរមធម៌ ដូចជាចិត្តឃើញជាធម៌ ចិត្តឮ ជាធម៌ ។ល។ ចិត្តនឹកគិតជាធម៌ សុខវេទនាទុក្ខវេទនាជាធម៌ លោភៈជាធម៌ ទោសៈជាធម៌។ល។ និង។ល។ ការឃើញធម៌ គឺឃើញសភាវពិតដែលកំពុងប្រាកដជាបរមត្ថធម៌ពុំមែនជារបស់យើង ពុំមែនជាយើង ពុំមែនជាតួខ្លួនឡើយ ។

- កាយនេះមិននៅយូរប៉ុន្មានឡើយ តែវិញ្ញាណចុងក្រោយមកដល់ហើយ ក៏ឈប់ដឹងខ្លួនថាអញ ថាជារបស់អញទៀតហើយ ដូច្នេះដឹងខ្លួនថាអញ គឺដោយសារមានវិញ្ញាណ ។

- វិញ្ញាណពុំមែនជាតួខ្លួន សត្វ បុគ្គលឡើយ ព្រោះមិនទៀងចក្ខុវិញ្ញាណមិនទៀង សោតវិញ្ញាណមិនទៀង ឃានវិញ្ញាណមិនទៀង ជីវ្ហាវិញ្ញាណមិនទៀង កាយវិញ្ញាណមិនទៀង មនោវិញ្ញាណមិនទៀង របស់ណាមិនទៀង មានការអស់ទៅ បាត់ទៅរបស់នោះត្រឹមជាផលរបស់បច្ច័យ មិនមែនជាយើង មិនមែនជាតួខ្លួនរបស់យើងឡើយ ។

- បើវិញ្ញាណមិនមែនជាតួខ្លួនរបស់យើង ហើយនោះអារម្មណ៍របស់វិញ្ញាណ ក៏សំរាប់វិញ្ញាណដឹងតែប៉ុណ្ណោះ បញ្ញាឃើញច្បាស់នូវវិញ្ញាណផង ឃើញច្បាស់នូវអារម្មណ៍របស់វិញ្ញាណផង ក៏មិនមានការប្រកាន់ថាអ្វីៗ ក្នុងលោកជារបស់យើង ជាយើង ជាខ្លួនរបស់យើងឡើយ ។

- ចក្ខុវិញ្ញាណឃើញរូបក៏ត្រឹមតែចិត្តឃើញប៉ុណ្ណោះ ឯរូបសំរាប់តែចក្ខុវិញ្ញាណឃើញប៉ុណ្ណោះដែរ ចក្ខុសម្ផ័ស្សមានចក្ខុជាបច្ច័យ សោមនស្ស ឬ ទោមនស្សដែលមានចក្ខុសម្ផ័ស្សជាបច្ច័យសោយនូវរូបារម្មណ៍ក៏ត្រូវរលត់បាត់ បញ្ញាឃើញច្បាស់នូវលោកសូន្យចាកតួខ្លួន ។

- សោតវិញ្ញាណ ឮសំលេងក៏ត្រឹមឮប៉ុណ្ណោះ ឯសំលេងក៏សំរាប់ត្រឹមតែសោតវិញ្ញាណ ឮប៉ុណ្ណោះដែរ ។

- តាមពិតនោះតើចាំបាច់ខ្លួនយើងបានដល់និព្វានដែរឬទេ ? បើក្នុងលោក ៦ នេះ មិនមានតួខ្លួនយើងផងនោះ ។

- និព្វានក៏ជាអនត្តា

សង្ខារធម៌ទាំងពួងគ្រាន់តែជាផលរបស់បច្ច័យ គឺ ជាអនត្តា បញ្ចប់រឿងរបស់ខ្លួនយើងបាន ព្រោះឃើញអនត្តា ។

- ធម្មជាតិដែលសោយនូវអារម្មណ៍ផ្សេងគ្នា ព្រោះការផ្សេងគ្នានៃផស្សៈ ផស្សៈផ្សេងគ្នាព្រោះការផ្សេងគ្នានៃធាតុ ។

- ចក្ខុធាតុជាបច្ច័យនៃចក្ខុសម្ផ័ស្ស
- សោតធាតុជាបច្ច័យនៃសោតសម្ផ័ស្ស
- ជីវ្ហាធាតុជាបច្ច័យនៃជីវ្ហាសម្ផ័ស្ស
- កាយធាតុជាបច្ច័យនៃកាយសម្ផ័ស្ស
- មនោធាតុជាបច្ច័យនៃមនោសម្ផ័ស្ស ( មនោធាតុនេះ គឺ មនោទ្វារ ) ។

- វេទនាណាមួយដែលកើតឡើង ព្រោះផស្សៈតាមសមគួរជាបច្ច័យ វេទនានោះគឺជាទុក្ខ ។

## ៤ ~ អហេតុកធម្មា

ពួកធម៌មិនមានហេតុបានដល់ អហេតុកចិត្ត ១៨ ដួង ចេតសិកសម្បយុត្ត ១២ ដួង និង មោហចេតសិក ក្នុងមោហចិត្តពីរ ព្រមទាំងរូប ២៨ ដួង និង និព្វន ។ សួរថា បើចិត្ត ១៨ ដួងនេះ មិនមានហេតុអញ្ចឹង ដូចម្តេចទើបកើតឡើងបាន ?

ឆ្លើយថា មិនមានហេតុក្នុងធម៌នេះ គឺមិនមានហេតុណាមួយក្នុងហេតុ ៦ ។

អ្វីក៏ដោយអោយតែកើតឡើង សុទ្ធតែមានបច្ច័យទាំងអស់ គឺ ( **បច្ចយហេតុ** ) ហេតុ គឺបច្ច័យ ដូចជាអហេតុកចិត្ត ១៨ ដួងនេះគ្រាន់តែមិនមាន ( ហេតុ ហេតុ ) ហេតុ គឺ ហេតុ ៦ យ៉ាងណាមួយ ប៉ុន្តែមានបច្ច័យនាំអោយកើតយ៉ាងពិតប្រាកដ ដូចជា គឺ - ទ្វិបញ្ចវិញ្ញាណចិត្ត ១០ ដួងនេះ ក្នុង ១ដួងៗ មានចេតសិក ៧ដួង គឺ ផស្សោ វេទនា សញ្ញា ចេតនា ឯកគ្គតា ជីវិតិន្ទ្រិយំ មនសិការោក្នុងចេតសិកទាំង ៧ នេះ មិនមានចេតសិកណាជាតួហេតុឡើយ ប៉ុន្តែចក្ខុវិញ្ញាណចិត្ត ២ដួង អាស្រ័យចក្ខុវត្ថុជាបច្ច័យ ដោយនិស្សយប្បច្ច័យផង អាស្រ័យរូបារម្មណ៍ជាបច្ច័យ ដោយអារម្មណប្បច្ច័យផង អាស្រ័យចេតសិកដែលប្រកបជាមួយ

ជាសម្បយុត្តប្បច្ច័យផង ចក្ខុវិញ្ញាណអកុសលវិបាក អាស្រ័យអកុសលកម្មជាបច្ច័យដោយកម្មប្បច្ច័យ ចក្ខុវិញ្ញាណជាកុសលវិបាកអាស្រ័យនូវកុសលកម្មជាកម្មប្បច្ច័យផង ហើយម្យ៉ាងទៀតចក្ខុវិញ្ញាណត្រូវអាស្រ័យចិត្តខណៈមួយមុនរលត់ទៅជាបច្ច័យយ៉ាងជិតទៀតផង ។

- ចក្ខុវិញ្ញាណធ្វើទស្សនកិច្ច គឺកិច្ចឃើញរូបារម្មណ៍ បុគ្គលណាមានការអប់រំចំរើនបញ្ញា មិនប្រកាន់ចក្ខុវិញ្ញាណថាជាខ្លួនជារបស់ខ្លួន បុគ្គលនោះរមែងមិនវង្វេងក្នុងរូបារម្មណ៍ឡើយ ។

- ដើម្បីយល់ច្បាស់អំពីអហេតុកចិត្ត យើងត្រូវរៀនចេតសិកដែលប្រកបជាមួយគ្រប់ចិត្តទាំងអស់ រួចហើយត្រូវចេតសិកណាមួយជាតួហេតុ ចេតសិកណាមិនមែនជាតួហេតុ ដូច្នេះទើបយើងដឹងថាចិត្តណាអត់មានហេតុហៅថាអហេតុកចិត្ត ចិត្តណាមានហេតុហៅថាសហេតុកចិត្ត មានហេតុ ១ ឬ ២ ឬ ក៏ហេតុ ៣ ។

## សតិប្បដ្ឋាន

- ព្រោះចក្ខុសម្ផ័ស្សជាបច្ច័យ វេទនា សញ្ញា សង្ខារ វិញ្ញាណកើតឡើងមានរូបជាអារម្មណ៍ សត្វក្នុងលោកភ្នែកមិនមានទេ

- ព្រោះសោតសម្ផ័ស្សជាបច្ច័យ វេទនា សញ្ញា សង្ខារ វិញ្ញាណកើតឡើងមានរូបជាអារម្មណ៍ សត្វក្នុងលោកត្រចៀកមិនមានទេ ។

- ព្រោះឃានសម្ផ័ស្សជាបច្ច័យ វេទនា សញ្ញា សង្ខារ វិញ្ញាណកើតឡើងមានក្លិនជាអារម្មណ៍ សត្វក្នុងលោកច្រមុះមិនមានទេ ។

- ព្រោះជីវ្ហាសម្ផ័ស្សជាបច្ច័យ វេទនា សញ្ញា សង្ខារ វិញ្ញាណកើតឡើងមានរសជាអារម្មណ៍ សត្វក្នុងអណ្តាតមិនមានទេ ។

- ព្រោះកាយសម្ផ័ស្សជាបច្ច័យ វេទនា សញ្ញា សង្ខារ វិញ្ញាណកើតឡើងផោដ្ឋព្វៈជាអារម្មណ៍ សត្វក្នុងលោកកាយមិនមានទេ ។

- ព្រោះមនោសម្ផ័ស្សជាបច្ច័យ វេទនា សញ្ញា សង្ខារ វិញ្ញាណកើតឡើងមានធម៌ផ្សេងៗជាអារម្មណ៍ សត្វក្នុងលោកចិត្តមិនមានទេ ។

- ម្នាលមារអ្នកឃើញនូវអ្វីថា ជាសត្វក្នុងគំនរនៃសង្ខារធម៌ ។

- ព្រោះខ្សែតំណនៃខន្ធ ធាតុ អាយតនៈទើបហៅថាសង្ខារ ។

- ព្រោះគំនរនៃខន្ធ ធាតុ អាយតនៈ ទើបហៅថាសង្សារ

សាគរ ។

- ព្រោះការប្រជុំរួមនៃខន្ធទើបហៅថា សត្វ ។

- នៅពេលដែលនឹកគិតឬដឹងថារបស់នេះ របស់នោះគឺគ្រាន់តែជាមនោវិញ្ញាណប៉ុណ្ណោះ មានសតិរលឹក មានបញ្ញា ក៏មិនប្រកាន់ថាខ្លួនយើង ឬថាជាសត្វបុគ្គលអ្វីឡើយ ។

- ការចេញចាកអំពីលោកនេះ គឺត្រូវពឹងលើបញ្ញារបស់ខ្លួនឯងទាំងស្រុងដោយការដឹងច្បាស់នូវលោកថាសូន្យ គឺសូន្យចាកខ្លួន ឬ ចាកវត្ថុជារបស់ខ្លួន ។

- ព្រោះហេតុជាប់ជំពាក់នឹងការឆ្ងាញ់ ទើបបានជាភ្លេចដល់សេចក្ដីទុក្ខក្នុងការស្រេចឃ្លាន ។

- ព្រោះហេតុតែជាប់ជំពាក់នឹងការសប្បាយក្នុងកាមគុណ ទើបបានជាភ្លេចដល់ទារុណកម្មមួយដែលខ្លួនបានទទួល គឺការស្រេកឃ្លានតាមផ្លូវចិត្ត ។

- បើមិនដឹងខ្លួនថាមានរោគអ្វីផងនោះ ធ្វើម៉េចនឹងព្រមលេបថ្នាំព្យាបាលទៅយ៉ាងណាមិញ បើមិនដឹងថា ការស្រេកឃ្លានតាមផ្លូវចិត្តវាជាជំងឺទេនោះ ធ្វើម៉េចនឹងព្រមលបថ្នាំ គឺការបដិបត្តិធម៌ ថែមទាំងមិនរវល់តមចំណីទាស់ទៀតផង ។

- អ្វីជាចំណីទាស់ ? វត្ថុកាម ៥ មុខ គឺ រូប សំលេង ក្លិន រស ផោដ្ឋព្វៈដែលជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាទីស្រឡាញ់ ជាទីតាំងនៃតំរេក ។

- វាពិតជាលំបាកតមមែនទែន ចំពោះចំណីណាដែលចង់បរិភោគ ហើយដែលលំបាកទ្រាំខ្លាំងណាស់ទៅទៀតនោះ គឺចង់ខ្លាំងឃ្លានខ្លាំង ។

- សត្វឆ្មាដែលកំពុងតែឃ្លាន រួចស្រាប់តែបានសាច់អាំងមួយដុំពាំក្នុងមាត់នោះ វាពិតជាមិនព្រមលែងដោយងាយៗនោះទេ កុំស្មានថា គ្រាន់តែធ្វើសំលេងស៊្វិចៗ ឬ ស្រែកថាឆ្មាៗ ហើយវាព្រមលះបង់ចោលនូវដុំសាច់នោះអោយសោះ ក្រែងតែវំពាត់វាយអោយធ្ងន់ដៃឯណោះ ទើបវាព្រមលែងចោល ។

- នឹកស្មានថាបានឆ្អែតទើបខំបរិភោគ ដឹងអីវាធ្វើអោយឃ្លានផងស្រេកផងលើសដើម ។

- ការអប់រំចំរើនបញ្ញា ប្រព្រឹត្តទៅដើម្បីឃើញច្បាស់នូវលោកក្នុងអរិយវិន័យ វត្ថុអ្វីៗ ផែនដី ភូមិ ស្រុក ប្រទេស មនុស្សសត្វ ព្រៃ ភ្នំ ទន្លេ សមុទ្រ សុទ្ធតែសន្និតទាំងអស់ របស់ទាំងអស់នេះមិនផុតចាកអំពីរូបារម្មណ៍ សទ្ទារម្មណ៍ គន្ធារម្មណ៍ រសា

រម្មណ៍ ផោដ្ឋព្វារម្មណ៍ និងធម្មារម្មណ៍ឡើយ អារម្មណ៍ ទាំង ៦ នេះ ទើបជាលោកពិត គឺជាលោកដែលមានសភាវៈមានការកើតប្រាកដជាអារម្មណ៍នៃវិញ្ញាណ ។

- ជីវិតដែលរស់នៅក្នុងលោក គឺជីវិតរបស់វិញ្ញាណ រស់នៅក្នុងលោកដែលជាអារម្មណ៍របស់ខ្លួនឯង តាមបរមត្ថពិតជីវិតក្តីវិញ្ញាណក្តីពុំមែនជាសត្វ ជាបុគ្គល ជាយើងឡើយ គ្រាន់តែជាវិថីចិត្តប្រព្រឹត្តទៅតាមទ្វារ ៦ កើតរលត់បន្តគ្នា ។

- ការបដិបត្តិគឺសិក្សា សង្កេតរលឹកដឹងចំពោះសភាវធម៌ដែលកំពុងប្រាកដ បញ្ញាឃើញច្បាស់នូវលោកសូន្យចាកសត្វ មានតែវិថីចិត្តដឹងអារម្មណ៍ហើយ ឃើញការអស់ទៅនៃលោក ឃើញការអស់ទៅវិញនៃវិថីចិត្ត ជីវិតពិតជាអនត្តាតែជាទុក្ខ ។

## សុត្តនិបាត

## ទ្វយតានុបស្សនាសូត្រ

- ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់សំដែងថា រូបសំលេងរស ផោដ្ឋព្វៈ ធម្មារម្មណ៍ទាំងអស់ជាទីប្រាថ្នា ជាទីស្រឡាញ់និងជាទីពេញចិត្តលោកពាលថាមាននៅដរាបណា អារម្មណ៍ទាំងនោះសត្វលោក ព្រមទាំងទេវលោកសន្មតថា ជាសុខដរាបនោះ អារម្មណ៍ទាំងនោះតែងរលត់ទៅក្នុងព្រះនិព្វានណា ព្រះនិព្វាននោះ ពួកសត្វលោកទាំងនោះសន្មតថាជាទុក្ខវិញ ។ ការរលត់នូវសក្កាយ គឺឧបាទានក្ខន្ធទាំង ៥ ព្រះអរិយៈទាំងឡាយឃើញថាជាសុខពិត ការឃើញរបស់ព្រះអរិយៈ អ្នកយល់នេះជាទំនាស់នឹងសត្វលោកទាំងពួង ។

ពួកជនពាលដ៏ទៃ ពោលនូវវត្ថុកាមណាថាជាសុខ ព្រះអរិយៈទាំងឡាយពោលនូវវត្ថុកាមថាជាទុក្ខពួកជនពាលដទៃពោលនូវព្រះនិព្វានណាថាជាទុក្ខ ព្រះអរិយៈទាំងឡាយដឹងច្បាស់នូវព្រះនិព្វាននោះថាជាសុខ អ្នកចូរឃើញនូវនិព្វានធម៌ដែលដឹងបានដោយក្រ ពួកអ្នកមិនដឹងវង្វេងហើយក្នុងធម៌នោះ ។

សេចក្តីងងឹតធ្វើនូវភាពខ្វាក់តែងប្រាកដដល់ពួកជនពាលដែលអវិជ្ជាបាំង មិនឃើញនូវព្រះនិព្វាន ឯព្រះនិព្វានដូចជាពន្លឺ រមែងបើកបង្ហាញដល់សប្បុរស អ្នកឃើញ ពួកជនអ្នកមិនឈ្លាសវៃនូវធម៌គឺព្រះនិព្វានរមែងមិនដឹងច្បាស់នូវព្រះនិព្វានសូម្បីមានក្នុងទីជិតឡើយ ។

ព្រះនិព្វាននេះពួកជនពាលដែលមានភវរាគៈគ្របសង្កត់ ហើយកំពុងអន្ទោលទៅតាមខ្សែក្នុងភព កើតហើយក្នុងកន្លែង

របស់មារមិនងាយនឹងត្រាស់ដឹងបានឡើយ ។

នរណាហ្ន៎ វៀរលែងតែព្រះអរិយៈចេញ គួរនឹងត្រាស់ដឹងនូវព្រះនិព្វានបាន ព្រះអរហន្តទាំងឡាយ មិនមានអាសវធម៌បរិនិព្វានហើយ ព្រោះបានត្រាស់ដឹងដោយប្រពៃនូវព្រះនិព្វាន ។

- ពាក្យថា ព្រះនិព្វានមាននៅក្នុងទីជិត **សន្តិកេ** បរមត្ថ ជោតិកាអត្ថថាប្រាប់ថាព្រោះត្រឹមរលត់ខន្ធនៃខ្លួនឯង ។

សេចក្តីល្អិតល្អន់ផ្សេងៗនៃអហេតុកចិត្ត

- អហេតុកចិត្ត១៨ជាវិញ្ញាណក្ខន្ធ ជាមនាយតនៈ
- អហេតុកចិត្ត ១៨ ជាវិញ្ញាណធាតុ ៧ គឺ
- ចិត្ត ២ ជាចក្ខុវិញ្ញាណធាតុ
- ចិត្ត ២ ជាសោតវិញ្ញាណធាតុ
- ចិត្ត ២ ជាឃានវិញ្ញាណធាតុ
- ចិត្ត ២ ជាជីវ្ហាវិញ្ញាណធាតុ
- ចិត្ត ២ ជាកាយវិញ្ញាណធាតុ
- ចិត្ត ៣ ជាមនោធាតុ
- ចិត្ត ៥ ជាមនោវិញ្ញាណធាតុ ។
- អហេតុកចិត្ត ១៨ ជាទុក្ខសច្ចៈជាមនិន្ទ្រីយ៍ ។
- អហេតុកចិត្ត ១៨ មាន ២ ជាតិ គឺ
- ចិត្ត ១៥ ជាវិបាកជាតិ
- ចិត្ត ៣ ជាកិរិយាជាតិ ។
- អហេតុកចិត្ត ១៨ ជាភូមិកាម កើតក្នុងភពផ្សេងៗ គឺ
- ចិត្ត ៦ ដួងកើតក្នុងកាមភព ១១ ។
- ចិត្ត ១០ ដួង កើតក្នុងភព ២៦ ជាន់ គឺកាមភព ១១ រូបភព ១៥ ដួង ។
- ចិត្ត ១ ដួងកើតក្នុងភព ៣០ ។
- ហសិតុប្បាទចិត្តកើតក្នុងភព ២២ ជាន់គឺកាមសុគតិភព ៧ និង រូបភព ១៥ ។

- **អហេតុកចិត្ត ១៨ ប្រកបដោយវេទនា ៤ ប្រភេទគឺ**
- ចិត្ត ១ ដួងប្រកបដោយសុខវេទនា
- ចិត្ត ១ ដួងប្រកបដោយទុក្ខវេទនា
- ចិត្ត ២ ដួងប្រកបដោយសោមនស្ស
- ចិត្ត ១៤ ដួងប្រកបដោយឧបេក្ខា ។

- អហេតុកចិត្ត ១៨ ជានហេតុ គឺមិនមែនជាតួហេតុ ជាវិប្បយុត្ត គឺប្រាសចាកអកុសលចេតសិក និងប្រាសចាកសោភណចេតសិក ។

- អហេតុកចេតសិក ១៨ ប្រកបជាមួយចេតសិក ១២ គឺ

- ចិត្ត ១០ មួយដួងៗ មានចេតសិក ៧

- ចិត្ត ៥ មួយដួងៗ មានចេតសិក ១០

- ចិត្ត ២ មួយដួងៗ មានចេតសិក ១១

- ហសិតុប្បាទចិត្ត ១ ដួងមានចេតសិក ១២ ។

- អហេតុកចិត្ត ១៨ ធ្វើកិច្ចបានទាំង ១៤ កិច្ចគឺ

- ចិត្ត ២ដួង ក្នុងដួងមួយៗមានកិច្ច ៥ គឺ បដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច សន្តីរណកិច្ច និង តទាលម្ពណកិច្ច ។

- ចិត្ត ១ដួង ធ្វើកិច្ច ២ គឺ អាវជ្ជនកិច្ច និង វោដ្ឋវនកិច្ច ។

- ចិត្ត ១ដួង ធ្វើកិច្ច ២ គឺសន្តីរណកិច្ច និង តទាលម្ពណកិច្ច

- ចិត្ត ១ដួង ធ្វើអាវជ្ជនកិច្ច

- ចិត្ត ២ដួង ធ្វើទស្សនកិច្ច

- ចិត្ត ២ដួង ធ្វើសវនកិច្ច

- ចិត្ត ២ដួង ធ្វើឃាយនកិច្ច

- ចិត្ត ២ដួង ធ្វើសាយនកិច្ច

- ចិត្ត ២ដួង ធ្វើផុស្សនកិច្ច

- ចិត្ត ២ដួង ធ្វើសម្បដិច្ឆន្នកិច្ច

- ហសិតុប្បាទចិត្តធ្វើជវនកិច្ច

- **អហេតុកចិត្ត ១៨ កើតតាមទ្វារដូចតទៅ**

- ចក្ខុវិញ្ញាណ ២ កើតតាមចក្ខុទ្វារ

- សោតវិញ្ញាណ២ កើតតាមសោតទ្វារ

- ឃានវិញ្ញាណ ២ កើតតាមឃានទ្វារ

- ជិវ្ហាវិញ្ញាណ ២ កើតតាមជិវ្ហាទ្វារ

- កាយវិញ្ញាណ ២ កើតតាមកាយទ្វារ

- មនោធាតុ ៣ កើតតាមបញ្ចទ្វារ

- អហេតុកកិរិយាមនោវិញ្ញាណ ២ និង អហេតុកវិបាកមនោវិញ្ញាណប្រកបដោយសោមនស្សវេទនាចិត្ត ៣ដួង នេះកើតតាមទ្វារ ៦ ។

- អហេតុកវិបាកមនោវិញ្ញាណប្រកបដោយឧបេក្ខាវេទនា ២ដួង កើតតាមទ្វារ ៦ ក៏មាន ក្រៅអំពីទ្វារ ៦ ក៏មាន ។

- អហេតុកចិត្ត ១៨ ដឹងអារម្មណ៍ដូចតទៅ

- ចក្ខុវិញ្ញាណ ២ មានរូបបច្ចុប្បន្នជាអារម្មណ៍
- សោតវិញ្ញាណ ២ មានសំលេងបច្ចុប្បន្នជាអារម្មណ៍
- ឃានវិញ្ញាណ ២ មានក្លិនបច្ចុប្បន្នជាអារម្មណ៍
- ជីវ្ហាវិញ្ញាណ ២ មានរសបច្ចុប្បន្នជាអារម្មណ៍
- កាយវិញ្ញាណ ២ មានផោដ្ឋព្វៈបច្ចុប្បន្នជា អារម្មណ៍
- មនោធាតុ ៣ មានអារម្មណ៍តាមបញ្ចទ្វារជាបច្ចុប្បន្ន ។

- អហេតុវិបាកមនោវិញ្ញាណទាំង ៣ដួង និង អហេតុកកិរិយាមនោវិញ្ញាណប្រកបដោយសោមនស្សវេទនា ( ហសិតុប្បាទ ) ចិត្ត ៤ដួង នេះមានអារម្មណ៍ជាកាមាវចរគ្រប់កាលទាំង ៣ ។

- អហេតុកកិរិយាមនោវិញ្ញាណប្រកបដោយឧបេក្ខាវេទនា មានអារម្មណ៍ទាំងអស់ផង គ្រប់កាលទាំង ៣ ផង ។

- ចិត្ត ១៣ មានរូបធម៌ជាអារម្មណ៍
- ចិត្ត ៤ មានទាំងរូបធម៌ មានទាំងនាមធម៌ជាអារម្មណ៍
- ចិត្ត ១ មានរូបធម៌ នាមធម៌ បញ្ញត្តិ និព្វានជាអារម្មណ៍ ។
- ចិត្ត ១៧ មានកាមាវចរជាអារម្មណ៍
- ចិត្ត ១ មានកាមាវចរ មហគ្គត លោកុត្តរ បញ្ញតិជាអារម្មណ៍ ។

- អហេតុកចិត្ត ១៨ អាស្រ័យវត្ថុរូបដូចតទៅ
- ចក្ខុវិញ្ញាណ ២ អាស្រ័យចក្ខុវត្ថុ
- សោតវិញ្ញាណ ២ អាស្រ័យសោតវត្ថុ
- ឃានវិញ្ញាណ ២ អាស្រ័យឃានវត្ថុ
- ជីវ្ហាវិញ្ញាណ ២ អាស្រ័យជីវ្ហាវត្ថុ
- កាយវិញ្ញាណ ២ អាស្រ័យកាយវត្ថុ
- ចិត្ត ៧ ដួង ដទៃអាស្រ័យហទយវត្ថុ

- អហេតុកកិរិយាមនោវិញ្ញាណប្រកបដោយឧបេក្ខាវេទនា បើនៅក្នុងបញ្ចវោការភពគឺភពដែលមានខន្ធ ៥ អាស្រ័យហទយវត្ថុ បើក្នុងអរូបព្រហ្ម មិនអាស្រ័យនូវហទយវត្ថុឡើយ ។

- ពាក្យថាវត្ថុមាន វចនត្ថថា **វសន្តិ ចិត្ត ចេតសិកា ឯត្ថាតិ វត្ថុ** ចិត្ត និង ចេតសិកទាំងឡាយ រមែងនៅអាស្រ័យក្នុងធម្មជាតិនេះ ព្រោះហេតុនោះ ធម្មជាតិនេះទើបឈ្មោះថា វត្ថុគឺធម្មជាតិជាទីអាស្រ័យកើតឡើងនៃចិត្ត ចេតសិក ( វសធាតុ វត្ថុបច្ច័យ ) ។

- វត្ថុកាលបើសំដែងដោយវោហារ ប្រៀបដូចជាផែនដី

អាស្រ័យកើតឡើងនៃដើមឈើទាំងឡាយ ឬថាជាទីតាំង ជាទីអាស្រ័យនៃរបស់គ្រប់យ៉ាងមានភ្នំជាដើមយ៉ាងណា វត្ថុរូបក៏ជាទីអាស្រ័យកើតឡើងនៃចិត្តនិងចេតសិកទាំងឡាយក៏យ៉ាងនោះដែរ ។

## សេចក្តីអធិប្បាយនៃអហេតុកចិត្ត ១៨

- អកុសលវិបាកអហេតុកចិត្ត ៧ អកុសលវិបាកចិត្ត ជាចិត្តដែលកើតឡើងព្រោះអកុសលកម្មអំពីអតីតៈជាបច្ច័យ ទើបត្រូវជាផលនៃកម្ម ។

ពិតណាស់ អកុសលដែលមិនមានកំលាំងដល់ថ្នាក់ប្រព្រឹត្តកន្លងនូវកុសលកម្មបថផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្តក៏មានអកុសលចិត្តដែលមានកំលាំងខ្លាំងក្លារហូតដល់ប្រព្រឹត្តនូវអកុសលកម្មបថផ្លូវកាយ វាចា ចិត្តក៏មាន ។

អកុសលកម្មទាំងអស់នេះ រលត់ទៅហើយ រមែងជាបច្ច័យអោយអកុសលវិបាកចិត្តកើតឡើង អកុសលកម្មដែលជាបច្ច័យអោយអកុសលវិបាកចិត្តនោះ ទោះជាអកុសលកម្មក្នុងជាតិនេះក្តី ក្នុងអតីតជាតិក្តី អនាគតជាតិកន្លងទៅហើយក្តី រមែងជាបច្ច័យអោយកើតអកុសលវិបាកចិត្តបានទាំងអស់ ប៉ុន្តែបើអកុសលកម្មគ្រប់អង្គជាបច្ច័យអោយកើតទាំងក្នុងបដិសន្ធិកាលទាំងក្នុងបវត្តិកាល បើមិនគ្រប់អង្គទេ ជាបច្ច័យអោយកើតអកុសលវិបាកចិត្តក្នុងបវត្តិកាលទាំងក្នុងអបាយភូមិ ៤ មនុស្សទេវតា ព្រហ្ម តាមសមគួរដល់បច្ច័យ តែបើបដិសន្ធិកាលក្នុងអបាយភូមិ ៤ តែម្យ៉ាង ។

**១~ ចក្ខុវិញ្ញាណ** ជាអហេតុកចិត្តកើតព្រមជាមួយឧបេក្ខាវេទនាកើតឡើងទទួលផលរបស់បាបកម្មដែលធ្វើទុកហើយ ចក្ខុវិញ្ញាណនេះកើតរាល់ដងក្នុងសង្សារវដ្ត រមែងឃើញត្រឹមតែពណ៌ប៉ុណ្ណោះ គឺមិនឃើញសត្វ បុគ្គល ឬវត្ថុអ្វីទេ ពណ៌នេះគឺ វណ្ណរូប ជាអនិដ្ឋារម្មណ៍ ។

- ចក្ខុបសាទ ជាឧបាទាយរូបអាស្រ័យមហាភូតរូបកើតឡើងព្រោះកម្មអតីតៈជាបច្ច័យ ចក្ខុខ្មែរយើងហៅថាភ្នែក ដោយបរមត្ថសំដៅដល់ចក្ខុបសាទរូប ពាក្យថាបសាទរូបគឺសេចក្តីថ្លារបស់មហាភូតរូបតែមិនមែនជាមហាភូតរូបឡើយ ហើយគួរដល់ការប៉ះខ្ទប់ និងរូប គឺ វណ្ណរូប ឬ រូបារម្មណ៍ ។

ក្នុងអដ្ឋកថា **សម្មោហវិនោទនី** សំដែងថា ចក្ខុមកអំពីចក្ខតិ ដោយសេចក្តីថាសំដែង ទើបពោលថា **ចក្ខតិ រូបំវិភាវេតីតិ**

**ចក្ខុ** ប្រែថា ធម្មជាតិឈ្មោះថាចក្ខុ ព្រោះអត្ថថាប្រាប់គឺសំដែងរូបអោយជាក់ច្បាស់ ។

ក្នុងដីកា **វិភាវិនី** សំដែងប្រាប់អំពីចក្ខុវិញ្ញាណថា **ចក្ខុស្មឹំ វិញ្ញាណំ តន្និស្សិតត្តាតិ ចក្ខុវិញ្ញាណំ** ប្រែថាវិញ្ញាណក្នុងចក្ខុ ព្រោះអាស្រ័យចក្ខុនោះ ហេតុនោះទើបឈ្មោះថា ចក្ខុវិញ្ញាណ ។

បើអកុសលកម្មអោយផល ក៏អោយធ្វើចក្ខុវិញ្ញាណឃើញរូបារម្មណ៍ដែលមិនល្អ បើកុសលកម្មអោយផលក៏ឃើញរូបារម្មណ៍ដែលល្អ ការឃើញរូបដែលល្អ ឬមិនល្អនោះមិននូវក្នុងអំណាច និងមិនប្រព្រឹត្តទៅតាមសេចក្តីត្រូវនៃបុគ្គលណាស្រេចហើយតែកម្មឯណាមានឱកាសអោយផល ព្រោះចក្ខុវិញ្ញាណនោះជាវិបាកចិត្តដែលកើតឡើងទទួលផលផ្លូវភ្នែកដោយអាស្រ័យចក្ខុបសាទឃើញពណ៌ជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍ ។

ចក្ខុវិញ្ញាណឃើញពណ៌ គឺវណ្ណរូបដែលមិនល្អ មិនគួរប្រាថ្នានោះជាផលរបស់អកុសលកម្ម បើសេចក្តីពិតយ៉ាងនេះពុទ្ធបរិស័ទគួរយល់ដឹងថាការអប់រំសតិបញ្ញាមិនត្រូវរំលងជីវិតយ៉ាងធម្មតានេះឡើយ ព្រោះជីវិតពុំមែនដទៃអំពីការពិត ជីវិតយ៉ាងធម្មតានេះឯង ដែលកើត ចាស់ ឈឺ ស្លាប់ និង មានសុទ្ធតែសភាវពិតដទៃៗទៀត ដែលមានសំដែងនៅក្នុងមហាសតិប្បដ្ឋានសូត្រ ទីណាដែលមានការកើត ចាស់ ឈឺ ស្លាប់ ទីនោះតែងមានឧបាទានក្ខន្ធជានិច្ច ជីវិតធម្មតាអាចបង្ហាញការពិតបានគ្រប់សភាវធម៌ក្នុងជីវិតប្រចាំកើតឡើងសុទ្ធតែមានបច្ច័យមិនមានខ្លួនយើង ឬអ្នកដ៏ទៃជាអ្នកធ្វើអោយកើតឡើងនោះឡើយ ដោយសេចក្តីថាសត្វក្នុងសង្ខារ គឺពុំមានយ៉ាងពិតប្រាកដ ។

ការដែលដឹងថាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍នោះមិនមែនជាកិច្ចនាទីរបស់ចក្ខុវិញ្ញាណទេ ព្រោះចក្ខុវិញ្ញាណធ្វើទស្សនកិច្ចតែម៉្យាង ចក្ខុវិញ្ញាណមាននាទីទទួលផលវិបាករបស់កម្មដោយត្រឹមតែឃើញនូវរូបារម្មណ៍ហើយក៏កន្លងទៅ គឺរលត់មិនបានតាំងនៅដោយបរមត្ថសត្វ អ្នកទទួលផលកម្មពុំមានសោះឡើយ ទ្រព្យសម្បត្តិមិនមែនជាអារម្មណ៍របស់វិបាកចិត្តទេ ទ្រព្យសម្បត្តិគ្រាន់តែការនឹកគិតប្រឌិតឡើងតែប៉ុណ្ណោះ វិបាករបស់កម្មក្នុងកាមភពនេះ ពុំមានដឹងទ្រព្យសម្បត្តិអ្វីឡើយ ។

អភិធម្មត្ថវិភាវិនីដីកា ពោលថាឧបាទាយរូបមានចក្ខុបសាទជាដើមប៉ះខ្ទប់ជាមួយឧបាយរូបមានពណ៌ជាដើម មានកំលាំងខ្សោយ ប្រៀបដូចសំឡីហើយប៉ះសំឡី ព្រោះដូច្នោះចក្ខុវិញ្ញាណជាដើម ទើបកើតព្រមជាមួយឧបេក្ខាវេទនា ។

**២. សោតវិញ្ញាណ** អកុសលវិបាកកើតឡើងដើម្បីទទួលផលរបស់អកុសលកម្ម គឺឮសំលេងមិនល្អ ។

សោតបសាទរូបជាវត្ថុ គឺជាទីអាស្រ័យនៃសោតវិញ្ញាណ កើតតាមទ្វារត្រចៀក ធ្វើសវនកិច្ចប្រកបជាមួយឧបេក្ខាវេទនា ព្រោះឧបាទាយរូបប៉ះខ្ទប់គ្នា ។

បច្ច័យដែលនាំអោយកើតនូវសោតវិញ្ញាណ មានច្រើនយ៉ាងណាស់ គ្រាន់តែសោតវិញ្ញាណកើតឡើងមិនមានហេតុ ៦ ណាមួយប្រកបជាមួយ ទើបហៅថាអហេតុកចិត្ត ។

សោតវិញ្ញាណជាបរមត្ថ ពុំមែនជាសត្វ ជាទីតាំងនៃសតិរលឹករឿយៗនៅពេលដែលចិត្តឮកំពុងប្រាកដ ។

សភាវធម៌តាមទ្វារទាំង ៦ ត្រូវបានអវិជ្ជាបិទបាំងអស់កាលជាយូរអង្វែងមកហើយ ប្រៀបបីដូចជាវត្ថុបុរាណដ៏យូរលង់ត្រូវកប់ក្នុងទីងងឹតរហូត បើបុគ្គលណារកនូវវត្ថុបុរាណនោះឃើញនឹងត្រូវបានគ្រប់គ្រងលើត្រៃភព គឺឈប់ធ្វើជាអ្នកក្រកំសត់រហូតយ៉ាងណា បើបុគ្គលទ្រោលប្រទីប គឺបញ្ញាឆ្លុះរកឃើញនូវសភាវធម៌ពិត គឺត្រឹមតែជាវិថីចិត្តតាមទ្វារទាំង៦ទេនោះ ក៏បានទៅជាម្ចាស់គ្រប់គ្រងលើតណ្ហា ឈប់បំរើតណ្ហា ឈប់តាក់តែងអភិសង្ខារ គឺកម្មដើម្បីអោយបានរូប សំលេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ទៀតហើយ ម្ចាស់លើតណ្ហា គឺព្រះខីណាស្រព ។

**៣. ឃានវិញ្ញាណ** អកុសលវិបាកកើតឡើងទទួលផលកម្មដែលបានធ្វើទុកហើយ ដឹងក្លិនជាអនិដ្ឋារម្មណ៍កើតនៅកន្លែងឃានបសាទរូបប្រកបជាមួយឧបេក្ខាវេទនា តាមឃានទ្វាធ្វើឃាយនកិច្ចជាបរមត្ថ ពុំមែនជាសត្វ បុគ្គល តួខ្លួនឡើយ ។

**៤. ជីវ្ហាវិញ្ញាណ** អកុសលវិបាកកើតឡើងទទួលផលនៃអកុសលកម្ម ដឹងរសជាអនិដ្ឋារម្មណ៍ប្រកបជាមួយឧបេក្ខាវេទនាតាមជីវ្ហាទ្វារធ្វើសាយនកិច្ច អាស្រ័យជីវ្ហាបសាតជាវត្ថុរូបជីវ្ហាវិញ្ញាណពុំមែនជាសត្វ ។

- ឃ្លានបាយ ស្រេកទឹក គឺធម្មតា តែស្រេកឃ្លានដោយតណ្ហាជាការឆ្កួត ឆ្ងាញ់នុយបិទនឹងផ្លែសន្ទូចជាចំណីមច្ឆត្រូវរងទុក្ខធំ ។

បើជីវ្ហាវិញ្ញាណដឹងរសជាអនិដ្ឋារម្មណ៍ក៏ស្រេចតែជីវ្ហាវិញ្ញាណ

ទៅចុះ ព្រោះគ្រប់រូប សំលេង ក្លិន រស ផោដ្ឋព្វៈដែលសត្វលោកចូលចិត្តត្រេអរនោះគឺជានុយសន្ទូចរបស់មារទេ ។

**៥. កាយវិញ្ញាណ** អកុសលវិបាកប្រកបជាមួយទុក្ខវេទនាតាមកាយទ្វារធ្វើផុស្សនកិច្ចដឹងផោដ្ឋព្វៈមិនល្អ ។

ដោយបរមត្ថ គឺ កាយបសាទជារូបសំរាប់ប៉ះខ្ទប់ នឹងធាតុទាំងបីវៀរអាបោធាតុ ដោយសារធាតុទាំងបីជាមហាភូតរូបប៉ះខ្ទប់នឹងកាយបសាទជាឧបាទាយរូបនោះ ប្រៀបដូចញញួរទៅវាយសំឡី ព្រោះហេតុដូចនេះ ទើបកាយវិញ្ញាណមិនប្រកបជាមួយឧបេក្ខាវេទនាឡើយ ។

**៦. មនោធាតុ** ជាអកុសលវិបាកអាស្រ័យ ហទយវត្ថុរូបធ្វើសម្បដិច្ឆន្នកិច្ចតាមបញ្ចទ្វារ មានអារម្មណ៍ជាបច្ចុប្បន្នតាមទ្វារទាំង ៥ ។

សម្បដិច្ឆន្នៈ ប្រែថាទទួលគឺអារម្មណ៍តអំពីបញ្ចវិញ្ញាណមានចក្ខុវិញ្ញាណជាដើម ប្រកបដោយឧបេក្ខាវេទនាជានិច្ច ។

មនោធាតុ គឺធាតុដឹង ដែលឈ្មោះថាធាតុ ព្រោះអត្ថថាសូន្យ គឺសូន្យចាកសត្វ បុគ្គលជាដើម និងម្យ៉ាងទៀតចិត្តនេះទ្រទ្រង់នូវលក្ខណៈរបស់ខ្លួនជាវិបាកមនោធាតុដោយមិនបានអាស្រ័យបសាទរូប ៥ ទើបមិនមែនជាបញ្ចវិញ្ញាណ ហើយព្រោះមិនដឹងធម្មារម្មណ៍ផ្សេងៗ ទើបមិនហៅថា មនោវិញ្ញាណ ។

**៧. មនោវិញ្ញាណ** ជាអកុសលវិបាក អាស្រ័យហទយវត្ថុធ្វើសន្តីរណកិច្ច តាមបញ្ចទ្វារ បន្ទាប់អំពីសម្បដិច្ឆន្នៈ

- សន្តីរណៈ ប្រែថាពិចារណា ។
- ធ្វើតទាលម្ពណកិច្ចតាមទ្វារ ៦ បន្ទាប់អំពីជវនៈ សោយអារម្មណ៍ហើយ តទាលម្ពណកិច្ចជាកិច្ចចុងក្រោយនៃវិថីចិត្តតាមទ្វារ ៦ ។

តទាលម្ពណៈ ប្រែថាអារម្មណ៍នោះ គឺកម្មជាបច្ច័យអោយវិបាកកើតឡើងកាន់យកឬតោងយកនូវអារម្មណ៍ដែលជវនសោយហើយនោះឯង ។

- ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច ចុតិកិច្ច ក្នុងអបាយភូមិ ៤ ណាមួយ ដោយមិនអាចហាមឃាត់បានជាដាច់ខាត កាលណាដែលអកុសលកម្មអោយផលក្នុងបដិសន្ធកាល ។

## កុសលវិបាកអហេតុកចិត្ត ៨

**១. ចក្ខុវិញ្ញាណ** កុសលវិបាក

**២. សោតវិញ្ញាណ** កុសលវិបាក

**៣. ឃានវិញ្ញាណ** កុសលវិបាក

**៤. ជីវ្ហាវិញ្ញាណ** កុសលវិបាក

- វិញ្ញាណធាតុ ៤ នេះប្រកបឧបេក្ខាវេទនាតាមទ្វារផ្សេងៗគ្នា អាស្រ័យវត្ថុក៏ផ្សេងគ្នា ដឹងអារម្មណ៍ក៏ផ្សេងគ្នា ។

**៥. កាយវិញ្ញាណ** កុសលវិបាកប្រកបជាមួយសុខវេទនាតាមទ្វារកាយ អាស្រ័យកាយវត្ថុទើបកើតឡើង មិនមែនសត្វ ។

**៦. មនោធាតុ** កុសលវិបាកធ្វើសម្បដិច្ឆកិច្ច គឺកិច្ចទទួលអារម្មណ៍បន្តអំពីបញ្ចវិញ្ញាណ តាមបញ្ចទ្វារ ។

**៧. មនោវិញ្ញាណ** កុសលវិបាកធ្វើសន្តីរណកិច្ច តាមបញ្ចទ្វារប្រកបជាមួយសោមនស្សវេទនា ព្រោះអារម្មណ៍ជាអតិឥដ្ឋារម្មណ៍ដ៏ល្អក្រៃលែង អារម្មណ៍នេះនៅស្រុកមនុស្សមានតិចជាងស្រុកទេវតាកើតអំពីកុសលកម្មក្រៃលែងដែរ មនោវិញ្ញាណនេះធ្វើតទាលម្ពលកិច្ចតាមទ្វារ ៦ ទៀតផង ជាវិបាកដែលកើតអំពីបុណ្យល្អប្រណីត ។

**៨. មនោវិញ្ញាណ** កុសលវិបាកប្រកបដោយឧបេក្ខាវេទនា ធ្វើសន្តីរណកិច្ចតាមបញ្ចទ្វារ និងតទាលម្ពណកិច្ចតាមទ្វារ ៦ ដោយអារម្មណ៍ជាឥដ្ឋាអារម្មណ៍ គឺល្អធម្មតាដោយច្រើននៅស្រុកមនុស្ស ។

- ធ្វើបដិសន្ធិកិច្ច ភវង្គកិច្ច និង ចុតិកិច្ច ក្នុងកំណើតមនុស្សដែលខ្វះបុណ្យ និងកំណើតទេវតាថ្នាក់ក្រោមៗដែលខ្វះបុណ្យដែរមានភាពពិការតាំងពីកំណើត ដូចជា ខ្វាក់ ថ្លង់ គ ខ្វិន ជាដើម ។

- កុសលវិបាកអហេតុកៈ គឺជាវិបាកកើតឡើងទទួលនូវផលរបស់មហាកុសលកម្ម មានអារម្មណ៍ល្អជាធម្មតានិងល្អក្រៃលែង ធ្វើកិច្ចហើយក៏រលត់អស់ទៅវិញ ។

### អហេតុកកិរិយាចិត្ត ៣

**១. កិរិយាមនោធាតុ** ជាកិរិយាព្រោះសំរាប់គ្រាន់តែផ្លាស់វិបាកធ្វើភវង្គកិច្ចអោយមកជាវិបាកក្នុងទ្វារ ៥ ។

- ភវង្គៈ គឺជាកិច្ចក្រៅទ្វារ ៦ មានការរក្សាកំណើតដែលកម្មជាបច្ច័យអោយបដិសន្ធិហើយ មិនអោយទៅជាកំណើតដទៃរហូតដល់ចុតិចិត្ត ។

- កិរិយាមនោធាតុធ្វើអាវជ្ជនកិច្ច គឺនឹករពឹងរកអារម្មណ៍តាមទ្វារទាំង ៥ បើមិនមានចិត្តមួយនេះទេ មិនអាចមានវិថីចិត្ត តាមទ្វារភ្នែក ទ្វារត្រចៀក ទ្វារច្រមុះ ទ្វារអណ្តាត ទ្វារកាយបាន

ឡើយ ។

- យើងគួរតែអប់រំរឿយៗនូវបញ្ញា ស្មារតី ដោយសេចក្តីមិនប្រមាទ កាយដែលប្រកបដោយមហាភូតរូប ៤ នេះសូន្យចាកសត្វ គ្រាន់តែជាធាតុសុទ្ធៗដូចដី ទឹក ភ្លើង ខ្យល់ ខាងក្រៅអញ្ចឹងដែរ សាកសពដែលគេចោលក្នុងព្រៃខ្មោច មិនបានដឹងខ្លួនថាអញយ៉ាងណា កាយនៃមនុស្សយើងដែលនៅរស់នេះក៏មិនបានដឹងខ្លួនថាអញយ៉ាងនោះដែរ ព្រោះរូបកាយជាធាតុមិនដឹងដោយសេចក្តីថាធាតុដីមិនមែនជាសត្វ ធាតុទឹកមិនមែនជាសត្វ ធាតុភ្លើងមិនមែនជាសត្វ ធាតុខ្យល់មិនមែនជាសត្វ ។

- ព្រោះអាស្រ័យមហាភូតរូប ៤ ទើបមានវត្ថុរូប ៦ គឺ ចក្ខុវត្ថុ សោតវត្ថុ ឃានវត្ថុ ជិវ្ហាវត្ថុ កាយវត្ថុ និង ហទយវត្ថុ ។ វត្ថុរូបទាំង ៦ ណាមួយក៏ដោយ គឺពុំមែនជាសត្វឡើយ គ្រាន់តែជាផលកើតឡើងអំពីកម្មតែប៉ុណ្ណោះ ។

- មនុស្សយើងកាលបើបានស្តាប់ឮអំពីការធ្វើកម្មល្អ ឬអាក្រក់តែងគិតយល់ថាតួខ្លួនជាអ្នកធ្វើ ដូចជាកម្មដែលបានធ្វើកន្លងទៅហើយជាដើម ប៉ុន្តែកាលបើបានចាក់ធ្លុះក្នុងសង្ខារជាបច្ចុប្បន្នដោយបញ្ញាដ៏ប្រពៃ គឺពុំបានប្រកាន់ថា មានសត្វក្នុងបច្ចុប្បន្ននេះទេនោះ ក៏មិនប្រកាន់ថាខ្លួនបានធ្វើកម្មនៅក្នុងអតីតកាលដែរ ហើយត្រូវបានឃើញច្បាស់ថា កម្មជាបច្ច័យនៃផលវិបាករបស់កម្ម ។

- ព្រោះអាស្រ័យនូវវត្ថុរូបប៉ះខ្ទប់គ្នាជាមួយអារម្មណ៍ខាងក្រៅទើបវិញ្ញាណកើតឡើងជាវិថីចិត្ត មានអាវជ្ជនកិច្ចមុនកិច្ចដទៃទៀតទាំងអស់ វិថីចិត្តជារបស់មិនទៀងតែងបាត់ទៅវិញ អស់ទៅវិញជាធម្មតា ។

- កាលបើវត្ថុរូបក៏មិនមែនជាសត្វ អារម្មណ៍ក៏មិនមែនជាសត្វ វិញ្ញាណកើតឡើងអំពីការប៉ះវត្ថុ និងអារម្មណ៍នោះក៏មិនមែនជាសត្វដែរ ។

## ២- អហេតុកកិរិយាដួងទី ២ គឺ

**មនោវិញ្ញាណធាតុ** ប្រកបដោយឧបេក្ខាវេទនា ធ្វើអាវជ្ជនកិច្ចនៅមនោទ្វារ និង វោដ្ឋវនកិច្ចនៅក្នុងបញ្ចទ្វារជាគ្រឿងទ្រនៃជវន ។

- កាលបើបញ្ញាពិចារណាឃើញច្បាស់នូវកាយគ្រាន់តែជាធាតុប្រាសចាកនាមធម៌ទាំងពួង ក៏មិនបានឃើញមានម្ចាស់ចិត្ត ឬក៏ម្ចាស់ជីវិតឡើយ វិញ្ញាណដែលអាស្រ័យវត្ថុរូបកើតឡើង បញ្ញា

ឃើញច្បាស់មិនបានប្រកាន់ថា វិញ្ញាណជាសត្វ ហើយក៏មិនបានត្រេអរចំពោះអារម្មណ៍នៃចិត្តដែរ ។

- សត្វលោកជាទាសភាពនៃការសោយអារម្មណ៍របស់ខ្លួនឯង ។

- សត្វលោកលើកដំកើងនូវបញ្ចក្ខន្ធដែលជាសត្រូវរបស់ខ្លួនឯង ដែលជាអ្នកសម្លាប់ខ្លួនឯង ។

- សត្វលោកនៅក្នុងមហាសមុទ្រធំដែលមានកិលេសជារលកទឹក មានកិលេសជាត្រីកាច សមុទ្រធំ គឺភ្នែក គឺរូបារម្មណ៍ គឺអាយតនៈទាំងអស់ ។

**៣ - អហេតុកិរិយាដួងទី ៣ គឺ**

**មនោវិញ្ញាណធាតុ** ដែលប្រកបដោយសោមនស្សវេទនា គឺជាចិត្តដែលនាំអោយព្រះអរហន្តញញឹមប្រព្រឹត្តទៅជាជវនកិច្ចតគ្នា ៧ ខណៈតាមទ្វារទាំង ៦ ទ្វារណាមួយក៏បាន យើងតែងហៅថាហសិតុប្បាទចិត្ត គឺ

- ហសិតៈប្រែថា ញញឹម
- ឧប្បាទៈប្រែថា ការកើតឡើង
- ចិត្តំ គឺជាចិត្តដឹងអារម្មណ៍ ។

ហសិតុប្បាទចិត្តនេះជាចិត្តរបស់ព្រះអរហន្តកើតព្រមជាមួយសោមនស្សវេទនា ជាចិត្តដែលធ្វើរូបអោយញញឹម ដូចជារឿងនៃព្រះមហាមោគ្គល្លានឃើញប្រេតដែលកំពុងបានទទួលទុក្ខវេទនា ការឃើញនោះ គឺឃើញដោយអភិញ្ញាកិរិយាចិត្ត ដែលប្រព្រឹត្តទៅព្រមជាមួយការពិចារណាថា សភាពដូចនេះនឹងមិនកើតដល់អាត្មាអញទៀតតទៅ រួចហសិតុប្បាទចិត្តនេះក៏កើតឡើង ។

- មានចិត្តប្រកបដោយសោមនស្ស ១២ ដួង ទៀត នាំអោយញញឹម ឬ សើច គឺ លោភចិត្ត ៤ ដួង មហាកុសលចិត្ត ៤ ដួង មហាកិរិយាចិត្ត ៤ ដួង ។

- បុថុជ្ជនសើច ឬ ញញឹមដោយចិត្ត ៨ ដួង គឺលោភចិត្ត ៤ ដួង និង មហាកុសលចិត្ត ៤ ដួង ព្រះសេក្ខបុគ្គលសើច ឬ ញញឹមដោយចិត្ត ៦ ដួងគឺវៀរលោភមូលចិត្តដែលប្រកបដោយទិដ្ឋិ ២ ដួងចេញ ចំណែកកិរិយាចិត្ត ៥ ដួង សំរាប់ព្រះអរហន្តញញឹម ។

- ដោយបរមត្ថត្រឹមតែចិត្តប្រកបដោយសោមនស្សវេទនាប៉ុណ្ណោះជាសមុដ្ឋាននាំអោយមានរូបសើច ឬ ញញឹម សត្វទាំង

ឡាយជាអ្នកសើច ឬយំពុំមានឡើយ ។

### ៥. ហេតុសម្បយុត្តា ធម្មា

ពួកធម៌ប្រកបជាមួយហេតុបានដល់ សហេតុកចិត្ត ៧១ ចេតសិកសម្បយុត្ត ៥២ វៀរមោហចេតសិកក្នុងមោហចិត្ត ។

- ពួកចិត្តនិងចេសិតដែលប្រកបជាមួយហេតុ គឺកើតជាមួយហេតុណាមួយក្នុងហេតុ ៦ រលត់ជាមួយហេតុ អាស្រ័យវត្ថុរូបជាមួយហេតុមានអារម្មណ៍ជាមួយហេតុ ។
- ពួកធម៌ដែលក្រុបជាមួយហេតុពុំមែនជាសត្វបុគ្គលឡើយ គឺជានាមក្ខន្ធ ៤ តែប៉ុណ្ណោះឯង ។

### ៦. ហេតុវិប្បយុត្តា ធម្មា

ពួកធម៌ប្រាស់ចាកហេតុ បានដល់អហេតុកចិត្ត ១៨ដួង ចេតសិកសម្បយុត្ត ១២ ដួង និងមោហចេតសិកក្នុងមោហចិត្ត ២ រូប ២៨ ដួង និព្វាន ។

- រូបធម៌មិនត្រឹមតែប្រាស់ចាកហេតុប៉ុណ្ណោះទេ គឺប្រាសចាកគ្រប់នាមធម៌ដែលជាចិត្ត និងចេតសិកទាំងអស់ ព្រោះរូបជាធាតុមិនទូវដឹងអារម្មណ៍ ។
- រូបជាទីអាស្រ័យនៃនាម នាមជាទីអាស្រ័យនៃរូប នាមរូបសូន្យចាកតួខ្លួនឯង ។
- បុគ្គលណាឃើញនាមរូបសូន្យចាកខ្លួនឯង បុគ្គលនោះរមែងបានដឹងច្បាស់ថាអវិជ្ជាជាបច្ច័យនៃអភិសង្ខារ គឺកម្មដោយមិនប្រកាន់ថា សត្វ បុគ្គល ជាអ្នកធ្វើកម្មឡើយ ។
- បញ្ញាឃើញនាមរូបមិនមែនសត្វ តែនៅមិនទាន់ឃើញនាមរូបសូន្យចាកខ្លួនឯង ព្រោះមិនឃើញនាមរូបអាស្រ័យគ្នា និងគ្នាការដែលមិនឃើញនាមរូបសូន្យចាកខ្លួនឯង គឺអវិជ្ជា ។ ការហួងហែង ការតាក់តែងនូវបុណ្យ និងបាបកើតព្រោះ អវិជ្ជាជាបច្ច័យ ។ អភិសង្ខារ គឺកម្មមិនមាន ព្រោះឃើញនាមរូបសូន្យចាកខ្លួនឯង ។

### ៧. ហេតូ ចេវ ធម្មា សហេតុកា ច

ពួកធម៌ជាហេតុ និងមានហេតុបានដល់ចេតសិតជាតួហេតុ ៦ វៀរមោហហេតុក្នុងមោហចិត្ត ។

- ក្នុងចិត្តុប្បាទណាដែលមានតួ ២ ឬ ៣ ហេតុនោះជាសហេតុកៈ គឺមានហេតុ ។
- រាល់ពេលនៃលោភហេតុកើតឡើងតែងប្រកបជាមួយមោហហេតុជានិច្ច ព្រោះវង្វេងក្នុងអារម្មណ៍ទើបជាប់ជំពាក់

រាល់ពេលដែលមានលោភៈសុទ្ធតែជាពេលឆោតល្ងង់ទាំងអស់។

- នៅពេលក្រោធខឹងជាមួយអ្នកដទៃ មិនមែនមកអំពីអ្នកដ៏ទៃធ្វើអោយខឹងនោះទេតែ គឺមកអំពីកិលេសរបស់ខ្លួនឯងដែលសន្សំអស់កាលជាយូរអង្វែងហើយ ទោសហេតុក៏មានមោហហេតុប្រកបជាមួយជានិច្ចផងដែរ រាល់ពេលមានទោសៈមិនដែលត្រូវទៅតាមសេចក្តីនៃអារម្មណ៍នោះឡើយ ព្រោះអារម្មណ៍នោះ បើបញ្ញាកើតឡើងបានដឹងតាមពិតបញ្ញារមែងនាំមកនូវអលោភៈ និងអទោសៈប្រកបជាមួយជានិច្ចពុំដែលខាន ។

## ៨. សហេតុកា ចេវ ធម្មា ន ច ហេតូ

ពួកធម៌មានហេតុតែមិនមែនជាតួហេតុ បានដល់ សហេតុកចិត្ត ៧១ ដួង ព្រមទាំងចេតសិក ៤៦ ដួង ដោយវៀរហេតុ ៦ ។

- ធម៌ទាំងឡាយគ្រាន់តែជាផលរបស់ហេតុ កើតឡើងបានអាស្រ័យហេតុ ត្រូវរលត់ទៅវិញដោយមិនទៅតាំងនៅក្នុងទីណាដូចជាផ្លេកបន្ទោរឰដ៍អាកាស ។

- ហេតុដែលនាំអោយកើតផល គឺជាបរមត្ថធម៌សច្ចៈ មិនមែនខ្លួនឯង ឬអ្នកដទៃណាឡើយ អ្វីដែលកើតឡើងអំពីហេតុរកខ្លួនឯងពុំមាន ។

## ៩. ហេតូ ចេវ ធម្មា ហេតុសម្បយុត្តា ច

ធម៌ទាំងឡាយជាតួហេតុ និង សម្បយុត្តដោយហេតុ បានដល់ចេតសិកជាតួហេតុ៦ វៀរតែមោហចេតសិកក្នុងមោហចិត្ត ២ ។

- មោហចេតសិកនៅក្នុងមោហមូលចិត្ត ២ដួង ជាតួហេតុពិតតែមិនប្រកបជាមួយលោភហេតុ ឬ ទោសហេតុឡើយ ។

- កាលដែលប្រាថ្នាចង់បានអ្វីៗដើម្បីអោយខ្លួនឯង ជាអ្នកបាននោះ ក៏គួរតែស្វែងរកខ្លួនឯងសិន កាលបើស្វែងរកហើយ គឺមិនខុសអំពីស្វែងរកស្នែងសេះ ឬស្នែងទន្សាយឡើយ ។

## ១០. ហេតុសម្បយុត្តា ចេវ ធម្មា ន ច ហេតូ

ធម៌ទាំងឡាយសម្បយុត្តដោយហេតុ តែមិនមែនជាតួហេតុបានដល់សហេតុកចិត្ត ៧១ដួង និងចេតសិកសម្បយុត្ត ៤៦ដួង ។

- សត្វលោករមែងស្វែងរកការសប្បាយរីករាយ ដែលការសប្បាយរីករាយនោះចាំបាច់ត្រូវតែមានចិត្តដឹងនូវអារម្មណ៍ សេចក្តីសប្បាយរីករាយត្រូវអស់ទៅព្រមគ្នាជាមួយគ្នានឹងចិត្តរលត់ សេចក្តីសប្បាយរីករាយមានត្រឹមតែមួយភ្លែតៗ ធ្វើអោយសត្វលោកលំបាកក្នុងការស្វែងរក ។

- ព្រះនិព្វានសុខដ៏ក្រៃលែងដោយមិនចាំមានវិញ្ញាណដឹងនូវ

អារម្មណ៍ មិនចាំបាច់មានវេទនាសោយនូវអារម្មណ៍ សុខនេះមិនប្រែប្រួល ។

- បុគ្គលណាពិចារណាឃើញច្បាស់ដោយបញ្ញាថា ការសោយអារម្មណ៍ជាសុខនោះ គឺជាទុក្ខ ព្រោះប្រែប្រួលតាមវិញ្ញាណ ទើបឃើញព្រះនិព្វានដែលជាបរមត្ថសុខ ព្រោះផុតចាកខន្ធ ៥ ជាឯកន្តសុខគឺសុខក្នុង ចំណែកតែឯងដោយមិនជាប់ទាក់ទិនជាមួយបញ្ចក្ខន្ធ ។

**១១. នហេតូ ខោ បន ធម្មា សហេតុកាបិ**

ពួកធម៌មិនមែនជាតួហេតុ ប៉ុន្តែមានហេតុប្រកបជាមួយបានដល់សហេតុកចិត្ត ៧១ដួង និង ចេតសិកសម្បយុត្ត ៤១ដួង ។

**១២. នហេតូ ខោ បន ធម្មា អហេតុកាបិ**

ពួកធម៌មិនមែនជាតួហេតុ និងមិនមានហេតុប្រកបជាមួយបានដល់ អហេតុកចិត្ត ១៨ដួង ចេតសិកសម្បយុត្ត ១២ដួង រូប ២៨ដួងព្រមទាំងនិព្វាន ។

## មកដល់អ្នកមានទុក្ខគ្រប់គ្នា

( ស្រង់ចាកអត្ថបទរបស់ម៉ែសុចិន្ត )

ឧបេក្ខាវេទនាគឺសេចក្តីដឹងខ្លួនមិនសុខមិនទុក្ខកើតឡើងហើយក៏រលត់ទៅ មិនទៀង សេចក្តីដឹងខ្លួនដទៃទៀត គឺសុខវេទនា ឬសោមនស្សវេទនា កើតបន្តហើយក៏រលត់ទៅ មិនទៀង វេទនាដ៏ទៃផ្សេងទៀត គឺទុក្ខវេទនា ឬ ទោមនស្សវេទនា កើតបន្តគ្នាហើយតក៏រលត់ទៅ មិនទៀង វិលវល់ផ្លាស់ប្តូរគ្នារាល់ថ្ងៃជានិច្ច មិនចេះចប់ឡើយ សុខទុក្ខប្តូរគ្នាចុះឡើងរហូតដល់ខណៈស្លាប់ អស់សភាពដែលជាបុគ្គលក្នុងជាតិមួយ គ្រប់ៗជាតិតែយ៉ាងនេះឯង ។

ដរាបណាដែលនៅមិនបានអប់រំចំរើនបញ្ញា រហូតដល់ថ្នាក់ដែលអាចរំលត់កិលេសបានជាសមុច្ឆេទ កិលេសទាំងឡាយដែលកើតឡើងមួយលើកៗ មួយខណៈៗ សូម្បីរលត់ទៅហើយក៏សន្សំបន្តតាមខណៈចិត្ត តៗទៅ ជាអនុស័យកិលេស គឺជាកិលេសដែលនៅមិនបានរលត់ ទើបជាបច្ច័យអោយកើតកិលេសប្រភេទនោះៗទៀត សូម្បីទោសមូលចិត្តដែលជាចិត្តថ្នាំងថ្នាក់អាក់អន់ ដោយត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះដូចជា

សំលេងមេក្រូ ឬវិទ្យុកមិនសូវច្បាស់ ខណៈនោះជាចិត្តប្រភេទណា ជាការមិនពេញចិត្តដែលកើតឡើងយ៉ាងរហ័ស ស្រាលៗតិចៗ បើមិនសង្កេតក៏មិនដឹងថា ខណៈនោះជាទោសមូលចិត្ត ។

ការថ្នាំងថ្នាក់អាក់អន់ចិត្ត ការមិនពេញចិត្ត កើតឡើងនិងរលត់ទៅវិញហើយ តែក៏សន្សំការថ្នាំងថ្នាក់នោះបន្តទៅដេកសម្ងំនៅក្នុងនៅចិត្តសន្តាន ជាបច្ច័យអោយទោសមូលចិត្តកើតឡើងទៀតទៅ ដូច្នោះទើបត្រូវពិចារណាអោយដឹងថា សូម្បីការមិនពេញចិត្ត ឬទាស់ចិត្តដោយត្រឹមតែបន្តិចបន្តួចក៏ជាទោសអកុសល ព្រោះបើមិនមែនជាការថ្នាំងថ្នាក់ អាក់អន់ចិត្តបន្តិចបន្តួច តែជាសេចក្តីក្រោធទៅលើបុគ្គលណាម្នាក់ គឺជាការក្រោធដែលមិនភ្លេចនិងនៅមិនបានបន្ថយចុះ ក៏ធ្វើអោយទៅជាការចងសេចក្តីក្រោធ ជាទុក្ខក្នុងជីវិតនៃបុគ្គលម្នាក់ៗ ។

ព្រះធម៌អនុគ្រោះអោយពិចារណាឃើញទោសរបស់អកុសលនិងសេចក្តីក្រោធ ស៊ឹងបើមិនឃើញទោស ក៏មិនដុសខាត់កំចាត់បង់បានឡើយ ដូច្នោះ បុគ្គលអ្នកមានទុក្ខគួរពិចារណាទុក្ខដែលជាសេចក្តីសោយសោក ខ្វូចចិត្ត អន់ចិត្ត មួម៉ៅក្តៅក្រហាយ មិនស្រស់ស្រាយ ខឹងក្រោធថា ជាលក្ខណៈរបស់ទោសៈ ដែលជាសភាវធម៌សំរាប់ប្រទូសស៊ាយដល់ចិត្តដោយប្រការផ្សេងៗ ។

សម្មោហវិនោទនី អត្ថកថា ខុទ្ទកវត្ថុវិភង្គនិទ្ទេសបានអធិប្បាយលក្ខណៈនៃឧបនាហៈគឺការចងនូវសេចក្តីក្រោធថា បុគ្គលណា រមែងចងនូវសេចក្តីក្រោធទុកក្នុងកាលមុន លុះដល់កាលជាខាងក្រោយសេចក្តីក្រោធកើតឡើងទៀតដូចនេះក៏ឈ្មោះថា **ឧបនា** ។

ចងនូវសេចក្តីក្រោធមានកិច្ចមិនលះបង់នូវពៀរ អធិប្បាយថា បុគ្គលអ្នកប្រកបដោយសេចក្តីក្រោធក្នុងលក្ខណៈណា រមែងមិនអាចដើម្បីលះបង់នូវពៀរ បុគ្គលនេះរមែងជាប់តាមក្រសែនៃសេចក្តីក្រោធដទៃៗទៀត ដោយថា ( បុគ្គលនេះមិនសមគួរនិយាយជាមួយយើងនូវពាក្យយ៉ាងនេះ ) ដូចនេះសេចក្តីក្រោធរបស់គេ រមែងឆេះឡើងដូចភ្លើងឆេះអុសស្ងួត សេចក្តីក្រោធរមែងមិនស្អាតដូចសាច់ដែលមានដំបៅ ។

**គ្រប់គ្នាមិនចង់ខឹងក្រោធ** ព្រោះនៅពេលដែលខឹងក្រោធហើយវាជាទុក្ខ កាលមិនសប្បាយចិត្តក៏ជាទុក្ខ សេចក្តីសោកក៏ជាទុក្ខ ។ ល ។

**គ្រប់គ្នាមិនចង់មានទុក្ខ** តែដែលនឹងមិនមានសេចក្ដីទុក្ខទៅបាននោះត្រូវពិចារណាអោយល្អិតល្អន់ដល់ហេតុដែលនាំអោយកើតទុក្ខ មិនថាទុក្ខនោះគ្រាន់ តែជាទុក្ខបន្តិចបន្តួច ឬថាជាទុក្ខធំ ក៏ត្រូវតែកើតអំពីហេតុនៃទុក្ខនោះ ហេតុនៃសេចក្ដីទុក្ខ គឺការត្រេអរពេញចិត្តក្នុងរូប សំលេង ក្លិន រស ផោដ្ឋព្វៈ ។

បុគ្គលដែលរំលត់សេចក្ដីត្រេកអរពេញចិត្តក្នុង រូប សំលេង ក្លិន រស ផោដ្ឋព្វៈ បានហើយនោះ ក៏ជាការរំលត់នូវទោសមូលចិត្តបានផងដែរ ប៉ុន្តែបើនៅជាអ្នកត្រេកអរពេញចិត្តក្នុង រូប សំលេង ក្លិន រស ផោដ្ឋព្វៈ រមែងរត់គេចចេញអំពីទុក្ខមិនផុតឡើយ ព្រោះសេចក្ដីត្រេអរក្នុងវត្ថុកាម ជាហេតុធ្វើអោយទោសមូលចិត្តកើត កាលមិនបានរបស់ដែលជាទីប្រាថ្នា ។

លោភៈជាសភាវៈធម៏ដែលល្អិត ព្រោះថាក្រៅអំពីការជាប់ជំពាក់ត្រេអរពេញចិត្តក្នុង រូប សំលេង ក្លិន រស ផោដ្ឋព្វៈ ជាប្រក្រតីក្នុងជីវិតប្រចាំថ្ងៃហើយ ក៏នៅមានអកុសលធម៏ដែលកើតជាមួយលោភៈ ដូចជាទិដ្ឋិចេតសិក គឺការឃើញខុស និងមានៈចេតសិក គឺការប្រកាន់លើកដំកើងខ្លួន ដូច្នោះទុក្ខទើបមានការបន្ថែមឡើងពីការស្រឡាញ់ជាប់ជំពាក់ក្នុងវត្ថុកាម គឺការដែលមាននូវទិដ្ឋិមានៈក៏ជាបច្ច័យអោយកើតទុក្ខ ឬទោសមូលចិត្តបន្ថែមឡើងទៀត ក្នុងកាលណាដែលមិនបាននូវរបស់ជាទីប្រាថ្នាត្រូវការ ។

ដូច្នេះទើបគួរពិចារណានូវសេចក្ដីផ្សេងៗ ដែលបានសំដែងទុកក្នុងព្រះត្រៃបិដកជាប្រយោជន៍អោយដឹងថា បុគ្គលម្នាក់ៗដែលមាននូវសេចក្ដីទុក្ខសុទ្ធតែកើតមកអំពីហេតុបច្ច័យផ្សេងៗ។

ការស្រវឹងនឹងជាតិកំណើត ពិតជាហេតុនាំអោយកើតទុក្ខទោមនស្ស គ្រាន់តែការរៀបចំទទួលមិនសមនឹងភាពនៃខ្លួនជាអ្នកខ្ពង់ខ្ពស់ ក៏ទោមនស្សអាក់អន់ចិត្ត សូម្បីបន្តិចបន្តួចក៏ជាទុក្ខបើមានការគោរពរាប់រកមិនដិតដល់ ក៏អាចជាហេតុអាក់អន់ចិត្តព្រោះខ្លួនគិតថា បុគ្គលដទៃដូចជាយើងនេះមិនមានគ្រប់គ្នាដែលមាននូវមានៈ រមែងត្រូវការអោយអ្នកដទៃឃើញសេចក្ដីសំខាន់របស់ខ្លួន ខណៈណាដែលបុគ្គលដទៃ មិនឃើញសេចក្ដីសំខាន់របស់ខ្លួនខណៈនោះ ក៏ជាបច្ច័យអោយកើតទុក្ខគឺទោសមនស្សវេទនាដែលកើតជាមួយនឹងទោសមូលចិត្ត ។

បុគ្គលខ្លះស្រវឹងក្នុងការមិនមានរោគ រមែងមានមានៈថាយើងមិនមានរោគ បុគ្គលដទៃក្រៅអំពីយើងមានរោគច្រើន អ្នកខ្លះក៏

គិតថាព្យាធិ សូម្បីគ្រាន់តែលើស្បែករបស់យើងក៏មិនមាន បើជាអ្នកស្រវឹងដល់ទៅយ៉ាងនេះ កាលកើតរោគឡើងគ្រាន់តែសើស្បែកបន្តិចបន្តួចនៅលើមុខ ឬទីដទៃ ដូចកើតមុន ឬជាំមុខក៏ជាទុក្ខទោមស្សខូចចិត្ត ។

ក្នុងមួយថ្ងៃៗទោសមស្សវេទនាកើតឡើង នេះជាធម៌ដែលគប្បីពិចារណាពិតៗ បើមិនពិចារណាក៏មិនអាចជ្រាបបានតាមពិតថា អ្វីជាហេតុនាំអោយកើតទុក្ខទោសមនស្ស ។

បុគ្គលខ្លះ ស្រវឹងក្នុងវ័យក្មេងកម្លោះ ក្រមុំ មិនពិចារណាដល់ការចាស់ ជរា ដែលជារបស់ធម្មតាត្រូវតែធ្លាក់ចុះកាន់រូបកាយ ព្រោះការស្រវឹងក្នុងវ័យ ក៏នាំអោយខូចចិត្តជាទុក្ខរឿយៗនៅពេលចូលដល់វ័យចាស់ ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញ សំលេងស្អក សម្បុរស្អាប់ ក្លិនស្អុយ ។

បុគ្គលខ្លះក៏ស្រវឹងក្នុងជីវិតគិតថា ខ្លួនឯងត្រូវបានជា អ្នកទទួលសេចក្តីសុខសប្បាយរហូតរឿយៗ មិនបានត្រៀមរៀបចំចិត្តក្នុងការដែលនឹងត្រូវជួបប្រទះសេចក្តីទុក្ខលំបាក ឬភ័យវិបត្តិផ្សេងៗឡើយ កាលដល់ពេលវិនាសលាភ ក៏រមែងសោយសោកខ្លាំងក្លា ឬ កាលអ្នកដ៏ទៃបានលាភច្រើនជាង ក៏ខូចចិត្ត ព្រោះថាខ្លួនធ្លាប់ជាអ្នកដែលបានលាភច្រើនជាងគេ ដូច្នេះគប្បីពិចារណានូវចិត្តអោយល្អិតល្អន់ ការសប្បាយរីយរាយណាៗទាំងអស់សុទ្ធតែអាស្រ័យជីវិត អាស្រ័យជាតិកំណើត អាស្រ័យបញ្ចក្ខន្ធ ដែលរបស់សំរាប់ជាទីអាស្រ័យនៃសេចក្តីសប្បាយរីករាយនោះរមែងជាទីធ្លាក់ចុះនៃជរា ព្យាធិ មរណៈ និងបញ្ហាគ្រប់ជំពូក ព្រមទាំងសត្រូវ គឺកិលេសសព្វគ្រប់ ។

បុគ្គលខ្លះស្រវឹងនៅក្នុងសក្ការៈ គឺរបស់ដែលអ្នកដទៃនាំមកបូជា ឬយកមកអោយដោយឃើញសេចក្តីសំខាន់ ភាពធំដុំខ្ពស់មុខមាត់ ឬឃើញដល់គុណធម៌ផ្សេងៗ កាលដល់ពេលអស់បុណ្យមិនមានអ្នកណាបែរងាករកមើលមុខរាប់រក ក៏ជាទុក្ខទោសមស្ស ។

បុគ្គលខ្លះស្រវឹងនៅក្នុងសេចក្តីគោរព រហូតដល់ទៅមានគំនិតថា មនុស្សទាំងឡាយមិនត្រូវគោរពអ្នកនេះ អ្នកនោះ តែត្រូវធ្វើសេចក្តីគោរពយើងគិតថា គេទាំងអស់នោះឃើញយើងហើយរមែងសំពះធ្វើសេចក្តីគោរព ។ ត្រូវពិចារណាសេចក្តីល្អិតល្អន់របស់ចិត្ត ព្រោះថាគ្រប់គ្នាក៏ធ្វើការគោរពជាប្រចាំ តែបើជួបប្រទះអ្នកណាម្នាក់ដែលធ្លាប់ធ្វើការគោរព ហើយពេល

នោះគេមិនសំដែងការគោរព ក៏អាចថ្នាំងថ្នាក់អាក់អន់ចិត្ត នេះគឺសេចក្តីប្រកាន់ខ្លួនហើយជាការស្រើងចំពោះការគោរពរបស់អ្នកដ៏ទៃដូចត្រីដែលបានផ្អែមមាត់ជាមួយខ្លាញ់ក្តាមបិទនៅនឹងផ្លែសន្ទូចរបស់នាយព្រានសន្ទូច ។

សេចក្តីក្នុងអត្ថកថាខុទ្ទកវត្ថុវិភង្គ បានសំដែងសេចក្តីល្អិតល្អន់តទៅរហូតដល់បុគ្គលជាអ្នកស្រើងក្នុងភាពជាប្រធាននាំមុខ ជាអ្នកកាត់ក្តីសំរេចបញ្ហារបស់ពួកគណៈ ឬសូម្បីភិក្ខុនិមន្តទៅបិណ្ឌបាត កាលនិមន្តដើរនាំមុខ ក៏មានមានៈ ថាលោកដទៃតាមអាត្មាអញទៅ ព្រោះអាត្មាអញជាអ្នកនាំមុខ កាលអស់សភាពនៃការនាំមុខនោះទៅនៅពេលណា ក៏រមែងធ្វើអោយកើតទោសមនស្ស ។

ក្រៅអំពីនោះក៏ជាអ្នកមានសេចក្តីស្រើងនៅក្នុងបរិវារ ចូលចិត្តមានអ្នកនៅជុំវិញច្រើនៗហែរហម អមដំណើរ តែបើមានត្រឹមបន្តិចបន្តួច ឬមិនមានសោះ តើមានសេចក្តីដឹងខ្លួនយ៉ាងម៉េចដែរ នេះគឺហេតុដែលនាំអោយកើតទុក្ខក្នុងមួយថ្ងៃៗ ។

ក្រៅអំពីនោះមានការស្រើងនៅក្នុងភោគសម្បត្តិ ក្នុងលាភដែលបានមកស្រើងក្នុងវណ្ណៈ ជាការស្អាតស្រស់ ចំពោះសម្រស់រាងកាយ ឬក្នុងគុណធម៌ផ្សេងៗ ដែលល្អៗ មានអ្នកដទៃសរសើរ ដូចជាពហុស្សូត ឬមានសីល ឬជាអ្នករក្សាធុតង្គ បើមនុស្សដទៃមិនដឹងក៏ខូចចិត្ត នេះក៏ជារឿងនៃសេចក្តីស្រើងទាំងអស់ បើស្រើងហើយក៏ជាហេតុនាំអោយកើតមានសេចក្តីទុក្ខ ។

ខ្លះទៀតស្រើងនៅក្នុងការសិក្សាថា ខ្លួនជាអ្នកមានការសិក្សាច្រើន ខ្លះក៏ស្រើងចំពោះបដិភាណ គឺការឆ្លាតនៅក្នុងការឆ្លើយតបបញ្ហាបើអ្នកដទៃមិនបានលើកដំកើងក៏ជាទុក្ខតូចចិត្ត ។

បុគ្គលខ្លះស្រើងក្នុងរត្តញ្ញូ ជាអ្នកដឹងរាត្រីយូរ ជាបុគ្គលក្នុងវ័យចាស់ ធ្លាប់ជួបធ្លាប់ប្រទះរឿងរ៉ាវច្រើន ភិក្ខុក៏ស្រើងក្នុងការប្រព្រឹត្តបិណ្ឌបាតជាវត្ត កាលបើអ្នកដទៃមិនត្រេអរអនុមោនាក៏ខូចចិត្ត ។

បុគ្គលខ្លះក៏ជាអ្នកស្រើងក្នុងភាពដែលថា មិនមានអ្នកណាមើលងាយ អាចជាអ្នកដែលមានសេចក្តីល្អច្រើន យ៉ាងរហូតដល់មិនមានអ្នកណាតិះដៀល ទើបធ្វើអោយកើតសេចក្តីស្រើងបានថា យើងមិនធ្លាប់មានអ្នកណាមើលងាយឡើយ បើតែយ៉ាងនេះកាលមានគេតិះដៀលត្រឹមតែបន្តិចបន្តួច តើមានសេចក្តីដឹងខ្លួនយ៉ាងម៉េចដែរ អាចជាទុក្ខធ្ងន់ជាងអ្នកដែលដឹងខ្លួនថា មាន

ច្រើនយ៉ាងដែលខ្លួននៅមិនទាន់ល្អ កាលអ្នកដទៃតិះដៀលក៏គួរទទួលស្តាប់ មិនមែនជារបស់គួរថ្នាំងថ្នាក់អាក់អន់ចិត្តឡើយ ។

បុគ្គលខ្លះស្រវឹងក្នុងឥរិយាបទដែលគួរជ្រះថ្លា ក្នុងកិរិយាមារយាទដែលល្អ តែបើមានធ្វើអ្វីភ្លាំងភ្លាត់គ្រាន់តែបន្តិចបន្តួច រមែងក្តៅចិត្ត តួយ៉ាងដូចជាកាន់ចានឬកែវធ្លាក់បែក ឬប៉ះកែវទឹកដួលជាដើមដែលមិនធ្លាប់មានមកអំពីមុន ។

សូមកុំភ្លេចថា **អ្វីៗគ្រប់យ៉ាងរមែងកើតឡើងបានជាធម្មតា** ដូច្នេះបើបុគ្គលមិនស្រវឹងនៅក្នុងរបស់អ្វីមួយក៏មិនបានជួបនឹងសេចក្តីក្តៅក្រហាយចិត្តដែរ ។

ក្រៅអំពីនោះក៏ជាអ្នកស្រវឹងក្នុងឥទ្ធិឫទ្ធិ ស្រវឹងក្នុងយសស្រវឹងក្នុងសីល ស្រវឹងក្នុងឈាន សេចក្តីស្រវឹងមិនមែនតិចតួចមិនងាយស្វាង សូម្បីក្នុងសិល្បៈក្នុងរូបកាយទ្រង់ទ្រាយសណ្ឋានអវៈយវៈតាំងតែចុងសក់ចុះដល់បាទជើងសុទ្ធតែជាវត្ថុនាំអោយស្រវឹង កាលប្រែប្រួលទៅក៏នាំអោយខូចចិត្តស្តាយគឺជាទុក្ខ ។ **មានការស្រវឹងច្រើន មានទុក្ខច្រើន ព្រោះថា សភាវធម៌ រមែងមិនអាចតាំងនៅជានិច្ចបានឡើយ** ត្រូវផ្លាស់ប្តូរប្រែប្រួលទៅតាមពេលវេលា ដូច្នេះជំនួសការគិតថាអ្វីដទៃគ្រាន់បើជាងយើងមិនបាន គួរតែសេចក្តីព្យាយាមអោយឃើញកិលេសរបស់ខ្លួនឯងវិញ ត្រូវមានការតាំងចិត្តពិតៗក្នុងកាលដែលឃើញសេចក្តីមិនល្អរបស់ខ្លួនឯងហើយ គប្បីលាងជំរះដុសខាត់អោយបានស្អាត ។

នេះជារឿងនៃសេចក្តីទុក្ខក្នុងជីវិតប្រចាំថ្ងៃ កាលពិចារណាហើយ ក៏នឹងឃើញបានថាមកអំពីហេតុច្រើនយ៉ាង ប៉ុន្តែមានផ្លូវដែលត្រូវរីករាយស្កប់ស្កល់ក្នុងកុលសច្រើនយ៉ាង ហើយបន្ថយចុះនូវអកុលសដែលជាទោសមូលចិត្ត កាលបើពិចារណាដល់ហេតុដែលនឹងអោយកើតទោសមូលចិត្តរបស់ខ្លួនឯងដោយល្អិតល្អន់ ។

សេចក្តីសុខនិងសេចក្តីទុក្ខផ្លាស់ប្តូរគ្នា សេចក្តីសុខរមែងមានដល់មនុស្សទាំងឡាយដោយកាល សេចក្តីទុក្ខរមែងមានដល់មនុស្សទាំងឡាយដោយកាល ទេវតាជាន់កាមាវចរ សេចក្តីសុខរមែងមានដល់ទេវតាទាំងឡាយនោះដោយកាល សេចក្តីទុក្ខរមែងមានដល់ទេវតាទាំងឡាយនោះដោយកាល ទេវតាទាំងឡាយនោះជាអ្នកទាបគឺស័ក្តិតូចឃើញ ទេវតាដែលមានស័ក្តិធំជាងហើយ ចាំបាច់ក្រោកឡើងចាកអាសនៈត្រូវជៀសចេញចាក

ផ្លូវ គប្បីធ្វើអញ្ជាលីកម្ម របស់នោះទាំងអស់ឈ្មោះថាជាសេចក្តីទុក្ខ ។

ស្តាប់ទៅដូចជាមិនមែនទុក្ខ ប៉ុន្តែចំពោះចិត្តអ្នកណាដឹងថាម៉េច វាមានសេចក្តីថ្នាំងថ្នាក់ មានការមិនពេញចិត្ត មានការអន់ចិត្តក្នុងខណៈដែលឃើញទេវតាមានស័ក្តធំជាង ហើយចាំបាច់ ត្រូវក្រោកចាកអាសនៈ ត្រូវគេចចេញចាកផ្លូវ និងគប្បីធ្វើអញ្ជាលីកម្ម ។

បុគ្គលខ្លះអាចមិនចង់សំពះអ្នកដទៃ ព្រោះគិតថាអ្នកដទៃគួរសំពះខ្លួនឯង ជួនកាលមិនចង់សំពះតែគិតថា បុគ្គលនេះគួរសំពះក៏ធ្វើអញ្ជាលិកម្មទៅទាំងមិនសប្បាយចិត្ត ចង្អៀតចង្អល់ចិត្តសូម្បីស្រាលៗក៏ដោយតែគប្បីជ្រាបថាវាជាទុក្ខ ។

បើជាបុគ្គលល្អិតល្អន់ពិតៗ សតិប្បដ្ឋានក៏អាចរលឹកលក្ខណៈនៃសេចក្តីថ្នាំងថ្នាក់អាក់អន់ចិត្ត ដែលជាចិត្តគប្បីត្រូវរលឹកដឹង បើមិនរលឹកដឹងការថ្នាំងថ្នាក់ចិត្តនោះទេ ក៏ជាយើង ជាតួខ្លួនយើង ហើយមិនអាចរំលត់ការប្រកាន់សភាវធម៌នោះថា ជាតួខ្លួន សត្វ បុគ្គលបានឡើយ ។

មានអ្នកណាគិតថានឹងលះបង់នូវកិលេសបាន ដោយមិនចាំបាច់រលឹកដឹងនូវការថ្នាំងថ្នាក់ អាក់អន់ចិត្តប្រព្រឹត្តទៅពុំបានឡើយ ព្រោះហេតុអ្វី ព្រោះការបដិឃៈថ្នាំងថ្នាក់ចិត្តមានពិតៗកាលការថ្នាំងថ្នាក់ចិត្តមានពិត ជាសភាវធម៌ដែលកើតឡើង និងធ្លាប់ប្រកាន់ថាជាយើង បញ្ញាត្រូវដឹងច្បាស់ក្នុងលក្ខណៈ នៃសភាវធម៌ដែលធ្លាប់ប្រកាន់ និងដឹងថាលក្ខណៈនោះ មិនមែនតួខ្លួនគឺជាសភាពនៃនាមធម៌ម្យ៉ាងប៉ុណ្ណោះ ។

ក្រៅអំពីការថ្នាំងថ្នាក់ អាក់អន់ចិត្តបន្តិចបន្តួច ដែលសំរាប់ធ្វើអោយប្រាសចាកសេចក្តីសុខ និង កំចាត់បង់នូវប្រយោជន៍នោះពេលខ្លះទោសមូលចិត្តដែលកើតឡើងក្នុងជីវិតរបស់បុគ្គលម្នាក់ៗហ្នឹងឯងរមែងជាទុក្ខធំដែលអាចឃើញបានច្បាស់ ។

ក្នុងសម្មោហវិនោទនី អដ្ឋកថាសច្ចវិភង្គនិទ្ទេស **និទ្ទេសសោក** អំពីព្យសនៈគឺសេចក្តីវិនាស ៥ ប្រការបានដល់ញាតិ ព្យសនៈ១ ភោគព្យសនៈ១ រោគព្យសនៈ១ សីលព្យសនៈ១ ទិដ្ឋិព្យសនៈ១ សេចក្តីសោក រមែងកើតមកអំពីព្យសនៈទាំងអស់នេះ ។

**១. ញាតិព្យសនៈ** ការវិនាសញាតិដោយប្រការផ្សេងៗដែលញាតិជាទីស្រឡាញ់ កាលព្រាត់ប្រាសទៅ រមែងនាំអោយកើតទុក្ខព្រោះមានលោភៈជាហេតុ ។

កាលមានសេចក្តីត្រេកអរពេញចិត្តក្នុងសត្វបុគ្គលក្នុងវត្ថុណាៗ រមែងមានទុក្ខដែលកើតព្រោះរបស់នោះ កាលញាតិអស់ជីវិតទៅក៏ត្រូវមានសេចក្តីសោក ខូចចិត្ត ឬសូម្បីគ្រាន់តែញាតិមានវិបត្តិអន្តរាយផ្សេងៗ បុគ្គលដែលជាប់ជំពាក់ជាមួយ ក៏ជាទុក្ខទោសមស្ស ។

បុគ្គលណាធ្វើរបស់អោយជាទីស្រឡាញ់ជាប់ជំពាក់ បុគ្គលនោះឈ្មោះថាធ្វើសេចក្តីទុក្ខអោយចំរើន ។

បុគ្គលណាមិនធ្វើរបស់អោយទីស្រឡាញ់ជាប់ជំពាក់ បុគ្គលនោះឈ្មោះថាធ្វើសេចក្តីទុក្ខអោយវិនាស ។

២ . **ភោគព្យសនៈ** ការវិនាសនូវទ្រព្យសម្បត្តិដោយហេតុផ្សេងៗ បើសម្បត្តិបន្តិចបន្តួច ក៏មិនសូវសោកស្តាយប៉ុន្មានដែរ តែបើសម្បត្តិដែលវិនាសទៅនោះច្រើន ក៏មានសេចក្តីខឹងខ្លួនញាប់ញ័រ តក់ស្លុតសោកស្តាយខ្លាំងទៅតាមការដែលជាប់ជំពាក់ ប៉ុន្តែសូមបានពិចារណា ការវិនាសទ្រព្យសម្បត្តិជាចំនួនច្រើននោះ ប្រៀបដូចជាការសាកល្បង ព្រោះថាត្រូវមានការវិនាសព្រាត់ប្រាសដ៏ធំធេងជាងនោះទៅទៀត នៅពេលដែលអស់ជីវិត ។ ពេលស្លាប់ជាពេលអស់វិញ្ញាណ អស់ការចងចាំលែង សោយអារម្មណ៍ក្នុងលោកជាការព្រាត់ប្រាស់អស់ពុំមានសល់នៅអ្វីក្នុងជាតិនេះ បដិសន្ធិវិញ្ញាណដែលជាវិបាករបស់កម្មប្បច្ច័យ បានប្រមូលយកនូវអ្វីៗដែលជាធ្លាប់សន្សំក្នុងសន្តានចិត្ត ដោយអំណាចជវនកិច្ច ។

ដូច្នោះកាលនៅមានជីវិត សូម្បីមានការវិនាស ទ្រព្យសម្បត្តិអស់តិចឬច្រើនប៉ុណ្ណាក៏ដោយ ជាការសាកល្បងឬពិសោធន៍ការជាប់ជំពាក់ក្នុងទ្រព្យសម្បត្តិនោះថាតើធ្វីអោយចិត្តញាប់ញ័រខ្លាំង ឬតិចប៉ុណ្ណា ឬក៏មានសេចក្តីមាំទាំព្រមក្នុងការព្រាត់ ។ គ្រប់គ្នាត្រូវចាកលោកនេះទៅ តែថាព្រមឬមិនព្រមក្នុងការលាចាកលោក បើមិនព្រមទេក៏ជាទុក្ខ សោយសោក អាឡោះអាល័យស្តាយ សូម្បីដឹងថាទោះជាយ៉ាងណា ក៏ត្រូវតែលាចាកក៏ដោយ ក៏នៅតែតក់ស្លុត ។

៣ . **រោគព្យសនៈ** ការវិនាសដែលកើតអំពីរោគ ព្រោះរោគរមែងធ្វើការមិនមានរោគអោយវិនាស គឺធ្វើការមិនមានរោគអោយអស់ទៅ ការមានជំងឺ រោគា ព្យាធិ ឈឺចាប់ខ្លាំងក្លានាំអោយកើតទោមនស្សដល់អ្នកអត់បញ្ញា ស៊ឹងគេចមិនផុតដូចគ្នា មិនមានអ្នកណាត្រូវការតែថាស្រេចតែនៅលើកម្មដែល

បានធ្វើទុកហើយ ។

- បញ្ចាក្ខន្ធជារោគ ជាបូស ជាអាពាធ ជាដំបៅ គឺឧបាទានក្ខន្ធ ៥ ជាទុក្ខ ព្រះនិព្វានមិនមានរោគ មិនមានទុក្ខ ។

៤ - **សីលព្យសនៈ** គឺជាការទ្រុស្តសីល រមែងធ្វើសីលអោយវិនាសព្រោះហេតុតែជាប់ក្នុងលាភ ឬយសជាដើម ។

កាលមានទុច្ចរិតកម្ម គឺការប្រព្រឹត្តកន្លងនូវសីលកើតឡើង រមែងបានទទួលទុក្ខដោយប្រការផ្សេងៗ តាំងតែពីខូចកេរ្តិ៍ឈ្មោះ និងមិនមានអ្នកណាគប់រកសមាគមជាដើម ម្យ៉ាងទៀតត្រូវមានទុក្ខព្រោះទទួលនូវផលនៃអកុសលកម្មក្នុងការប្រទូសរ៉ាយសីលនោះៗ តាមសមគួរដល់កាលពេលវេលា និងការធ្ងន់ ឬស្រាលរបស់ទុច្ចរិតកម្មនោះផង ។

៥ - **ទិដ្ឋិព្យសនៈ** ការវិនាសនូវសេចក្តីយល់ត្រូវ ដែលកើតអំពីការយល់ខុស ដែលជាអន្តរាយដ៏ធំ ព្រោះមិនអាចគិតពិចារណាអោយត្រឹមត្រូវហេតុផលនៃសភាវធម៌តាមសេចក្តីពិតបានដូច្នោះ ដរាបណាដែលនៅមិនទាន់ផុតចាកការឃើញខុស សង្សារវដ្តដែលពេញទៅដោយកងទុក្ខពុំអាចអស់ទៅបានឡើយ ។

តទៅក៏នឹងដល់នូវទុក្ខធំ **គឺឧក្ខរបស់មរណៈ** ចប់អស់នូវទុក្ខតូចតាចផ្សេងៗដែលមានក្នុងជីវិតប្រចាំថ្ងៃ សេចក្តីក្នុងសម្មោហវិនោទនី អត្ថកថា សច្ចវិភង្គនិទ្ទេស សំដែងថាសូម្បីមរណៈនេះតួខ្លួនឯងក៏មិនជាទុក្ខ តែព្រះដ៏មានប្រភាគត្រាស់ថា **ឧុក្ខ** ព្រោះជាវត្ថុជាទីតាំងនៃទុក្ខ សេចក្តីពិតវេទនាដែលមានក្នុងសរីរៈនៅពេលជិតស្លាប់ រមែងផុតសរីរៈ ម្យ៉ាងទៀតនិមិត្ត នរកជាដើមប្រាកដ ក៏ដល់នូវទោមនស្សយ៉ាងខ្លាំងក្លាគប្បីជ្រាបថា មរណៈជាទុក្ខ ដោយជាវត្ថុជាទីតាំងនៃទុក្ខទាំងពីរប្រការគឺទុក្ខផ្លូវកាយ ១ និង ទុក្ខផ្លូវចិត្តសំរាប់បុគ្គលមានកាមច្ឆន្ទៈ ១ ដូច្នេះឯង ។

អ្នកសិក្សាជ្រាបហើយថា សេចក្តីស្លាប់នោះក៏គឺខណៈចិត្តចុងក្រោយ បានដល់ **ចុតិចិត្ត** ដែលកើតឡើង ហើយរលត់ទៅធ្វើអោយអស់នូវសភាពនៃបុគ្គលក្នុងកំណើតមួយ នឹងត្រឡប់មកកាន់ភាពជាបុគ្គលដើមវិញ ពុំបានឡើយ ក្នុងជាតិមុនៗនៃសង្សារវដ្តដែលកន្លងទៅហើយ ធ្លាប់ជាអ្នកណា រស់នៅយ៉ាងណា ធ្វើការអ្វីៗ ក៏អស់រលីងនូវសភាពនោះៗនៃបុគ្គលនោះ កាលស្លាប់ចាកជាតិមុនហើយកើតមកជាបុគ្គលក្នុងជាតិនេះ យ៉ាងណា កាលចុតិចិត្តគឺចិត្តដួងចុងក្រោយនៃ ជាតិនេះកើតឡើងនិងរលត់តទៅ ក៏អស់នូវសភាពជាបុគ្គលនេះក្នុងជាតិនេះយ៉ាងនោះឯង។

ត្រឹមតែខណៈចិត្តមួយគឺចុតិចិត្តកើតហើយរលត់ទៅ ហៅស្លាប់ ខណៈចិត្តមួយនោះមិនមានការសោយអារម្មណ៍ជាទុក្ខឡើយ តែទុក្ខកើតមុននោះឯង ព្រោះជាទូទៅវេទនាដែលកើតមុនចុតិ ដុតសរីរៈ ឧបមាដូចគប់ស្នោដែលមានភ្លើងឆេះហើយកាន់ បញ្ចូរាស់ខ្យល់ តែសំរាប់បុគ្គលខ្លះនោះងាយពេកណាស់ ស្លាប់ដោយមិនលំបាក ។

សេចក្ដីពិតដែលប្រៀបការស្លាប់រួចហើយ កើតដូចជាការបិទភ្នែករួចបើកភ្នែកវិញ ការបិទបើកភ្នែកនៅយឺតជាង ព្រោះត្រឹមតែមួយខណៈចុតិចិត្តកើត ហើយរលត់ទៅ បដិសន្ធិចិត្តមួយខណៈត្រូវកើតបន្តភ្លាមនោះ ជាការលឿនរហ័សពេកណាស់ ដូច្នោះបុគ្គលដែលមិនមានទុក្ខវេទនាខ្លាំងក្លា មុនចុតិចិត្តគឺមុនស្លាប់នោះ ក៏ស្រេចតែនៅលើកម្មនៃបុគ្គលម្នាក់ៗដែលបានធ្វើទុកមក ព្រោះកាយបសាទប៉ះខ្ទប់នឹងផោដ្ឋព្វៈណាហើយ ជាបច្ច័យអោយចិត្តដែលជាវិបាករបស់កម្មកើតជាមួយសុខ ឬ ទុក្ខវេទនានោះត្រូវជាផលរបស់កម្មដែលបានធ្វើរួចហើយ ។

បើជាអ្នកដែលព្រមពិតៗ គឺមិនគួរខ្លាចឡើយ ព្រោះថាទាន់ពេលដែលចុតិចិត្តរលត់ បដិសន្ធិចិត្តក៏កើតបន្តភ្លាម កាលនៅមិនអស់កិលេស នៅមិនមែនជាព្រះអរហន្តក៏ត្រូវតែមានបដិសន្ធិបន្តអំពីចុតិ ព្រោះកម្លាំងកម្មជាបច្ច័យ តើខ្លាចស្លាប់ឬទេ ? ព្រោះកាលចុតិចិត្តកើតនិងរលត់ទៅហើយ បដិសន្ធិចិត្តក៏កើតបន្តទាន់ពេល តើស្តាយភពនេះ ជាតិនេះឬទេ ? នេះជារឿងនៃបុគ្គលម្នាក់ៗដែលចង់នៅរស់តទៅទៀត កាលដែលពេលស្លាប់ទៅហើយនោះ ឬក៏ជារឿងរបស់អ្នកយល់ព្រមស្លាប់ កាលណាដែលដល់ពេលស្លាប់ ទាំងនេះក៏ព្រោះថាកាលមានខន្ធកើតឡើងប្រាកដដែលនឹងមិនត្រេអរពេញចិត្ត ប្រកាន់មាំក្នុងខន្ធនោះ ជាការមិនងាយជាទីបំផុត ។

ដរាបណាដែលនៅមិនទាន់ចុតិចិត្ត ក៏រមែងមានសេចក្ដីត្រេកអរ ក្នុងជីវិត ក្នុងភព ក្នុងខន្ធ កាលមានសេចក្ដីត្រេកអរពេញចិត្តក្នុងជីវិត ក្នុងភព ក្នុងខន្ធ មរណៈទើបជាវត្ថុដែលជាទីតាំងនៃទុក្ខ ២ យ៉ាង គឺ ទុក្ខកាយ ១ ទុក្ខចិត្ត១ ។ ប្រការមួយទៀត ព្រោះសេចក្ដីស្លាប់នេះជាទីតាំងនៃសេចក្ដីទុក្ខផ្លូវចិត្តនៃបុគ្គលបាបដែលជិតស្លាប់ ឃើញនូវនិមិត្តអាក្រក់ផ្សេងៗ និងបុគ្គលល្អដែលអត់ទ្រាំមិនបានក្នុងការព្រាត់ប្រាសសត្វនិងសង្ខារជាទីស្រឡាញ់ ។

- ទុក្ខវេទនាដែលសំរាប់ស្លាប់សែនលំបាក ងាយក្នុងការធ្វើអោយវង្វេងស្មារតី ដូច្នេះសាធុជនគប្បីជម្រះនូវឧបាទានចេញអំពីចិត្ត ដើម្បីបាននូវទីពឹងដ៏ពិប្រាកដ ។

បទពិចារណា

- អ្វីដែលត្រូវកើត ក៏កើតតាមហេតុបច្ច័យ បង្គាប់បញ្ជាមិនបាន ។

- បើអត់មានយើងទេ យើងក៏អត់មានទុក្ខដែរ ។

- ដែលហៅថាសត្វបុគ្គល តួខ្លួន យើងគេ ក៏គឺខន្ធ៥នោះឯង ។

- ចិត្តមិនល្អព្រោះកំពុងគិតមិនល្អ ។

- ខណៈដែលគិតល្អ ក៏ជាចិត្តល្អដែលកំពុងគិត ។

- ធ្វើកុលសហើយ ក៏ជារបស់ល្អហើយ មិនចាំបាច់សង្ឃឹមផលតបស្នងឡើយ ។

- មិនគិតមើលងាយមើលថោកអ្នកដ៏ទៃ ហើយក៏មិនស្វែងរកទោសនៃអ្នកដទៃផងដែរ ។

- គិតដល់សេចក្តីល្អរបស់អ្នកដទៃ ដើម្បីអនុមោនា ។

- បរមត្ថជារបស់ដែលមានពិត បញ្ញតិមិនមែនសភាវធម៏ដែលមានពិតឡើយ ។

- គួរមានការស្មោះត្រង់ និងកតញ្ញូអោយច្រើនៗ ។

- លះកិលេស ដើម្បីមិនកើតមកកាន់សភាពបែបនេះទៀត ។

-សម្តេចព្រះសម្មាសម្ពុទ្ធជាម្ចាស់ មិនឈ្លោះជាមួយអ្នកណា ។

- កាលមិនប្រកាន់ខ្លួន មិនភ្លេចខ្លួន មិនអួតអាង ក៏សប្បាយពិតៗ មិនជាទុក្ខ ។

- ខណៈរលឹកដឹងសភាវធម៏តាមសេចក្តីពិតនោះ ជាមជ្ឈិមបដិទា ។

- ហិរិ កើតកាលអប់រំចំរើនបញ្ញា ។

- ពណ៌ សំលេង ក្លិន រស ត្រជាក់ ក្តៅ ទន់ រឹង តឹង ញ័រជារូបបរមត្ថជារបស់ដែលមានពិត ។

- សម្បត្តិបែងចែកគ្នាបាន តែកម្មជារបស់អ្នកណាក៏ជារបស់អ្នកនោះ បែងអោយគ្នាមិនបានឡើយ ។

- ចិត្តដែលមានបាបអកុលស លាមកស្អុយ គិតអាក្រក់ ។

- កុំពេញចិត្តជាមួយកិលេស និង កុំចូលរួមជាមួយខ្លួនឯងដែលមានកិលេស ។

- ត្រូវព្យាយាមកែខៃអ្វីៗដែលមិនល្អដោយការចំរើនសតិប្បដ្ឋានរឿយៗ ។

- ជាប់ជំពាក់ ព្រោះចូលចិត្តសុខវេទនា ។
- មិនឈប់គិត ព្រោះចាំតាក់តែងកម្មដោយការគិត ។
- ការចងគំនុំ ជាដំបៅស្អុយរបស់ចិត្ត ។
- ពុទ្ធបរិស័ទ ត្រូវតែមិនជឿនូវមង្គលភ្ញាក់ផ្អើល និងត្រូវមានការរឹងប៉ឹងចំពោះសទ្ធាដោយជឿច្បាស់ថា គ្រប់គ្នាមានកម្មជារបស់ខ្លួន ។ មានអ្នកណាខ្លះ ដែលកើតមកហើយមិនស្លាប់ មានអ្នកណាខ្លះដែលកើតមកហើយ មិនសុខខ្លះទុក្ខខ្លះ មិនមែនអ្នកដទៃធ្វើអោយការកើតមកក្នុងលោកនេះ ក៏កើតមកព្រោះកម្មរបស់ខ្លួន និងកាលកើតមកហើយ មានដំណើរជីវិតប្រព្រឹត្តទៅយ៉ាងណាក៏ ព្រោះកម្មរបស់ខ្លួននោះឯង ។
- គ្រប់យ៉ាងដែលកើតជាខន្ធទាំងអស់ ។
- ខណៈដែលកំពុងគិតនោះ អ្វីពិត អ្វីមិនពិត បរមត្ថពិត រឿងដែលគិតមិនពិត ។
- សភាវធម៌កើតឡើងហើយក៏រលត់ មិនត្រឡប់មកវិញឡើយ ។
- ខណៈដែលយល់ចូលចិត្តធម៌ ជាកុសលកម្មផ្លូវចិត្ត ។
- ការកើតជាទុក្ខដ៏ក្រៃលែង គួរអប់រំចំរើនបញ្ញាដើម្បីដឹងច្បាស់សច្ចធម៌ ។
- ចេតនាដែលជាកុសលនោះ លះវត្ថុដើម្បីប្រយោជន៍សុខនៃអ្នកដទៃ ដោយមិនសង្ឃឹមផលណាៗតបជំនួស ខណៈនោះចិត្តផ្លូវផង់ប្រាសចាកលោភៈប្រព្រឹត្តទៅដើម្បីជុសខាត់កិលេសរបស់ខ្លួនឯង ។
- លោកប្រាកដ កាលអារម្មណ៍ប្រាកដផ្លូវភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយចិត្ត ។
- ចិត្តអាក្រក់ឬល្អព្រោះចេតសិកដែលកើតរួមជាមួយ ។
- សភាវធម៌គ្រប់យ៉ាងកើតឡើងធ្វើកិច្ចរបស់ខ្លួនគ្រប់ៗខណៈ ។
- សត្រូវ គឺកិលេសជាចោរខាងក្នុង ។
- អត់ធន់ ព្យាយាមរលឹកដឹងលក្ខណៈនៃសភាវធម៌ដែលកំពុងប្រាកដរឿយៗ រហូតជីវិតដោយមិនសង្ឃឹមផល ។
- ខណៈដែលមានមានៈ មិនមែនមេត្តា ។
- ព្រះធម៌តឿនអោយពិចារណាខ្លួនឯង ដើម្បីអោយដឹងថារហូតជីវិតនេះមិនមានតួខ្លួន មិនមានសត្វបុគ្គល មានត្រឹមតែបរមត្ថ គឺរូបធម៌ នាមធម៌ប៉ុណ្ណោះ ។

- ខណៈដែលឃើញរបស់ណាថាជារបស់យើង ទោះជារបស់អ្វីក៏ដោយ ក៏ត្រឹមតែរបស់ខាងក្រៅប៉ុណ្ណោះ គឺជារូបារម្មណ៍ដែលចក្ខុវិញ្ញាណបានឃើញ ជារបស់សាធារណៈចក្ខុវិញ្ញាណរបស់អ្នកណាក៏ឃើញបានដែរ ។

- ខណៈដែលខូចចិត្តខ្លាំង ឬតិចនោះក៏មិនមែនសត្វ បុគ្គលតួខ្លួន យើង គេ ព្រោះជាលក្ខណៈរបស់ទោសៈ ដែលជានាមធម៌ជាចេតសិកមួយបែបបានកើតរួមជាមួយចិត្តក្នុងខណៈនោះហើយក៏រលត់ទៅ ។

- ចិត្តរបស់អ្នកណាក៏ជារបស់អ្នកនោះ កាលក្រោធចំពោះអ្នកណា ចិត្តក៏ជាទុក្ខ ដូចភ្លើងឆេះពីអុសណាក៏ដុតកំទេចនូវអុសនោះដូច្នោះដែរ ។

- ខំកសាងកុសលរៀង១ខ្លួនទៅ កុំរវល់តែបញ្ជូនចិត្តទៅដើម្បីប្រកាន់គ្នាទៅវិញទៅមកវាចំរើនតែបាបទេ ។

- បើពិតជាពឹងសេចក្ដីល្អរបស់ខ្លួនឯងចាំបាច់រករឿងឈ្លោះគ្នាធ្វើអ្វី ។

- អ្នកបានធម៌ គឺមិនហួងហែងបុគ្គលដទៃ សូម្បីខ្លួនឯងក៏មិនប្រកាន់មាំ ។

- បុគ្គលសង្វេគចំពោះសង្ខារ រមែងមានចិត្តជ្រះស្រឡះ មិនរករឿងឈ្លោះនឹងអ្នកដទៃ ជាបុគ្គលស្ងប់ស្ងាត់ មានចិត្តនឹងធឹងមិនមានការច្រណែន មិនលើកដំកើងខ្លួនឯង មិនមើលងាយអ្នកដទៃ មិនក្រោធខឹងជាមួយអ្នកណាឡើយ ។

- វត្ថុកាមជាទីតាំងនៃសេចក្ដីជាប់ជំពាក់ត្រូវការ ជាសន្ទូចជាអន្ទាក់របស់មារ ។

- បើសតិកើត មិនគិតក្នុងរឿងឥតប្រយោជន៍ ។

- មិនមានអ្នកយល់សប្តិ មិនមានអ្នកដេកលក់ មិនមានអ្នកភ្ញាក់ គឺមានត្រឹមតែវិថីចិត្តប៉ុណ្ណោះ ។

- ខណៈយល់សប្តិ ជាកុសលចិត្ត ឬ អកុសលចិត្តដែលគិតនឹករឿងរ៉ាវផ្សេង១ប៉ុណ្ណោះ ។

- កាលបានជ្រាបដឹងនូវអកុសលរបស់អ្នកដទៃហើយ គួរមានមេត្តា ។

- នាមរូបកើតរលត់ បញ្ញត្តិមិនមែនជាសភាវធម៌ ទើបមិនកើតមិនរលត់ ។

- ត្រូវសិក្សាអោយស្គាល់កិលេសដែលល្អិត ។

- រូបមិនដឹងអ្វីឡើយ សភាវៈដឹងជានាមធម៌ សត្វ បុគ្គលក្នុង ឬ

ក្រៅនាមរូប គឺ មិនមានឡើយ ។

- ធម្មៈគឺខណៈនេះឯង សិក្សា ពិចារណា អោយយល់ចូលចិត្ត នូវសភាវធម៌ក្នុងខណៈនេះ ។

- សតិចេតសិកកើតជាមួយចិត្តដែលល្អតែប៉ុណ្ណោះ ហើយតែងតែប្រឆាំងនឹងមោហៈអវិជ្ជាជានិច្ច ។

- ឃើញសត្វ បុគ្គល តួខ្លួន យើង គេ ក៏ដូចឃើញ ស្រមោលក្នុងកញ្ចក់ ។

- មិនគួរភ្ញាក់ផ្អើលក្នុងរបស់ដែលអត់ខ្លឹមសារ គួរអោយរឹងមាំក្នុងកុសលខ្លាំងឡើង១ ។

- បានឮពាក្យសរសើរហើយស្ងប់កិលេស ឬទេ គួរត្រៀមរៀបចំទទួលសេចក្ដីស្លាប់វិញប្រសើរជាង រង់ចាំទទួលការសរសើរ ។

- គួរប្រយ័ត្នប្រយែងនូវស្មារតីអោយបានណាស់ ក្នុងពេលដែលអ្នកដទៃលើកដំកើង ឬ មើលងាយ សរសើរ ឬនិន្ទា ។

- ត្រូវអត់ធន់ក្នុងកាលដែលអ្នកដទៃមានអកុសល សូម្បីតែតិះដៀលក្នុងចិត្ត ។

- គួរអាណិតអ្នកដែលមាននូវអកុសល ព្រោះរមែងសន្សំនូវអកុសលច្រើនឡើង១ទៀត ។

- សត្វលោកជាកម្មទាយាទគឺជាអ្នកទទួលនូវមតិករបស់កុសលកម្ម និង អកុសលកម្ម បញ្ញាដែលដឹងនូវសភាវធម៌ តាមសេចក្ដីពិត ជាសម្បត្តិដ៏មានតម្លៃក្រៃលែងជាសម្បត្តិដទៃ និងត្រូវតែបញ្ញារបស់ខ្លួនឯង ។

- រង្កៀសចំពោះអកុសលរបស់ខ្លួនឯង ជំនួសការរង្កៀសចំពោះអកុសលរបស់អ្នកដទៃ ។

ពុទ្ធបរិស័ទក្នុងនគររម្មៈ ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធទីបង្ករជាប្រធានហើយ ក៏បូជាព្រះដ៏មានព្រះភាគជាម្ចាស់ដោយផ្កាឈើ និងគ្រឿងក្រអូបជាដើមទៀត ថ្វាយបង្គំហើយចង់ស្ដាប់អនុមោនាទាន ទើបចូលទៅអង្គុយជិត១ លំដាប់នោះព្រះសាស្ដាបានត្រាស់អនុមោនាទានដ៏ពិរោះយ៉ាងក្រៃលែង ជាទីចាប់ចិត្តរបស់ឧបាសក ឧបាសិកាទាំងអស់នោះថា ធម្មតាទានលោកពោលថាជាដើមហេតុសំខាន់របស់សេចក្ដីសុខជាដើមនិងពោលទៀតថាជាទីតាំងនៃដណ្ដើរទៅកាន់ព្រះនិព្វាន ។

ទានជាគ្រឿងការពាររបស់មនុស្ស ជាផៅពង្ស ជាគ្រឿងនាំមុខ ទានជាគតិដ៏សំខាន់របស់សត្វ ។

ទានលោកសំដែងថា ជាគ្រឿងជួយចម្លងទុក្ខ និង ទានលោក

សរសើរថា ជានគរការពារភ័យ ។

ទានលោកពោលថា ជាអាសិរពិស ព្រោះអត្ថថា ចូលជិតបានដោយលំបាក ទានដូចជាផ្កាឈូកព្រោះអត្ថថា មន្ទិលមានលោភៈជាដើមមិនអាចប្រឡាក់បាន ។

ទីពឹងពាក់ពំនាក់អាស្រ័យរបស់បុរសស្ត្រី ស្មើដោយទានមិនមានក្នុងលោក ព្រោះដូច្នោះអ្នកទាំងឡាយចូរបំពេញទានដោយការធ្វើតាមអធ្យាស្រ័យ ។

តើនរជនណាទៅ ដែលជាអ្នកមានបញ្ញាក្នុងលោកនេះ ជាអ្នកត្រេអរក្នុងប្រយោជន៍ទំនុបបំរុង មិនអោយនូវទានទាំងឡាយដែលជាហេតុនៃស្ថានសួគ៌។

តើនរណាទៅ ដែលឮថាទានជាដែនកើតសម្បត្តិនៃទេវតាទាំងឡាយ ហើយមិនគប្បីអោយទានដែលនាំមកនូវសេចក្តីសុខ ទានជាគ្រឿងនាំមកនូវសេចក្តីសុខ ទានជាគ្រឿងញ៉ាំងចិត្តអោយរីករាយ ។

នរជនបំពេញទានហើយ ក៏ជាបុគ្គលដែលទេពអប្សរចោមរោម អភិរម្យក្នុងនន្ទវ៉ន៍ដែលជាទីរីករាយសុខសំរាន្តរបស់ទេវតារហូតអស់កាលយូរ ។

អ្នកអោយទានរមែងបានបីតិដ៏ឱឡារិក រមែងប្រសព្វជួបប្រទះនូវការគោរពក្នុងលោកនេះអ្នកអោយទានរមែងជួបប្រសព្វនូវកិត្តិយសដ៏ធំធេង អ្នកអោយទានរមែងជាអ្នកដែលមហាជនទំនុបទុកចិត្ត ។

នរជននោះអោយទានហើយ រមែងបានដល់នូវភាពមាំទាំនៃភោគៈ និងមានអាយុវែង រមែងបានជាអ្នកមានរូបស្អាត មានសំលេងពិរោះនៅក្នុងវិមានទាំងឡាយ សប្បាយរីករាយក្នុងស្ថានសួគ៌ ។

ទានជាទ្រព្យមិនទូទៅដល់ភ័យទាំងឡាយ គឺចោរភ័យ អគ្គីភ័យជាដើម ទាននោះរមែងអោយសាវកញាណភូមិ បច្ចេកពុទ្ធភូមិរហូតដល់ពុទ្ធភូមិ ។

គ្រាទ្រង់ធ្វើអនុមោនាទាន ប្រកាសអានិសង្សនៃទានដោយន័យដូចពោលមកយ៉ាងនេះជាដើមហើយ ក៏ត្រាស់សីលកថាក្នុងលំដាប់តអំពីទាននោះ ធម្មតាសីលនោះជាមូលនៃសម្បត្តិក្នុងលោកនេះនិងលោកខាងមុខ។

សីលជាដើមហេតុសំខាន់របស់សុខទាំងឡាយ អ្នកមានសីលរមែងទៅកាន់សុគតិភព សីលជាគ្រឿងការពារ ជាគ្រឿងជ្រក

ពូនជាគ្រឿងនាំមុខ ។

ទីពឹងពំនាក់អាស្រ័យរបស់ជនទាំងឡាយក្នុងលោកនេះ ឬក្នុងលោកដទៃដែលស្មើដោយសីលនឹងមានមកអំពីណាសីលជាទីតាំងសំខាន់នៃគុណទាំងឡាយដូចផែនដីជាទីតាំងនៃសព្វរបស់ទាំងពួងលើផែនដីដូច្នោះឯង ។

សីលជាកម្មល្អ សីលជាគុណជាតិដ៏ខ្ពង់ខ្ពស់នៅក្នុងលោកអ្នកប្រព្រឹត្តដោយប្រពៃក្នុងធម្មចរិយារបស់ព្រះអរិយៈលោកហៅថាអ្នកមានសីល ។

ព្រះរាជាទាំងឡាយទ្រង់ប្រដាប់ដោយកែវមុក្តា និងកែវមណីនៅល្អមិនដូចបុគ្គលប្រដាប់ដោយគ្រឿងប្រដាប់គឺសីល រមែងល្អរុងរឿង ។

ក្លិនដែលក្រអូបទៅទាំងតាមខ្យល់ ទាំងបញ្ច្រាសខ្យល់ស្មើដោយក្លិនសីលនឹងមានមកពីណា ។

ក្លិនផ្កាឈើមិនក្រអូបបញ្ច្រាសខ្យល់ ឬ ក្លិនចន្ទន៍ ក្រស្នា ផ្កាម្លិះក៏មិនក្រអូបបញ្ច្រាស់ខ្យល់ ចំណែកក្លិនរបស់សប្បុរសរមែងក្រអូបបញ្ច្រាសខ្យល់ សប្បុរសរមែងក្រអូបទៅគ្រប់ទិស ។

ក្លិនគឺសីលជាកំពូល នៃគន្ធជាតិទាំងអស់នេះ គឺចន្ទន៍ ក្រស្នា ឧបល ម្លិះ ។

មហានទី គឺ គង្គា យមុនា សរភូ សរសវតី និន្នគា អចិរវតី មហី មិនអាចជំរះមន្ទិលរបស់សត្វទាំងឡាយក្នុងលោកនេះ តែទឹកគឺសីលរមែងជំរះមន្ទិលរបស់សត្វទាំងឡាយបាន ។

អរិយសីលនេះ ដែលរក្សាល្អហើយមានភាពត្រជាក់ដ៏ក្រៃលែង រមែងរំងាប់សេចក្តីក្តៅក្រហាយបាន ចំណែកចន្ទន៍លឿងខ្សែមាស កែវមណី និងស្មើដួងចន្ទ្រ័ រំងាប់សេចក្តីក្តៅក្រហាយមិនបាន ។

សីលរបស់អ្នកមានសីល រមែងកំចាត់បង់នូវភ័យមិនមានការតិះដៀលខ្លួនឯងជាដើមបានគ្រប់ពេល និងអោយកើតនូវកិត្តិយសព្រមទាំងការរីករាយគ្រប់កាលទាំងពួង ។

របស់ដទៃ សម្ភារៈដទៃជាជណ្តើរឡើងកាន់ស្ថានសួគ៌ស្មើដោយសីលមិនមានឡើយ ម្យ៉ាងទៀតសីលជាទ្វារចូលទៅកាន់នគរព្រះនិព្វានដែលក្សេមចាកទុក្ខ ។

អ្នកទាំងឡាយចូរដឹង អានិសង្សដ៏ខ្ពង់ខ្ពស់របស់សីល ដែលជាឬសគល់នៃគុណទាំងឡាយ កំចាត់នូវទោសទាំងពួងដូចពោលមកនេះឯង ។

- ក្នុងអនុបព្វីកថា បន្ទាប់អំពីទាន សីលព្រះអង្គទ្រង់ត្រាស់សំដែងនូវស្ថានសួគ៌គឺសគ្គកថា ដើម្បីបញ្ជាក់អំពីផលរបស់បុណ្យផង ដើម្បីញ៉ាំងអ្នកស្តាប់អោយមានចិត្តគ្រាកចេញចាកកាមគុណ ជារបស់មនុស្សផង បន្ទាប់មកទៀតព្រះអង្គត្រាស់សំដែនូវទោសរបស់កាម សូម្បីស្ថានសួគ៌ក៏មិនទៀង មិនតាំងនៅជាសុខរហូតឡើយ ស៊ីងប្រែប្រួល ទីបំផុតព្រះអង្គត្រាស់សំដែងនូវព្រះនិព្វានដែលផុតចាកទុក្ខទាំងពួង ។

- បុគ្គលក្នុងលោក រមែងមិនប្រាថ្នាអោយសេចក្តីទុក្ខធ្លាក់មកដល់ខ្លួនឡើយ អ្នកដែលកើតមកហើយគ្រប់ៗគ្នា រមែងស្វែងរកសេចក្តីសុខតែម្យ៉ាង ព្រោះហេតុដូច្នេះ សាធុជនគប្បីលះបង់ការបៀតបៀនគ្នាចោលចេញ ហើយចូរចំរើននូវមេត្តានិងករុណាអោយសម្បូណ៌ឡើង ។

- បុគ្គលបានធ្វើទានលះបង់សម្បត្តិទ្រព្យទំនុបបំរុងអ្នកដ៏ទៃរមែងបានត្រឡប់មកវិញនូវរបស់មានតម្លៃខ្ពឹមសារ គឺបុណ្យដូច្នេះបុគ្គលគប្បីបំពេញនូវទានបារមី ដុសខាត់កិលេសដោយមិនជាប់ជំពាក់ក្នុងទ្រព្យសម្បត្តិដែលត្រូវលះបង់នោះដូចជាក្អមទឹកដែលពេញទៅដោយទឹកត្រូវគេចាក់ទឹកនោះចេញ ផ្កាប់ក្អមហើយផ្ងារមកវិញ ពុំមានទឹកដោយមកតាមក្អមយ៉ាងណាការធ្វើនូវទានបំពេញបារមីដុសខាត់កិលេស ក៏មិនមានការជាប់ជំពាក់ស្តាយនូវទ្រព្យសម្បត្តិដែលបានលះបង់យ៉ាងនោះដែរ ។

- បុគ្គលបំពេញទានបារមី ជាឧបនិស្ស័យសំរាប់លះបង់នូវបញ្ចក្ខន្ធ ព្រោះទានគឺការលះ ។

- បើកុំតែសំរាប់រស់នៅអប់រំបញ្ញា ទ្រព្យសម្បត្តិត្រូវលះបង់ចោលទាំងអស់ទៅ ព្រោះអ្វី? ព្រោះទ្រព្យសម្បត្តិបានធ្វើអោយសត្វលោកវង្វេងស្មារតីក្លាយទៅជាបុគ្គលឆ្កួត ហើយបានបន្តនូវពូជឆ្កួតនេះរាប់ជាតិជាអនេក ដូច្នេះបុគ្គលត្រូវពិចារណានូវបច្ច័យសំរាប់រស់នៅតាមឱវាទរបស់ព្រះពុទ្ធបរមគ្រូ ។

- មនុស្សលោកចេះធ្វើគ្រឿងបំពុលដ៏សាហាវខ្លាំងក្លា ប៉ុន្តែសម្បត្តិទ្រព្យសាហាវជាង បណ្តាការសាហាវក្នុងលោកទាំងអស់គ្រាន់តែជាសាខានៃទ្រព្យសម្បត្តិប៉ុណ្ណោះ ។

- ខន្ធ ៥ គឺជារបស់ក្តៅ ក្តៅដោយសារភ្លើងទុក្ខ ជាតិ ជរា ព្យាធិ មរណៈ ភ្លើងកិលេស គឺរាគៈ ទោសៈ មោហៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្សៈ និង ឧបាយាសៈ ។

- ការសប្បាយរីករាយ ត្រេកត្រអាលនៅក្នុងខន្ធលោកនេះ

ព្រះសម្ពុទ្ធជាម្ចាស់មិនត្រាស់បដិសេធថា មិនពិតនោះទេ គឺ រីករាយពិត ត្រេកត្រអាលពិត តែព្រះអង្គត្រាស់ថាជាហេតុនាំអោយកើតទុក្ខពិត ។

- ប្រយោជន៍នៃការអប់រំចំរើនសតិប្បដ្ឋាន គឺស្គាល់កិលេស ស្គាល់សេចក្តីប្រកាន់ខន្ធ ៥ ថាជាតួខ្លួន ថាជារបស់ខ្លួនដែល សេចក្តីប្រកាន់នោះគឺជានាមធម៌មួយប្រភេទ ជានាមធម៌គួរដល់ការលះបង់ គួរដល់ការរំលត់ដោយបញ្ញា ។

- បញ្ញាដែលចាក់ធ្លុះនូវឧបាទានក្ខន្ធទុក្ខ រមែងនាំពុទ្ធបរិស័ទ្ធហែហមអមដំណើរទៅតាមស្នាមព្រះបាទនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់រហូតដល់អមតៈ មហានគរដែលផុតចាកបញ្ចក្ខន្ធ ជានគរដែលផុតចាកជរានិងមរណៈ ។

- សទ្ធាមានតម្លៃជាងទ្រព្យសម្បត្តិ សទ្ធាជាពូជនៃគុណធម៌គ្រប់យ៉ាង មានទាន មានសីលជាដើម សទ្ធារមែងអប់រំចិត្តអោយមានសេចក្តីសន្តោស អោយមានសេចក្តីស្ងប់ ទ្រព្យសម្បត្តិមិនអាចនាំមកនូវគុណធមទាំងអស់នេះបានឡើយ សូម្បីទ្រព្យសម្បត្តិនោះច្រើនប៉ុណ្ណាក៏ដោយ ។

- សទ្ធាមិនមែនប្រែថាអស់ប្រាក់នោះទេ សទ្ធាគឺជាប្រភេទនៃអរូបធម៌ម្យ៉ាងដែលជឿជាក់នូវអ្វីដែលជាសេចក្តីពិតនៃជីវិត ហើយញុំាងចិត្តដែលប្រកបជាមួយនោះអោយថ្លាស្អាតចាក លោភៈ ទោសៈ ការវង្វេង សេចក្តីស្រវឹង និងការយល់ខុសជាដើម ។

- សទ្ធាជឿការត្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធ នាំមកនូវប្រយោជន៍ដ៏ធំធេង គឺ ការប្រព្រឹត្តតាមពាក្យប្រៀនប្រដៅរបស់ព្រះអង្គ ។

- សទ្ធាជាដៃសំរាប់ទទួលយកនូវគ្រប់គុណធម៌ទាំងអស់ រួមទាំងឱវាទរបស់ព្រះសម្មាសម្ពុទ្ធផង ។

- សទ្ធាជាទឹកសំរាប់លាងដៃអោយស្អាតបរិសុទ្ធបុគ្គលកំណាញ់ឈ្មោះថាមានដៃក្រខ្វក់ ទោះជាលាងដោយសាប៊ូមួយ ថ្ងៃ ៧ដងក៏ដោយ ។

- សទ្ធាជាភ្លើងសំរាប់ដុតបំពត់ចិត្តដែលរឹងរូសកោងកាចអោយមកជាទន់ភ្លន់ ស្លូតបូត គឺជាភ្លើងដុតបំផ្លាញនូវភាពស្មោកគ្រោកដែលជាប់នៅជាមួយចិត្ត ។

- សទ្ធាជាមេទ័ពនៃកុសលធម៌ ដឹកនាំកងទ័ពក្នុងការកំចាត់បង់នូវសត្រូវ គឺកិលេសដែលតែងតែរារាំងមិនអោយកុសលធម៌

ចំរើនឡើងបាន ។

- សទ្ធា សីល ចាគៈ បញ្ញា ជាគ្រឿងការពារ វិបត្តិអន្តរាយ ទុក្ខទោសគ្រោះថ្នាក់ ហើយនាំមកនូវសេចក្តីសុខកាយ សប្បាយចិត្ត រាល់ថ្ងៃនេះឯង ។

- សេចក្តីស្លាប់គឺបញ្ចប់ទុក្ខក្នុងមួយអត្តភាព មិនគួរអោយខ្លាចឡើយ ប៉ុន្តែរបស់ដែលគួរខ្លាចពិតប្រាកដ គឺកិលេសដែលមិនព្រមទទួលយកនូវការពិត មិនដឹងសេចក្តីពិតនៃជីវិត ។

**សតិជាថ្នាំបន្សាបការស្រវឹង ធម្មទានជាថ្នាំជំនួយសតិបញ្ញា សទ្ធាជ្រះថ្លាជាដៃដ៏ស្អាតសំរាប់ទទួលយកនូវអត្ថរសនៃព្រះធម៌ ៗ**

**សូមអនុមោទនាការសិក្សានិងការស្តាប់ព្រះធម៌**

**ឆ្នាំ ទី ៨ ព.ស ២៥៤០**

**ជំនួយសតិភាគ ២ ចប់**

បោះពុម្ព មួយម៉ឺក្បាល ជាធម្មទាន ដោយសទ្ធារបស់ពុទ្ធបរិស័ទច្រើនរូប ។